**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de Droit et des Sciences Économiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# បណ្តឹងឧបាស្រ័យក្នុងរឿងរដ្ឋប្បវេណី

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ហ៊ូ សុវណ្ណា**

កញ្ញា **សុខ ច័ន្ទម៉ានីន**

ណែនាំដោយ៖

លោកគ្រូ **សៅ ស៊ីវុត្ថា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទ **ហ៊ូ សុវណ្ណា** និងនាងខ្ញុំ **សុខ ច័ន្ទម៉ានីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២៣-២០២៤។

**យើងខ្ញុំសូមសម្តែងនូវសេចក្តីកតញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាវជ្រៅបំផុតជូនចំពោះ៖**

| | |
|---|---|
| លោកឪពុក **ហ៊ូ លី** | លោកឪពុក **សុខ ចាន់ថា** |
| អ្នកម្តាយ **ផាន់ ចំរើន** | អ្នកម្តាយ **ឈាង ស៊ីនាត** |

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតទៅដល់អ្នកមានគុណទាំងពីរដែលលោកមានគុណដ៏សែនមហាធំធេងចំពោះរូបកូនដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សា ថ្នាក់ថ្នម ផ្តល់នូវក្តីស្រឡាញ់ មេត្តា ករុណា ប្រកបដោយព្រហ្មវិហារធម៌អប់រំទូន្មានល្អៗប្រៀនប្រដៅ ដល់កូនឱ្យមានសេចក្តីអត់ធ្មត់ ព្យាយាម និងចេះតស៊ូនៅក្នុងជីវិត។ មិនត្រឹមតែប៉ុណ្ណោះ លោកអ្នកមានគុណទាំងពីរ ខិតខំប្រឹងប្រែង អស់ពីកម្លាំងកាយចិត្ត លះបង់គ្រប់បែបយ៉ាងទាំងស្មារតី ទាំងសម្ភារៈ និងទាំងប្រាក់កាស ដើម្បីឱ្យកូនទទួលបានចំណេះដឹងដ៏ប្រពៃថ្លៃថ្លា សម្រាប់ជាស្ពានចម្លង សម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ ទៅថ្ងៃអនាគត។

សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបាទចូលសិក្សានៅក្នុងសាកលវិទ្យាល័យនេះ និងបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្នុងអំឡុងពេល ៤ ឆ្នាំកន្លងមកនេះ យើងខ្ញុំបានទទួលនូវការអប់រំណែនាំ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ ព្រមទាំងផ្ទេរនូវចំណេះដឹងដល់យើងខ្ញុំ និងសិស្សដទៃទៀតតាំងពីថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់បរិញ្ញាបត្រពិតជាពុំអាចកាត់ថ្លៃបាន។

ជាពិសេស សូមថ្លែងអំណរគុណចំពោះលោកគ្រូ **សៅ ស៊ីវុត្ថា** ជាលោកគ្រូណែនាំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្រៀន ផ្តល់ដំបូន្មាន ផ្តល់យោបល់ ព្រមទាំងផ្តល់អនុសាសន៍ ទាំងផ្នែកស្មារតី និងឯកសារ ព្រមទាំងជួយត្រួតពិនិត្យកែតម្រូវចំណុចខ្វះខាត ជាពិសេស លោកបានជួយកែលម្អនូវចំណុចខុសឆ្គងដែលកើតមាន ព្រមទាំងការណែនាំ ដើម្បីរៀបចំក្នុងការស្រាវជ្រាវចងក្រង សារណាបញ្ចប់ការសិក្សាមួយនេះឡើង។

**គណៈគ្រប់គ្រងសាកលវិទ្យាល័យ សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកសិក្សា** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានលះបង់នូវរាល់ពេលវេលា និងកម្លាំងកាយចិត្ត ក្នុងការដឹកនាំ បង្ហាត់បង្រៀន និងជួយជ្រោមជ្រែងយ៉ាងយកចិត្តទុកដាក់ចំពោះនិស្សិតទាំងអស់កន្លង

មកឲ្យទទួលបននូវចំណេះដឹងដែលជាប្រទីបសម្រាប់បំភ្លឺផ្លូវនាពេលអនាគត ដែលអាចបង្គលក្ខណៈងាយស្រួលដល់ការសិក្សាយើងខ្ញុំ ។

**សូមមេត្តាទទួលនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត និងមិនអាចបំភ្លេចបាន ចំពោះឧបការគុណដ៏ធំធេងអំពីយើងខ្ញុំ។**

ជាទីបញ្ចប់នេះ យើងខ្ញុំ សូមលើកដៃប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់នៅក្នុងលោកនេះ សូមតាមជួយមើលថៃរក្សា ការពារ ដល់លោកអ្នកមានគុណ និងសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឲ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ៤ ឆ្នាំ រួចមក យើងខ្ញុំមានសេចក្តីសោមនស្ស រីករាយយ៉ាងក្រៃលែង ដោយទទួលបានចំណេះដឹងជំនាញនីតិសាស្ត្រលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងផ្នែកនីតិសាធារណៈ ក្រោមការខិតខំប្រឹងប្រែង ប្រកបដោយយកចិត្តទុកដាក់អប់រំ ផ្តល់ដំបូន្មាន ណែនាំ បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យទាំងអស់។

ជាលទ្ធផល ដោយសារតែមានការជួយជ្រោមជ្រែង និងការយកចិត្តទុកដាក់ទាំងអស់នេះហើយ ធ្វើឱ្យយើងខ្ញុំ បាទមានឱកាសក្នុងការបង្ហាញស្នាដៃតាមរយៈការសិក្សាស្រាវជ្រាវ និងសរសេរចងក្រងសារណាមួយនេះឱ្យលេចចេញជារូបរាងឡើង ដែលជាចំណងដៃក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររបស់យើងខ្ញុំ នៅក្រោមប្រធានបទ "**បណ្តឹងឧបាស្រ័យក្នុងរឿងរដ្ឋប្បវេណី**"។ ការចងក្រងសារណានេះឡើង គឺក្នុងគោលបំណង ជួយពង្រីកនូវចំណេះដឹងលើវិស័យរដ្ឋប្បវេណីក៏ដូចជាវិស័យច្បាប់ឱ្យកាន់តែមានភាពច្បាស់លាស់ និងស៊ីជម្រៅ ហើយយើងខ្ញុំសង្ឃឹមថា កម្រងសារណានេះនឹងចូលរួមជាចំណែកដ៏សំខាន់ សម្រាប់ជាឯកសារស្រាវជ្រាវបែបលក្ខណៈវិទ្យាសាស្ត្រថ្មីមួយ ដើម្បីជាមូលដ្ឋានដល់សិស្សនិស្សិត និងអ្នកស្រាវជ្រាវទាំងឡាយ ដែលកំពុងជួបនឹងលំបាកក្នុងការស្វែងរកឯកសារបំពេញបន្ថែមទាក់ទងនឹងនីតិវិធីរដ្ឋវេណីអំឡុងពេលសិក្សារៀនសូត្រ។

ក្នុងនាមយើងខ្ញុំ ជានិស្សិតដែលបានធ្វើការស្រាវជ្រាវ រៀបចំ ចងក្រងនូវសារណាមួយនេះឡើង យើងខ្ញុំសូមទទួលស្គាល់ថា ទោះបីជាសារណាមួយនេះត្រូវបានចងក្រងឡើង ដោយការខិតខំប្រឹងប្រែង យកចិត្តទុកដាក់ និងផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយក៏អាចនៅតែមានការភ្លេចភ្លាំង ខុសឆ្គងត្រង់ចំណុចណាមួយដោយអចេតនាជាក់ជាពុំខាន។ ហេតុដូច្នេះ យើងខ្ញុំសូមធ្វើការអភ័យទោសពីសំណាក់សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ និងមិត្តអ្នកអានទាំងឡាយទុកជាមុននូវរាល់កំហុសឆ្គង ចំណុចខ្វះខាតទៅលើឃ្លាឃ្លោងប្រយោគ ឬកំហុសអក្ខរាវិរុទ្ធទាំងឡាយ។ យើងខ្ញុំសូមស្វាគមន៍ជានិច្ចនូវរាល់មតិយោបល់រិះគន់ក្នុងន័យស្ថាបនា ដើម្បីធ្វើការកែលម្អសារណាមួយនេះឱ្យកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជដល់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ហើយយកចិត្តទុកដាក់ក្នុងការអានលើប្រធានបទនេះ សូមឱ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ និងទទួលបាននូវជោគជ័យគ្រប់ភារកិច្ច។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ** ............................................................ ៤

១.និយមន័យ បណ្តឹងឧបាស្រ័យ ............................................................ ៤

១.១.ទស្សនក្នុងបណ្តឹងឧបាស្រ័យ ............................................................ ៥

១.២.ការធ្វើបណ្តឹងឧបាស្រ័យ ............................................................ ៥

២.គោលបំណងនៃបណ្តឹងឧបាស្រ័យ ............................................................ ៦

២.១.ការសង្គ្រោះរបស់ភាគី ............................................................ ៦

២.២.ការចេញសេចក្តីសម្រេចដ៏ត្រឹមត្រូវ ឬ ផ្តល់យុត្តិធម៌ដល់ភាគី ............................................................ ៧

**ផ្នែកទី២៖ ភាពខុសគ្នាបណ្តឹងទាមទារឲ្យជម្រះសារជាថ្មី និងបណ្តឹងឧបាស្រ័យ** ............ ៧

១.បណ្តឹងទាមទារឲ្យជំនុំជម្រះសារជាថ្មី ............................................................ ៧

២.បណ្តឹងឧបាស្រ័យ ............................................................ ៨

**ផ្នែកទី៣៖ ប្រភេទនៃបណ្តឹងឧបាស្រ័យ** ............................................................ ៨

**ជំពូកទី២**

**បណ្តឹងឧទ្ធរណ៍**

**ផ្នែកទី១៖ និយមន័យ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍.** ............................................................ ១០

១.និយមន័យ ............................................................ ១០

២.មូលហេតុនៃបណ្តឹងឧទ្ធរណ៍ ............................................................ ១១

៣. កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ............................................................ ១៣

**ផ្នែកទី២៖ លក្ខខណ្ឌ និងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍** ............ ១៥
១. លក្ខខណ្ឌនៃបណ្ដឹងឧទ្ធរណ៍............ ១៥
១.១. អ្នកមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ ............ ១៥
១.២. អំឡុងពេលក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍............ ១៦
២. នីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ ............ ១៧
២.១. ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ............ ១៨
២.២. ការទទួលពាក្យបណ្ដឹងឧទ្ធរណ៍............ ១៨
២.៣. ការពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍............ ១៩
២.៤. ការបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍ ............ ១៩
២.៥. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់............ ១៩
**ផ្នែកទី៣៖ អានុភាពនៃការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍** ............ ២០
១.ការផ្អាកការចូលជាស្ថាពរនៃសាលក្រម............ ២០
២.ការផ្ទេរការជម្រះក្ដី ............ ២១
៣.អវិភាគភាពនៃបណ្ដឹងឧទ្ធរណ៍............ ២១
**ផ្នែកទី៤៖ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ និងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍**............ ២៣
១. បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ............ ២៣
២. ការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ............ ២៥
២.១. គោលការណ៍នៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍............ ២៥
២.២. ការទាញហេតុផលដោយផ្ទាល់មាត់............ ២៦
**ផ្នែកទី៥៖ ការបញ្ចប់បណ្ដឹងឧទ្ធរណ៍** ............ ២៨
១. ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ ............ ២៨
១.១. ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ............ ២៨
១.២. ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយសកម្មភាពភាគី............ ២៩

២. ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ. ...................... ៣២
២.១. សាលដីកាលើកចោលបណ្ដឹងឧទ្ធរណ៍. ...................................................... ៣២
២.២. សាលដីកាច្រានចោលបណ្ដឹងឧទ្ធរណ៍ ....................................................... ៣៣
២.៣. សាលដីកាទទួលស្គាល់បណ្ដឹងឧទ្ធរណ៍ ..................................................... ៣៤
២.៣.១. ការលុបចោល និងការវិនិច្ឆ័យដោយខ្លួនឯង ........................................ ៣៤
២.៣.២. ការលុបចោល និងការបញ្ជូនត្រលប់ទៅតុលាការដើមវិញ ........................ ៣៥
២.៣.៣. ការលុបចោល និងការផ្ទេរនូវរឿងក្ដីទៅតុលាការផ្សេង ............................. ៣៦

## ជំពូកទី៣

## បណ្ដឹងសារទុក្ខ

**ផ្នែកទី១៖ សញ្ញាណទូទៅនៃបណ្ដឹងសាទុក្ខ** .............................................................. ៣៨
១. និយមន័យ.................................................................................................. ៣៨
២. មូលហេតុនៃបណ្ដឹងសាទុក្ខ.......................................................................... ៣៨
៣. កម្មវត្ថុនៃបណ្ដឹងសាទុក្ខ .............................................................................. ៤២
**ផ្នែកទី២៖ លក្ខខណ្ឌ និងនីតិវិធីនៃបណ្ដឹងសាទុក្ខ** ................................................ ៤២
១. លក្ខខណ្ឌនៃបណ្ដឹងសាទុក្ខ.......................................................................... ៤២
១.១. អ្នកមានសិទ្ធិធ្វើបណ្ដឹងសាទុក្ខ ................................................................ ៤៣
១.២. អំឡុងពេលនៃការធ្វើបណ្ដឹងសាទុក្ខ ........................................................... ៤៣
១.២.១. អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងសាទុក្ខ ............................................. ៤៣
១.២.២. អំឡុងពេលនៃការដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ ............. ៤៤
២. នីតិវិធីនៃបណ្ដឹងសាទុក្ខ .............................................................................. ៤៤
២.១. ការទទួលពាក្យបណ្ដឹងសាទុក្ខ .................................................................... ៤៤
២.២. ការពិនិត្យពាក្យបណ្ដឹងសាទុក្ខ ................................................................... ៤៥
២.៣. ការបញ្ជូនពាក្យបណ្ដឹងសាទុក្ខ..................................................................... ៤៥
២.៤. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលផ្ទាល់មាត់ ................................. ៤៥
**ផ្នែកទី៣៖ អានុភាពនៃពាក្យបណ្ដឹងសាទុក្ខ** ........................................................... ៤៦

១. អានុភាពបង្អាក់ការចូលជាស្ថាពរ ........ ៤៦
២. អានុភាពនៃការផ្ទេរការជំនុំជម្រះក្តី ........ ៤៦
៣. អានុភាពអវិភាគនៃបណ្តឹងសាទុក្ខ ........ ៤៦
**ផ្នែកទី៤៖ បណ្តឹងសាទុក្ខឆ្លោះ និងការជំនុំជម្រះនៃបណ្តឹងសាទុក្ខ** ........ ៤៧
១. បណ្តឹងសាទុក្ខឆ្លោះ ........ ៤៧
២. ការជំនុំជម្រះនៃបណ្តឹងសាទុក្ខ ........ ៤៧
២.១. គោលការណ៍នៃការជំនុំជម្រះបណ្តឹងសាទុក្ខ ........ ៤៨
២.២. ការទាញហេតុដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី១ ........ ៤៨
២.៣. ការទាញហេតុដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី២ ........ ៤៩
**ផ្នែកទី៥៖ ការបញ្ចប់បណ្តឹងសាទុក្ខ** ........ ៥០
១. ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ........ ៥០
១.១. ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ ........ ៥០
១.២. ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី ........ ៥១
២. ការបញ្ចប់បណ្តឹងសាទុក្ខដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ........ ៥១
២.១. ការលើកចោលនូវបណ្តឹងសាទុក្ខដោយដីកាសម្រេច ........ ៥១
២.២. សាលដីកាច្រានចោលបណ្តឹងសាទុក្ខ ........ ៥២
២.៣. សាលដីកាទទួលស្គាល់នូវបណ្តឹងសាទុក្ខ ........ ៥២
២.៣.១. ការបដិសេធចោល និងបញ្ជូនត្រលប់ទៅតុលាការដើម ........ ៥២
២.៣.២. ការផ្ទេររឿងក្តីទៅតុលាការផ្សេង ........ ៥៣
២.៣.៣. ការបដិសេធ និងការវិនិច្ឆ័យដោយខ្លួនឯង ........ ៥៣
**ជំពូកទី៤**
**បណ្តឹងជំទាស់**
**ផ្នែកទី១៖ និយមន័យ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងជំទាស់** ........ ៥៥
១. និយមន័យ ........ ៥៥
២. មូលហេតុនៃបណ្តឹងជំទាស់ ........ ៥៦

៣. កម្មវត្ថុនៃបណ្តឹងជំទាស់ ........ ៥៦
**ផ្នែកទី២៖ លក្ខខណ្ឌ នីតិវិធី និងអានុភាពនៃបណ្តឹងជំទាស់** ........ ៥៧
១. លក្ខខណ្ឌ ........ ៥៧
១.១.អ្នកមានសិទ្ធិប្តឹងជំទាស់ ........ ៥៧
១.២. អំឡុងពេលនៃបណ្តឹងជំទាស់ ........ ៥៨
២. នីតិវិធីនៃបណ្តឹងជំទាស់ ........ ៥៨
២.១. ការទទួលពាក្យបណ្តឹងជំទាស់ ........ ៥៨
២.២. ការពិនិត្យពាក្យបណ្តឹងជំទាស់ ........ ៥៨
៣. អានុភាព ........ ៥៩
**ផ្នែកទី៣៖ វិសាលភាពនៃការជំនុំជម្រះលើបណ្តឹងជំទាស់** ........ ៥៩
១. វិសាលភាពនៃការជំនុំជម្រះបណ្តឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍ ........ ៥៩
២. វិសាលភាពនៃការជំនុំជម្រះបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់ចៅក្រម
ដែលទទួលការបញ្ជា ឬការប្រគល់សិទ្ធិ ........ ៦០
**សេចក្តីសន្និដ្ឋាន** ........ ៦២
**អនុសាសន៍** ........ ៦៤
**ឯកសារយោង**
**បញ្ជីរាយនាមឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា បានធ្លាក់ចូលក្នុងភ្លើងសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំ ដែលជាហេតុនាំឱ្យប្រព័ន្ធស្ទើរតែទាំងអស់ត្រូវបានបំផ្លិចបំផ្លេញ ក្នុងនោះរួមទាំងប្រព័ន្ធយុត្តិធម៌ក៏ត្រូវបានបំផ្លាញយ៉ាងដំណំ។ បើក្រឡេកមើលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រព័ន្ធយុត្តិធម៌ត្រូវបានបំផ្លាញទាំងស្រុង ឬអាចនិយាយបានថាបានធ្លាក់ដល់ចំណុចសូន្យ។ ប្រជាពលរដ្ឋស្លូតត្រង់ ទាំងប្រុសស្រី ទាំងក្មេងចាស់ ត្រូវទទួលរងនូវការកាប់សម្លាប់ដោយគ្មានមេត្តា ដោយគ្មានការជំនុំជម្រះរកយុត្តិធម៌នោះទេ។ គ្មានច្បាប់ គ្មានទម្លាប់អ្វីឡើយ ដោយគ្រប់យ៉ាងត្រូវបានគ្រប់គ្រងដោយអង្គការ ឱ្យតែអង្គការថាយ៉ាងមិច គឺយ៉ាងនោះ ថាសម្លាប់គឺសម្លាប់។ អង្គការអាចចោទប្រកាន់មនុស្សគ្រប់រូបថាប្រព្រឹត្តទោស ដោយមិនចាំបាច់មានភស្តុតាង ដោយមិនចាំបាច់វិនិច្ឆ័យវែកញែកឡើយ។ មានរូបភាពបង្ហាញពីភាពអយុត្តិធម៌ជាច្រើនរាប់សឹងតែមិនអស់។ តែក្រោយឆ្នាំ១៩៧៩ ប្រព័ន្ធយុត្តិធម៌បានទទួលនូវភាពរីកចម្រើនខ្លះៗ តែពុំសូវមានយុត្តិធម៌អ្វីធំដុំដែរ។ ក្រឡេកមកដល់ពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាវិស័យយុត្តិធម៌របស់ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ដោយគិតចាប់តាំងពីឆ្នាំ១៩៩៣ មកប្រព័ន្ធតុលាការបានបែងចែកជារចនាសម្ព័ន្ធ ថ្នាក់ ប្រភេទ បានយ៉ាងល្អប្រសើរ។ ដោយមានជំនួយពីប្រទេសបារាំង និងប្រទេសជប៉ុន បានធ្វើឱ្យប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជា ជាពិសេសប្រព័ន្ធតុលាការមានការរីកចម្រើនល្អប្រសើរជាងមុនឆ្ងាយ។ ទោះជាយ៉ាងណា យើងសង្កេតឃើញថាមានប្រជាជនតិចតួចណាស់ដែលបានយល់ដឹងថាពីនីតិវិធីក្នុងតុលាការពីថ្នាក់ក្រោមរហូតដល់ថ្នាក់ខ្ពស់ ជាពិសេសការយល់ដឹងពីបណ្តឹងឧបាស្រ័យឡើងទៅតុលាការជាន់ខ្ពស់។ នៅតែមានប្រជាជនខ្មែរតិចតួចបានយល់ដឹងថា ក្នុងរឿងក្តីរដ្ឋប្បវេណីនៅក្រោយពេលដែលសាលាដំបូងបានចេញសេចក្តីសម្រេច ដែលអាចជាសាលក្រម ឬដីកាសម្រេច រួច ហើយប្រសិនបើខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ ដោយខ្លួនយល់ថាសេចក្តីសម្រេចនោះធ្វើឡើងដោយផ្ទុយច្បាប់ គេអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅកាន់សាលាឧទ្ធរណ៍តាមតំបន់ ដើម្បីឱ្យតុលាការនេះ ធ្វើការជំនុំជម្រះតាមការទាមទាររបស់ខ្លួន។ មិនតែប៉ុណ្ណោះ នៅមានអ្នកខ្លះទៀតមិនបានដឹងផងថា អ្វីទៅជាបណ្តឹងសាទុក្ខ ឬបណ្តឹងជំទាស់ទៀតផង។ ដោយសង្កេតឃើញថាមានបញ្ហាអសកម្មទាំងនេះហើយ ទើបជម្រុញទឹកចិត្តឱ្យយើងខ្ញុំលើកយកប្រធានបទស្តីពី "**បណ្តឹងឧបាស្រ័យក្នុងរឿងរដ្ឋប្បវេណី**" ដើម្បីយកមកធ្វើការពន្យល់ និងធ្វើការស្រាយបំភ្លឺឱ្យកាន់តែច្បាស់។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅពេលដែលយើងធ្វើការលើកយក ប្រធានបទស្តីពី "**បណ្តឹងឧបាស្រ័យក្នុងរឿងរដ្ឋប្បវេណី**" នេះមកនិយាយ នោះនឹងមានចម្ងល់ចោទឡើងថា៖

- តើអ្វីទៅជាបណ្តឹងឧបាស្រ័យ?
- អ្វីទៅជារឿងក្តីរដ្ឋប្បវេណី?
- តើបណ្តឹងប្រភេទនេះមានប៉ុន្មានប្រភេទ? អ្វីខ្លះ?
- តើដើម្បីធ្វើបណ្តឹងទាំងនោះ យើងត្រូវធ្វើអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវអំពីប្រធានបទនេះ គឺដើម្បីដោះស្រាយនូវរាល់ចម្ងល់ទាក់ទងនឹងបណ្តឹងឧបាស្រ័យទាំងនេះជូនសិស្សនិស្សិតទាំងឡាយឱ្យបានយល់កាន់តែច្បាស់។ យើងសង្ឃឹមថាមិត្តៗអ្នកស្រាវជ្រាវនឹងបានកើនចំណេះដឹងទុក្ខជាឯកសារសម្រាប់សិស្សៗ។ មិនតែប៉ុណ្ណោះ យើងខ្ញុំក៏ចង់រួមចំណែក ក្នុងការពង្រីកចំណេះដឹងផ្នែកទូទៅផ្នែកច្បាប់ជូនដល់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ ជាពិសេសប្រជាជនកម្ពុជាដែលពុំសូវឬពុំមានការយល់ដឹងអំពីនីតិវិធីនៃការធ្វើបណ្តឹងឧបាស្រ័យក្នុងរឿងក្តីរដ្ឋប្បវេណី ទាំងនៅសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការ កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ យើងខ្ញុំជឿជាក់យ៉ាងមុតមាំថាស្នាដៃនេះនឹងអាចចូលរួមចំណែកលើកស្ទួយប្រព័ន្ធនីតិរដ្ឋនៅកម្ពុជា ឱ្យកាន់តែល្អប្រសើរឡើងថែមមួយកម្រិតទៀត និងចូលរួមចំណែកលើកស្ទួយវឌ្ឍនភាពភាពនៃចំណេះដឹងផ្នែកច្បាប់ដល់ប្រជាជនខ្មែរ។ លើសពីនេះគឺ ដើម្បីចងក្រងបង្កើតជាស្នាដៃនេះឡើង យើងខ្ញុំបានធ្វើការសិក្សាស្វែងយល់ផ្នែកទ្រឹស្តីពីសាស្ត្រាចារ្យជាច្រើន ហើយបានធ្វើការស្រាវជ្រាវឯកសារនៅតាមបណ្ណាល័យជាច្រើនកន្លែង ដូចជាបណ្ណាល័យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជាដើម ដោយធ្វើការប្រមែប្រមូលឯកសារដែលពាក់ព័ន្ធពីប្រភព ទាំងនោះយកមកធ្វើការវិភាគដោយច្បិចយកតែព័ត៌មានសំខាន់ៗ មានតម្លៃសម្រាប់ចងក្រងជាស្នាដៃនេះឡើង។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ យើងនឹងធ្វើការផ្តោតសំខាន់ទៅលើក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។ ចំពោះដែនកំណត់នៃការសិក្សាស្រាវជ្រាវប្រធាននេះ គឺធ្វើការបកស្រាយ និងសិក្សាស្រាវជ្រាវនៅក្នុងដំណាក់កាលរបស់សាលាដំបូង, សាលាឧទ្ធរណ៍ និងតុលាការកំពូល ហើយយើងនឹងធ្វើការសិក្សាស្រាវជ្រាវតែក្នុងរឿងក្តីរដ្ឋប្បវេណីតែប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលនូវរឿងព្រហ្មទណ្ឌ ឬអនុវត្តដោយបង្ខំឡើយ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការជ្រើសរើសប្រធានបទខាងលើមកធ្វើការសិក្សាស្រាវជ្រាវ គឺចង់បង្ហាញឱ្យអ្នកសិក្សាគ្រប់មជ្ឈដ្ឋានក៏ដូចជាប្រជាពលរដ្ឋគ្រប់រូប មានស្វែងយល់ឱ្យបានកាន់តែច្បាស់ និងស៊ីជម្រៅទៅលើនីតិវិធិនៃបណ្តឹងរដ្ឋប្បវេណីក្នុងដំណាក់កាលនានា រួមមានដំណាក់កាលត្រៀមសម្រាប់ការទាញហេតុផល និងដំណាក់កាលទាញហេតុផល

ជាដើម។ ហេតុដូច្នេះ ការសិក្សាស្រាវជ្រាវប្រធានបទមួយនេះ គឺមានសារៈសំខាន់ណាស់ ដើម្បីជាចំណេះដឹងទូទៅក្នុងការធ្វើបណ្តឹង ព្រមទាំងទុកជាឯកសារមួយ ដើម្បីជាជំនួយដល់សិស្សនិស្សិត នឹងអ្នកសិក្សាស្រាវជ្រាវ ដែលមានគោលបំណងចង់សិក្សាស្វែងយល់អំពីប្រធានមួយនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះ ផ្តោតសំខាន់ទៅលើបណ្តឹង ៣ (បី) សំខាន់ៗ រួមមានបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និង បណ្តឹងជំទាស់ ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីក្នុងគន្ថីទី៣។ ដោយឡែក ខ្លឹមសារនៃប្រធានបទសារណានេះ ត្រូវបានបែងចែកជា ៤ (បួន) ជំពូកធំៗ

- ជំពូកទី១ គឺសញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ
- ជំពូកទី២ និយាយពីបណ្តឹងឧទ្ធរណ៍
- ជំពូកទី៣ គឺបណ្តឹងសាទុក្ខ និង
- ជំពូកទី ៤ គឺបណ្តឹងជំទាស់។

# ជំពូកទី១
# សញ្ញាណទូទៅ
# នៃបណ្ដឹងឧបាស្រ័យ

# ជំពូកទី១
# សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ

នៅក្នុងរឿងក្តីរដ្ឋប្បវេណី បណ្តឹង គឺជាសិទ្ធិមួយដែលច្បាប់ទទួលស្គាល់សម្រាប់បុគ្គលឯកជនអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងការធ្វើបណ្តឹងទៅស្ថាប័នតុលាការ ដើម្បីដោះស្រាយនូវបញ្ហាដែលកើតមានឡើងក្នុងគោលបំណងទាមទារឱ្យតុលាការចេញសាលក្រមតាមការទាមទារដោយផ្អែកតាមភស្តុតាង និងគតិច្បាប់ជាធរមាន។ យើងក៏អាចបកស្រាយបានម្យ៉ាងទៀតផងដែរថា បណ្តឹងរដ្ឋប្បវេណី គឺជាលិខិតជាលាយលក្ខណ៍អក្សរដែលរៀបចំឡើងដោយដើមចោទធ្វើការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារដោយផ្អែកតាមច្បាប់សារធាតុ និងច្បាប់ទម្រង់ ចំពោះភាគីម្ខាងទៀតហៅថាចុងចម្លើយ។[1] ដូច្នេះ វាជាសកម្មភាពទាមទារមួយដែលបានធ្វើឡើងដោយដើមចោទចំពោះចុងចម្លើយ ទៅតុលាការដែលមានសមត្ថកិច្ចក្នុងការជំនុំជម្រះក្តីដោយអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ហើយទាមទារឱ្យតុលាការចេញសេចក្តីសម្រេច ជាសាលក្រម ឬសាលដីកា ឬដីកាសម្រេចជាដើម។ ចំណែកឯ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះទៀតសោត ក៏ជាបណ្តឹងតវ៉ារបស់ភាគី ដែលពុំយល់ស្របជាមួយនឹងសេចក្តីសម្រេចណាមួយ អាចជាសាលក្រម សាលដីកា ឬដីកាសម្រេចរបស់ចៅក្រម ឬតុលាការ ដើម្បីទាមទារឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើមណាមួយដែលភាគីមិនពេញចិត្ត ដោយភាគីទាមទារក្នុងបណ្តឹងឧបាស្រ័យ។

ជាទូទៅ មុននឹងឈានចូលដល់ការសិក្សាអំពីប្រភេទនៃបណ្តឹងនីមួយៗនៃបណ្តឹងឧបាស្រ័យ យើងត្រូវសិក្សាស្វែងយល់ឱ្យច្បាស់ជាមុនអំពីសញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ ដែលអត្ថន័យនៃបណ្តឹងឧបាស្រ័យនេះដោយផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី នឹងត្រូវបានបកស្រាយនៅចំណុចបន្ទាប់។

## ផ្នែកទី១៖ សញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ

នៅក្នុងផ្នែកនេះ យើងនឹងធ្វើការបកស្រាយអំពីសញ្ញាណទូទៅនៃបណ្តឹងឧបាស្រ័យ រួមបញ្ចូលទាំងនិយមន័យបណ្តឹងឧបាស្រ័យ និងគោលបំណងនៃបណ្តឹងឧបាស្រ័យ។

### ១. និយមន័យនៃបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យ គឺជាបណ្តឹងទៅកាន់តុលាការជាន់ខ្ពស់ ដែលទាមទារដោយភាគីទៅតុលាការជាន់ខ្ពស់ឱ្យលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេច ដែលចេញដោយតុលាការថ្នាក់ក្រោម ឬតុលាការជាន់ទាប នៅមុនពេលសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ឬតុលាការជាន់ទាបបានចូលជាស្ថាពរ ចំពោះសេចក្តីសម្រេចនោះ ភាគីដែលមិនសុខចិត្តនឹងសេចក្តីសម្រេចតុលាការអាចប្តឹងទៅកាន់តុលាការជាន់ខ្ពស់បានតាមរយៈបណ្តឹងឧបាស្រ័យ ដែលបណ្តឹងទាំងនោះរួមមាន៖ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់។

[1] មាត្រា ៣២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ១.១. ទស្សនគ្គុខបណ្តឹខឧបាស្រ័យ

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជានីតិវិធីធ្វើឧបាស្រ័យទាមទារដោយភាគីទៅតុលាការជាន់ខ្ពស់ឱ្យលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេចដែលចេញដោយសាលាដំបូងរាជធានីខេត្ត នៅមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ[2]។ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះ អាចធ្វើទៅបានតែមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរតែប៉ុណ្ណោះ។ ស្របគ្នានេះផងដែរ នៅពេលដែលមានបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាសេចក្តីសម្រេចដើមនោះ ដែលមិនទាន់ចូលជាស្ថាពររហូតដល់ដំណើរការឧបាស្រ័យទៅតុលាការជាន់ខ្ពស់នោះបានបញ្ចប់។ [3] ផ្ទុយទៅវិញ យើងអាចនិយាយបានថាការចូលជាស្ថាពរនៃសេចក្តីសម្រេចមួយគឺជាស្ថានភាពដែលសេចក្តីសម្រេចនោះ មិនអាចធ្វើការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ ។

### ១.២. ភារធ្វើបណ្តឹខឧបាស្រ័យ

ភាគីអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន មុនពេលសេចក្តីសម្រេចមិនទាន់ចូលជាស្ថាពរ តែប៉ុណ្ណោះ។ ហេតុដូចនេះអាចនិយាយបានថាបើសេចក្តីសម្រេចនោះចូលជាស្ថាពរគឺមិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ។ ចំពោះសេចក្តីសម្រេចដែលមិនទាន់ចូលជាស្ថាពរដែលភាគីអាចប្តឹង ឧបាស្រ័យបានមានដូចជា៖ សាលក្រម ឬសាលដីកា ឬដីកាសម្រេច។ ផ្ទុយមកវិញសេចក្តីសម្រេចដែលបានចូលជាស្ថាពរគឺអាចប្រើប្រាស់បណ្តឹងផ្សេងទៀតទៅតុលាការបាន ក្រៅពីបណ្តឹងឧបាស្រ័យ តែជាមធ្យោបាយឧបាស្រ័យដដែល គឺបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។

ចំពោះសាលក្រម ឬ សាលដីកា ភាគីអាចធ្វើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខបាន។ ដោយបណ្តឹងឧទ្ធរណ៍ធ្វើឡើងដើម្បីផ្លាស់ប្តូរ ឬ លុបចោលនូវសាលក្រមដែលមិនទាន់ចូលជាស្ថាពររបស់សាលាដំបូង ឬ អាចធ្វើបណ្តឹងសាទុក្ខក្នុងករណីគូភាគីបានព្រមព្រៀងមិនប្តឹងឧទ្ធរណ៍ ហើយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ ក្រោយពីតុលាការបានចេញសាលក្រមចុងក្រោយ។[4] ចំណែកបណ្តឹងសាទុក្ខធ្វើឡើងចំពោះសាលដីកាដែលមិនទាន់ចូលជាស្ថាពររបស់សាលាឧទ្ធរណ៍។

ចំណែកបណ្តឹងជំទាស់វិញ គឺជាបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់តុលាការជាន់ទាប ប៉ុន្តែបណ្តឹងជំទាស់នេះអាចធ្វើទៅបានលុះត្រាតែមានបញ្ញត្តិក្នុងច្បាប់។[5] ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៣០២ ចំពោះដីកាសម្រេចដែលអាចប្តឹងជំទាស់បាន គឺជាដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ពោលភាគីអាចប្តឹងឧបាស្រ័យបាននៅពេលដែលភាគីមិនពេញចិត្តនឹងដីកាសម្រេចនោះ។

[2] មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[3] មាត្រា ១៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[4] មាត្រា២៥៩ កថាខណ្ឌទី១ ចំណុច ក និង ខ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[5] មាត្រា២៥៩ កថាខណ្ឌទី១ ចំណុច គ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

លើសពីនេះទៅទៀត កាលណាភាគីដែលបានប្ដឹងជំទាស់ចំពោះដីកាសម្រេចដែលមានចែងក្នុងក្រមរួចហើយ មិនអាចប្ដឹងជំទាស់ទៅលើដីកាសម្រេចចំពោះបណ្ដឹងជំទាស់មុនបានឡើយ។

## ២. គោលបំណងនៃបណ្ដឹងឧបាស្រ័យ

នីតិវិធីរដ្ឋប្បវេណី មានគោលបំណងការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ។ ក្នុងគោលបំណងនេះ បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។[6] បណ្ដឹងរដ្ឋប្បវេណី ដោះស្រាយវិវាទ រវាងភាគីដោយបង្ខំភាគីដោយផ្ទាល់គោរពតាមសេចក្ដីសម្រេចរបស់តុលាការ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបង្កើតប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីនេះឡើង មិនមែនក្នុងគោលបំណងធ្វើការដោះស្រាយវិវាទនោះទេ តែគឺដើម្បីធ្វើការទទួលស្គាល់តាមរយៈតុលាការ ថាបុគ្គលណាម្នាក់មានសិទ្ធិស្របច្បាប់ និងដើម្បីការពារសិទ្ធិរបស់បុគ្គលនោះ ដោយបញ្ចប់នូវវិវាទ ហេតុដូច្នេះវាមិនមែនមានន័យថា ការដោះស្រាយវិវាទអាចនាំកើតជាលទ្ធផលអ្វីដល់ភាគីនោះទេ។ ម្យ៉ាងទៀត នីតិវិធីរដ្ឋប្បវេណីអាចសម្រេចគោលដៅបាន លុះត្រាតែមានការដោះស្រាយមួយដ៏ត្រឹមត្រូវ ហើយសិទ្ធិរបស់បុគ្គលដែលជាម្ចាស់សិទ្ធិនោះ ត្រូវបានទទួលស្គាល់ដោយផ្អែកទៅលើច្បាប់។ ការការពារសិទ្ធិតាមរយៈនីតិវិធីរដ្ឋប្បវេណីបែបនេះ មិនមែនជាការដាក់ទានពីរដ្ឋទៅប្រជាពលរដ្ឋនោះទេ។ ផ្ទុយទៅវិញ គេត្រូវយល់ថា បុគ្គលឯកជនគ្រប់រូប ទាំងជនបរទេស និងជនជាតិខ្មែរ មានសិទ្ធិដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីស្វែងរកការការពារសិទ្ធិរបស់ខ្លួន កាលណាសិទ្ធិនោះត្រូវបានគេបំពាននៅក្នុងវិវាទរដ្ឋប្បវេណី ។[7]

### ២.១. ការសង្គ្រោះរបស់ភាគី

ថ្វីត្បិតតែតុលាការគឺជាស្ថាប័នឯករាជ្យមួយ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកនូវយុត្តិធម៌ឲ្យប្រជាពលរដ្ឋ ក៏ប៉ុន្តែនៅក្នុងនោះក៏មានភាពខ្វះចន្លោះមួយចំនួននៃការវិនិច្ឆ័យសេចក្ដីរបស់ចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះពីព្រោះរាល់ការសម្រេចសេចក្ដីដែលធ្វើឡើងដោយមនុស្ស ការវិនិច្ឆ័យ ខុស ឬ ការភ័ន្តច្រលំណាមួយតែងតែកើតមានដោយជៀសមិនរួច ។ ក៏ប៉ុន្តែ ប្រសិនបើទុកឱ្យស្ថានភាពនៅតែដូច្នេះតទៀត កំហុសនោះគឺមិនត្រឹមតែបំពានសិទ្ធិរបស់ភាគីប៉ុណ្ណោះទេ គឺធ្វើឱ្យប្រជាពលរដ្ឋបាត់បង់នូវជំនឿទុកចិត្តចំពោះប្រព័ន្ធតុលាការថែមទៀតផង ។ ដូច្នេះហើយ បានជាចាំបាច់ត្រូវមាននូវប្រព័ន្ធមួយតាមរយៈពាក្យបណ្ដឹង ឬពាក្យសុំរបស់ភាគីណាម្ខាងមិនសុខចិត្តនឹងសេចក្ដីសម្រេច ឬដីកាសម្រេចរបស់តុលាការថ្នាក់ក្រោម។ តាមរយៈនោះតុលាការជាន់ខ្ពស់អាចនឹងពិនិត្យ មើលនូវសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោមបាន ដោយផ្អែកតាមពាក្យសុំរបស់ភាគីម្ខាងដែលមិនសុខចិត្តចំពោះសេចក្ដីសម្រេចនោះ ហើយប្រសិនបើសេចក្ដីសម្រេចថ្នាក់ក្រោមនោះមិនត្រឹមត្រូវ តុលាការថ្នាក់ខ្ពស់ជាងនោះ

[6] មាត្រា ២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[7] មាត្រា ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

អាចធ្វើការកែប្រែ ឬលុបចោលនូវសេចក្តីសម្រេចនោះបាន នេះគេហៅថា **"របបប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់"** ។ ដោយសារ របបប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាប្រព័ន្ធមួយដែលតុលាការជាន់ខ្ពស់កែតម្រូវនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយរង់ចាំពាក្យសុំឧបាស្រ័យ ហេតុដូច្នេះ អាចហៅផងដែរថា របបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាយន្តការមួយសម្រាប់ធ្វើការសង្គ្រោះសិទ្ធិភាគីឱ្យរួចផុតពីឥទ្ធិពលនៃការវិនិច្ឆ័យខុស ឬកំហុសក្នុងនីតិវិធីនៃការជំនុំជម្រះ ។

### ២.២. ការចេញសេចក្តីសម្រេចដ៏ត្រឹមត្រូវ ឬ ផ្តល់យុត្តិធម៌ដល់ភាគី

តាមរយៈការអនុញ្ញាតឱ្យធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានរឿងក្តីជាច្រើន ដែលត្រូវបានពិនិត្យ និងធ្វើការជំនុំជម្រះបន្តដោយតុលាការជាន់ខ្ពស់មួយចំនួនតូច ហើយចុងបំផុតក្រោយ គឺតុលាការកំពូល។ ដើម្បីបានជាលទ្ធផលរួមមួយ ដែលជាសេចក្តីសម្រេចចុងក្រោយបានសេចក្តីថាសេចក្តីសម្រេចតាមសាលាដំបូង និងសាលាឧទ្ធរណ៍ត្រូវបានបង្រួបបង្រួមក្លាយទៅជាការបកស្រាយ និងអនុវត្តតែមួយដោយតុលាការកំពូល។ ហើយការរួមបញ្ចូលនូវការបកស្រាយច្បាប់នេះទៀតសោត គឺតុលាការត្រូវធានានូវប្រព័ន្ធគតិយុត្តដែលប្រកបដោយស្ថេរភាពមានសណ្តាប់ធ្នាប់ និងប្រកបដោយ តុល្យភាពក្នុងនាមជាការតាំង នាមឱ្យប្រជារាស្ត្រខ្មែរ។

## ផ្នែកទី២៖ ភាពខុសគ្នារវាងបណ្តឹងទាមទារឲ្យជំនុំជម្រះសារជាថ្មី និងបណ្តឹងឧបាស្រ័យ

នៅក្នុងផ្នែកនេះនឹងធ្វើការបកស្រាយនូវភាពខុសគ្នារវាង បណ្តឹងទាមទារឲ្យជំនុំជម្រះសារជាថ្មី និងបណ្តឹងឧបាស្រ័យ ដោយមានលក្ខខណ្ឌមួយចំនួនដូចជា៖

### ១. បណ្តឹងទាមទារឲ្យជំនុំជម្រះសារជាថ្មី

បណ្តឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី គឺជានីតិវិធីក្នុងការប្តឹងទៅលើសេចក្តីសម្រេចទៅកាន់តុលាការដើមដែលបានចូលជាស្ថាពរ ដើម្បីឱ្យតុលាការធ្វើការពិនិត្យ និងវិនិច្ឆ័យឡើងវិញម្តងទៀត ដោយមូលហេតុដូចជា៖

- សេចក្តីសម្រេចមានការខ្វះចន្លោះក្នុងដំណើរការនីតិវិធីនៃបណ្តឹង។
- ឯកសារដែលជាមូលដ្ឋាននៃសេចក្តីវិនិច្ឆ័យសាលក្រម ឬសាលដីកាមានវិការៈធ្ងន់ធ្ងរ ឬមានភាពខ្វះខាតមិនប្រក្រតីដែលបានចូលជាស្ថាពររួចហើយ។
- មានជាច្រើនចំណុចទៀតដែលមានចែងក្នុងមាត្រា ៣០៧ និងមាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ក្នុងនោះដែរតុលាការដែលមានសមត្ថកិច្ច ក្នុងការជំនុំជម្រះចំពោះបណ្តឹងទាមទារឱ្យជំនុំជម្រះជាថ្មី គឺតុលាការដែលបានចេញសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរនោះ។ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចធ្វើឡើងដោយតតិយជនបាន ក្នុងករណីដែលភាគីដើមចោទ និងចុងចម្លើយរួមគំនិតគ្នាទទួលយកនូវសាលក្រម ឬ សាលដីកា ក្នុងបំណងដែលធ្វើឱ្យតតិយជនបាត់បង់សិទ្ធិ និងផលប្រយោជន៍។ ក្នុង

ករណីនេះគឺ ដើមចោទ និងចុងចម្លើយក្លាយជាសហចុងចម្លើយ។ ចំពោះនីតិវិធីនៃការជំនុំជម្រះសាជាថ្មី ត្រូវយកនីតិវិធីនៃការជំនុំជម្រះលើកទី១ មកអនុវត្តដូចគ្នាផងដែរ។

ដូចនេះចំពោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីអាចធ្វើទៅបាន លុះត្រាតែសេចក្តីសម្រេចនោះចូលជាស្ថាពរ ដែលជាសាលក្រម ឬសាលដីកាចុងក្រោយ តែមិនមានដីកាសម្រេចដែលអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ។

## ២. បណ្តឹងឧបាស្រ័យ

ចំពោះបណ្តឹងឧបាស្រ័យវិញ គឺភាគីមានសិទ្ធិប្តឹងទៅតុលាការជាន់ខ្ពស់បាន ប្រសិនបើគិតថាខ្លួនបានបាត់បង់ផលប្រយោជន៍។ ប៉ុន្តែការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ លុះត្រាតែសេចក្តីសម្រេចរបស់តុលាការអាចជាសាលក្រម ឬដីកាសម្រេចដែលមិនទាន់ចូលជាស្ថាពរ ក៏អាចប្តឹងបានដែរ ដើម្បីលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេចដើម។ ដូច្នេះបណ្តឹងឧបាស្រ័យធ្វើទៅបាន បើសិនបើសេចក្តីសម្រេចរបស់តុលាការជាន់ទាបដែលជាសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេច មិនទាន់ចូលជាស្ថាពរ ។ តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខនៃការជំនុំជម្រះឧបាស្រ័យគឺ តុលាការជាន់ខ្ពស់ជាងតុលាការដែលបានចេញសេចក្តីសម្រេច រួមមានសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចមិនទាន់ចូលជាស្ថាពរនោះ។

សរុបមកវិញ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងបណ្តឹងឧបាស្រ័យ មានល័ក្ខខ័ណ្ឌខុសគ្នាត្រង់ថាមូលហេតុដែលនាំឱ្យមានការធ្វើបណ្តឹងទាំងពីរ ហើយបណ្តឹងឧបាស្រ័យធ្វើឡើងចំពោះសេចក្តីសម្រេចមិនទាន់ចូលជាស្ថាពរ ប៉ុន្តែបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីធ្វើឡើងចំពោះ សេចក្តីសម្រេចដែលចូលជាស្ថាពរ និងខុសគ្នាទៀតត្រង់ថាតុលាការដែលសមត្ថកិច្ចផ្តាច់មុខចំពោះបណ្តឹងនីមួយៗ ។ ម៉្យាងវិញទៀត ភាគីអាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីបាន ចំពោះដីកាសម្រេចចូលជាស្ថាពរហើយ។ ក្នុងចំណោមដីកាសម្រេចដែលបានធ្វើឡើងជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាចុងក្រោយ ហើយបើមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្នុងដីកាសម្រេចនោះភាគីអាចធ្វើការប្តឹងទាមទារឱ្យមានការជំនុំ ជម្រះសាជាថ្មីដែលខុសពីបណ្តឹងឧបាស្រ័យដោយសមត្ថកិច្ចឱ្យជំនុំជម្រះសាជាថ្មី គឺជាសមត្ថកិច្ចរបស់តុលាការកំពូល។ ការប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវតែមានមូលហេតុ ដែលមានចែងក្នុងមាត្រា ៣០៧ និងមាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ផ្នែកទី៣៖ ប្រភេទនៃបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានបីប្រភេទ គឺ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និងបណ្តឹងជំទាស់។ ចំពោះបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការ ជាន់ខ្ពស់ចំពោះសាលក្រម និងសាលដីកា។ សម្រាប់បណ្តឹងជំទាស់វិញ គឺជាបណ្តឹងឧបាស្រ័យទៅ តុលាការជាន់ខ្ពស់ចំពោះដីកាសម្រេច។[8]

[8] មាត្រា ២៥៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ហេតុដូច្នេះហើយ បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានប្រភេទផ្សេងៗគ្នា ដែល បែងចែកទៅតាមប្រភេទនៃសេចក្ដីសម្រេចដើមដែលក្នុងនោះបុគ្គលដែលមានបំណងដាក់ពាក្យប្ដឹង ឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវជ្រើសរើសប្រភេទនៃបណ្ដឹងឧបាស្រ័យឱ្យបានត្រឹមត្រូវ ដោយស្របទៅតាមប្រភេទនៃសេចក្ដីសម្រេចដើម ដូចនេះក្នុងជំពូកបន្ទាប់នឹងធ្វើការបកស្រាយលម្អិតអំពីប្រភេទនីមួយៗនៃបណ្ដឹងឧបាស្រ័យ។

# ជំពូកទី២
# បណ្តឹងឧទ្ធរណ៍

# ជំពូកទី២
# បណ្តឹងឧទ្ធរណ៍

នៅក្រោយពេលដែលសាលាដំបូង បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងបានចេញសេចក្តីសម្រេចដែលហៅថាសាលក្រមរួចមក ភាគីដែលកើតទុក្ខមិនសុខចិត្តនឹងសេចក្តីសម្រេចដែលបានកំណត់ក្នុងសាលក្រមនោះ ភាគីក៏អាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។ នីតិវិធីនេះ ជាការធ្វើបណ្តឹងឧទ្ធរណ៍ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ដែលជាតុលាការនៃការជំនុំជម្រះលើកទី២។ យ៉ាងណាមិញនៅក្នុងលំហូរនៃនីតិវិធីនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ដោយត្រូវអនុវត្តនៅតាមនីតិវិធី ដែលច្បាប់បានកំណត់ទុក ដើម្បីឲ្យជ្រាប និងស្វែងយល់ឲ្យកាន់តែច្បាស់អំពីបណ្តឹងឧទ្ធរណ៍ និងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ នឹងធ្វើការបកស្រាយលម្អិតនៅផ្នែកនីមួយៗខាងក្រោម៖

## ផ្នែកទី១៖ និយមន័យ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍

នៅក្នុងផ្នែកនេះ នឹងធ្វើការបកស្រាយលម្អិតតាមរយៈ និយមន័យ មូលហេតុ និងកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ដូចមានខាងក្រោម៖

### ១. និយមន័យនៃបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍គឺជាប្រភេទមួយនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់តុលាការជាន់ទាបដែលហៅថាសាលាដំបូង ក្នុងគោលបំណងលុបចោល ឬផ្លាស់ប្តូរនូវសាលក្រមចុងក្រោយរបស់សាលាដំបូង។ ដូច្នេះមានន័យថា បណ្តឹងឧទ្ធរណ៍អាចធ្វើទៅបាន ចំពោះតែសាលក្រមដែលបានសម្រេចចុងក្រោយនៃការជំនុំជម្រះលើកទី១ តែប៉ុណ្ណោះ។[9] ចំពោះតុលាការដែលជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវបានហៅថា តុលាការនៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ ជាតុលាការជាន់ខ្ពស់ដែលមានសមត្ថកិច្ចជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ ហើយការជំនុំជម្រះដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវហៅថា **ការជំនុំជម្រះលើកទី ២** ការជំនុំជម្រះនេះគឺដើម្បីវិនិច្ឆ័យរកភាពត្រឹមត្រូវ ឬភាពមិនត្រឹមត្រូវលើបណ្តឹងឧបាស្រ័យលើសាលក្រមនៃការជំនុំជម្រះលើកទី១ ដោយធ្វើការពិនិត្យឡើងវិញលើអង្គហេតុ និងអង្គច្បាប់ ចំពោះការទាមទារនៃការជំនុំជម្រះលើកទី១។ ឧទាហរណ៍៖ នៅពេលដែលតុលាការនៃសាលាដំបូង យល់ព្រមទទួលយកពាក្យបណ្តឹង និងអនុវត្តនីតិវិធី នោះហៅថា ការជំនុំជម្រះលើកទី១ រហូតដល់ពេលដែល សេចក្តីសម្រេចរបស់តុលាការនៃសាលាដំបូងនោះចេញសេចក្តីសម្រេចដលជាសាលក្រម ភាគីណាមួយដែលមិនពេញចិត្តចំពោះការសម្រេចនោះ អាចធ្វើបណ្តឹងឧទ្ធរណ៍បាន ហើយតុលាការនៃសាលាឧទ្ធរណ៍នឹងត្រួតពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍ និងអនុវត្តនីតិវិធីនៃបណ្តឹងបន្តនោះគេហៅថា ការជំនុំជម្រះលើកទី២។

[9] មាត្រា ២៥៩ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

យ៉ាងណាមិញក្នុងករណីមួយចំនួនតាមបញ្ញត្តិពិសេសដូចជា សេចក្តីសម្រេចរបស់គណៈមេធាវីជាអាទិ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ជាតុលាការនៃការជំនុំជម្រះលើកទី១ដែរ។ ដូច្នេះហើយ បណ្តឹងឧទ្ធរណ៍អាចនឹងធ្វើឡើងបានតែចំពោះសាលក្រមចុងក្រោយ នៃការជំនុំជម្រះលើកទី ១ តែប៉ុណ្ណោះ ចំពោះសាលក្រមរបៀប មិនអាចប្តឹងឧទ្ធរណ៍ឯករាជ្យដោយ ឯកឯងបានឡើយ ឬម៉្យាងទៀតបណ្តឹងឧបាស្រ័យចំពោះសាលដីកា ចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលចេញក្នុងនាមជាការជំនុំជម្រះលើកទី១ អាចប្តឹងបានដល់បណ្តឹងសាទុក្ខ។ ថ្វីត្បិតតែបណ្តឹងឧទ្ធរណ៍គឺធ្វើឡើងចំពោះសាលក្រម ប៉ុន្តែក៏មានប្រភេទនៃសាលក្រមដែលមិនអាចធ្វើបណ្តឹងឧទ្ធរណ៍បាន នោះគឺសាលក្រមរបៀប ដោយសារតែសាលក្រមនេះពុំមានអានុភាពអ្វីផ្សេង ក្រៅពីអានុភាពដើម្បីត្រៀមចេញសាលក្រមចុងក្រោយក្នុង ការជំនុំជម្រះ ដោយសារវាពុំមានអាជ្ញាអស់ជំនុំ ឬអានុភាពអនុវត្តទេ ។[10]

## ២. មូលហេតុនៃបណ្តឹងឧទ្ធរណ៍

យ៉ាងណាក៏ដោយ ទោះបីជាការកាត់ក្តីតាមប្រព័ន្ធតុលាការសាលាដំបូងបានបញ្ចប់ទៅដោយបានចេញសាលក្រមរួចរាល់ក៏ដោយ ក៏រមែងតែងតែគូរភាគីដែលពុំបានទទួលនូវផលប្រយោជន៍ស្របតាមសេចក្តីត្រូវការស្របទៅតាមបំណងរបស់ខ្លួន ដោយសារតែការចេញសេចក្តីសម្រេចខ្លះនាំឲ្យខូចខាតនូវផលប្រយោជន៍ ឬទទួលបានលទ្ធផលនៃសេចក្តីសម្រេចមិនបានដូចអ្វីដែលខ្លួនបានរំពឹងទុក ហេតុនេះហើយដើម្បីបំពេញនូវរាល់សេចក្តីត្រូវការ ក៏ដូចជាភាពខ្វះខាតដែលកើតមានឡើង និងត្រូវបានគូរភាគីរកឃើញនៅក្នុងសេចក្តីសម្រេចរបស់សាលាដំបូងដែលជាសាលក្រម នោះភាគីអាចធ្វើបណ្តឹងឧទ្ធរណ៍ដោយយោងតាមមូលហេតុដែលមានបញ្ញត្តិនៅក្នុងច្បាប់ ។

ដោយឈរលើមូលដ្ឋានស្របទៅតាមគតិច្បាប់ ចំពោះមូលហេតុដែលបានកំណត់យ៉ាងជាក់ច្បាស់នៅក្នុងច្បាប់មូលហេតុនៃបណ្តឹងឧទ្ធរណ៍ ភាគីអាចប្តឹងបានដោយផ្អែកទៅតាម ៤ ស្ថានភាពរួមមាន៖

➢ សាលក្រមនៃការជំនុំជម្រះលើកទី១ ប្រព្រឹត្តទៅដោយមិនត្រឹមត្រូវ មានកំហុស ឬសេចក្តីសម្រេចចុងក្រោយនៃសាលក្រមដើម អាចមានលក្ខណៈមិនត្រឹមត្រូវដោយផ្អែកលើសំអាងហេតុផ្សេងៗ របស់តុលាការនៃបណ្តឹងឧទ្ធរណ៍ (ភស្តុតាង ច្បាប់សារធាតុ ) ជាក់ស្តែងមានដូចជាអត្ថិភាព ឬ នត្ថិភាពនៃកាតព្វកិច្ច ដោយមានការលើកឡើងអំពីមូលហេតុនៃការរំលាយ ឬលុបចោល ឬមោឃភាពនៃកិច្ចសន្យាជាអាទិ៍ ។[11] ឧទាហរណ៍ ភាគីដើមចោទឈ្មោះ ក បានប្តឹងភាគីចុងចម្លើយឈ្មោះ ខ ទៅសាលាដំបូងខេត្តកំពង់ចាម ដើម្បីឱ្យតុលាការចេញសាលក្រមលេខ ១៥១ "ឈ" ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ ដែលមានខ្លឹមសារថា បង្គាប់ឱ្យចុងចម្លើយឈ្មោះ ខ អនុវត្តនីតិវិធីលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីដែលមានទីតាំងនៅទីរួមខេត្តកំពង់ចាម ដោយមូលហេតុនៃ

[10] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្តឹង គន្ថីទី១ ជំពូកទី៤ ផ្នែកទី១ កថាខណ្ឌទី១ ចំណុច២

[11] មាត្រា២៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

ការរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២០ ។ ដោយតុលាការយល់ឃើញថាមានមូលហេតុរំលាយកិច្ចសន្យា ប៉ុន្តែភាគីចុងចម្លើយឈ្មោះ ខ យល់ថាគ្មានលក្ខណៈសារធាតុគ្មានមូលហេតុនៃការរំលាយកិច្ចសន្យាទេ ដោយសារខ្លួនបានបំពេញកាតព្វកិច្ចតាមការកំណត់ក្នុងកិច្ចសន្យាលក់ទិញចុះថ្ងៃទី០៣ ខែ មីនា ឆ្នាំ ២០២០ រួចរាល់អស់ហើយ។ ហេតុដូច្នេះសាលក្រមរបស់សាលាដំបូងខេត្តកំពង់ចាម ខាងលើនេះភាគីចុងចម្លើយអាចធ្វើការប្តឹងឧទ្ធរណ៍បាន។

➢ នីតិវិធីនៅតុលាការនៃការជំនុំជម្រះលើកទី ១ នោះមានលក្ខណៈផ្ទុយនឹងច្បាប់ធ្ងន់ធ្ងរ ដែលជាស្ថានភាពដែលសាលាដំបូងបានជម្រះក្តីដោយបំពានលើនីតិវិធី ដែលច្បាប់បានកំណត់ដូចជាទាក់ទងទៅនឹង ការពិនិត្យភស្តុតាង ការបញ្ជូន និងការប្រកាសសាលក្រមជាដើម។ ឧទាហរណ៍ ៖ ភាគីដើមចោទ ក បានដាក់ពាក្យបណ្តឹងប្តឹង ខ បង់ប្រាក់ចំនួន ៨០,000 ដុល្លារអាមេរិកដោយយោងទៅលើមូលហេតុនៃកិច្ចសន្យាលក់ទិញរថយន្ត ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ២០២១។ សំណុំរឿងត្រូវចាត់ការដោយចៅក្រម គ ហើយមុនពេលប្រកាសសាលក្រម ចៅក្រម គ បានផ្លាស់ចេញទៅ បម្រើការងារនៅតុលាការផ្សេង។ ចៅក្រម ឃ ត្រូវបានចាត់តាំងឱ្យកាន់សំណុំរឿងនោះបន្ត ហើយបានប្រកាសសាលក្រមដោយផ្អែកលើការទាញហេតុផលផ្ទាល់មាត់របស់ចៅក្រម គ ។ ក្នុងករណីនេះ ចុងចម្លើយឈ្មោះ ខ អាចធ្វើការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះបានដោយផ្អែកមូលហេតុសាលក្រមជំនុំជម្រះលើកទី១ មានកំហុសនីតិវិធីធ្ងន់ធ្ងរ។

➢ ការលើកបណ្តឹងចោលរបស់សាលាដំបូងមានលក្ខណៈមិនត្រឹមត្រូវ និងមានភាពចាំបាច់ក្នុងការទាញហេតុផលថែមទៀត ជាស្ថានភាពដែលសាលាដំបូងបានលើកចោលពាក្យបណ្តឹងរបស់ដើមចោទដោយសាលក្រមមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយមូលហេតុពាក្យបណ្តឹងរបស់ដើមចោទផ្ទុយនឹងច្បាប់មិនអាចកែតម្រូវបាន ។[12] ដូចជាតុលាការយល់ថាខ្វះលក្ខខណ្ឌនៃបណ្តឹង ប៉ុន្តែភាគីយល់ថាតុលាការវិនិច្ឆ័យទៅលើអង្គហេតុពុំទាន់គ្រប់គ្រាន់នោះទេ ភាគីអាចធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះបាន។ ឧទាហរណ៍៖ ដើមចោទ ក បានដាក់ពាក្យបណ្តឹង ប្តឹងចុងចម្លើយ ខ សងប្រាក់ ៤០,000$ ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ដែលកំណត់ពេលសងនៅថ្ងៃទី ១ ខែមីនា ឆ្នាំ ២០២១។ សាលាដំបូងបានលើកចោលពាក្យបណ្តឹង ដោយសាលក្រម ដោយមូលហេតុគ្មានផលប្រយោជន៍នៃបណ្តឹង។ ដូច្នេះ ដើមចោទ ក បានធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុថាសាលក្រមលើកចោលនេះមិនត្រឹមត្រូវ។

➢ ការជំនុំជម្រះលើកទី ១ មានកំហុសចំពោះសមត្ថកិច្ចផ្តាច់មុខ គឺជាស្ថានភាពដែលសាលាដំបូង បានចេញសាលក្រម ចំពោះការទាមទារដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ដោយសារច្បាប់ កំណត់សមត្ថកិច្ចផ្តាច់មុខចំពោះករណីណាមួយ ដូចជាបណ្តឹងលែងលះ បណ្តឹងទាមទារបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃបុត្តភាព

[12] មាត្រា ២៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ជាអាទិ៍ ។[13] ឧទាហរណ៍ ៖ ដើមចោទ ភាគី ក បានដាក់ពាក្យបណ្តឹង ទាមទារឲ្យទទួលស្គាល់កូន ដោយយក ខ ជាភាគីចុងចម្លើយ។ ដើមចោទ ភាគី ក មានលំនៅឋាននៅខេត្ត កំពង់ចាម ចំណែកឯភាគី ខ មានវត្តមានចុងក្រោយនៅប្រទេសកម្ពុជានៅក្នុងខេត្ត កណ្តាល ប៉ុន្តែបានចាកចេញទៅ បរទេសជាង ១២ ឆ្នាំមកហើយ។ សាលាដំបូងខេត្តកណ្តាល បានចាត់ការពាក្យបណ្តឹងនេះហើយ សម្រេច ទទួលស្គាល់ "ក" ជាកូនរបស់ភាគី ខ។ ភាគី ខ បានប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ដោយមូលហេតុថា សាលាដំបូងខេត្តកណ្តាល មិនមានសមត្ថកិច្ចក្នុងចាត់ការបណ្តឹង ព្រោះការជំនុំជម្រះលើបណ្តឹងទាមទារទទួលស្គាល់កូន គឺជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង នៃលំនៅឋានរបស់ភាគី នៃទំនាក់ទំនងឋានៈបុគ្គល។ ក្នុងករណីលំនៅឋាន ឬទីសំណាក់របស់ភាគីនៃទំនាក់ទំនងឋានៈ បុគ្គលមិនអាចកំណត់បានដោយសារករណីជាក់ស្តែងនីមួយៗ ច្បាប់សន្មតថា តុលាការដែលមាន សមត្ថកិច្ចលើរឿងក្តីប្រភេទនេះ គឺសាលាដំបូងរាជធានីភ្នំពេញ។

## ៣. កម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍គឺជាប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង ។ ដូច្នេះហើយកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍គឺដើម្បីទាមទារឲ្យតុលាការជាន់ខ្ពស់ លុបចោល ឬ ផ្លាស់ប្តូរនូវសាលក្រមចុងក្រោយនៃការជំនុះជម្រះលើកទី១ របស់សាលាដំបូងដែលមិនទាន់ចូលជាស្ថាពរ ប៉ុន្តែលើកលែងក្នុងករណីមួយចំនួន [14]

ចំពោះសេចក្តីសម្រេចដែលមិនអាចប្តឹងឧទ្ធរណ៍បាន ពោលគឺមិនមែនជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍រួមមានដូចជា៖

- ករណីគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខក្រោយពេលតុលាការបានចេញសាលក្រមចុងក្រោយដែលមិនទាន់ចូលជាស្ថាពររបស់សាលាដំបូង។ ការព្រមព្រៀងបែបនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ គ្រាន់តែព្រមព្រៀងផ្ទាល់មាត់មិនប្តឹងឧទ្ធរណ៍នោះ ក៏មិនអាចប្តឹងសាទុក្ខបានដែរ ដោយសារភាគីគិតថាចង់លះបង់ការវិនិច្ឆ័យទៅលើអង្គសេចក្តីលើកទី២ ដែលតុលាការនៃបណ្តឹងឧទ្ធរណ៍ជា តុលាការវិនិច្ឆ័យទៅលើអង្គសេចក្តីនោះផងដែរ ។[15] ឧទាហរណ៍៖ ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងគ្នាប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូល ដោយធ្វើជាលាយលក្ខណ៍អក្សរ ក្នុងគោលបំណងលះបង់នូវការវិនិច្ឆ័យទៅលើ ការជំនុំជម្រះលើកទី២ ដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ តែទាមទារការវិនិច្ឆ័យលើអង្គច្បាប់ដោយតុលាការ នៃបណ្តឹងសាទុក្ខ។

[13] មាត្រា២៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[14] មាត្រា ២៦០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[15] មាត្រា២៦០ កថាខណ្ឌទី១ ចំណុច១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

➢ ករណីសាលក្រមចុងក្រោយដែលវិនិច្ឆ័យទៅលើរឿងក្ដីរដ្ឋប្បវេណី ឬ ពាណិជ្ជកម្ម ដែលមានតម្លៃនៃកម្មវត្ថុនៃបណ្ដឹងមិនលើសពី ៥,០០០,០០០ (ប្រាំលាន) រៀល។ ឧទាហរណ៍៖ ភាគី "ក" បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០០ ដុល្លារ ដែលជារឿងក្ដីចេញសាលក្រមចុងក្រោយមកមានតម្លៃនៃកម្មវត្ថុតិចជាង ៥លានរៀល ដូច្នេះសាលក្រមនេះភាគីមិនអាចប្ដឹងឧទ្ធរណ៍បានទេ។

➢ ចំពោះសាលក្រមរបៀបក៏មិនមែនជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ដែរ ព្រោះសាលក្រមរបៀបមិនមែនជាសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ទេ។ ដូចការលើកឡើងខាងលើសាលក្រមរបៀបពុំមានអានុភាពអ្វីផ្សេង ក្រៅពីអានុភាពដើម្បីត្រៀមចេញសាលក្រមចុងក្រោយក្នុងការជំនុំជម្រះ ហើយពុំមានអាជ្ញាអស់ជំនុំ ឬអានុភាពអនុវត្តទេ។[16]

➢ សេចក្ដីសម្រេចរបស់សាលាដំបូងដែលមិនអាចធ្វើការឧបាស្រ័យតែម្ដង គឺមិនមែនជាកម្មវត្ថុនៃ បណ្ដឹងឧទ្ធរណ៍ទេ ដូចជាដីកាសម្រេចអំពីការតវ៉ាចំពោះការដឹកនាំនីតិវិធី ឬដីកាសម្រេចបង្គង់នីតិវិធីនៃបណ្ដឹងជាអាទិ៍។

➢ សេចក្ដីសម្រេចដែលអាចធ្វើឧបាស្រ័យដោយបណ្ដឹងជំទាស់ គឺមិនអាចប្ដឹងឧទ្ធរណ៍បានទេ ពោលមិនមែនជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍ឬដីកាសម្រេចរបស់សាលាដំបូងមិនអាចធ្វើបណ្ដឹងឧទ្ធរណ៍បានទេ។ ឧទាហរណ៍៖ ដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ឬដីកាសម្រេចលើកចោលពាក្យសុំឱ្យថែរក្សាការពារភស្ដុតាង ជាអាទិ៍។

➢ ចំពោះសេចក្ដីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្ដី ដែលជាប់ជាមួយនឹងសាលក្រមចុងក្រោយ មិនអាចប្ដឹងឧទ្ធរណ៍ដោយឯករាជ្យបានឡើយ ។[17]

➢ ម្យ៉ាងទៀតក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី១ ចេញសាលក្រមកំបាំងមុខ បើភាគីបន្តការវិនិច្ឆ័យនៅតុលាការនៃការជំនុំជម្រះលើកទី១ ហើយភាគីមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីប្ដឹងទាស់ដែល បានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា២០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនអាចធ្វើបណ្ដឹងឧទ្ធរណ៍បានទេ។ ប៉ុន្តែបើភាគីនោះលះបង់នូវផលប្រយោជន៍ដែលបន្តការវិនិច្ឆ័យនៅតុលាការនៃការជំនុំជម្រះលើកទី១ គឺអាចប្ដឹង ឧទ្ធរណ៍បាន ចំណែកភាគីដែលខ្វះលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីប្ដឹងទាស់ ក៏អាចប្ដឹងឧទ្ធរណ៍បានដែរ។ ចំពោះការ ប្ដឹងទាស់លើសាលក្រមកំបាំងមុខបានចេញសាលក្រមចុងក្រោយរួចហើយក៏អាចប្ដឹងឧទ្ធរណ៍បានដែរ។

យ៉ាងណាមិញបណ្ដឹងឧបាស្រ័យចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ ដែលបានចេញក្នុងនាមជាការសម្រេចសេចក្ដីនៃការជំនុំជម្រះលើកទី១ អាចប្ដឹងបានត្រឹមតែសាទុក្ខប៉ុណ្ណោះ។[18] លើសពីនេះ ទៅទៀត ក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី១ ចេញសាលក្រមកំបាំងមុខ ទោះបីជាលក្ខខណ្ឌ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ២០៤ ត្រូវបានបំពេញក៏ដោយក៏ភាគីអាចលះបង់ផល ប្រយោជន៍ ក្នុង

[16] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីបណ្ដឹង

[17] មាត្រា២៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[18] មាត្រា ២៥៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ការបន្តអោយវិនិច្ឆ័យនៅថ្នាក់ដដែលដោយដាក់បណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះ ហើយអាចប្ដឹងឧទ្ធរណ៍បានដែរ។ ប្រសិនបើលក្ខខណ្ឌដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ២០៤ នោះ មិនត្រូវបានបំពេញភាគីមិនអាចប្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខបានឡើយ ហេតុដូច្នេះបណ្ដឹង ឧទ្ធរណ៍ គឺជាវិធីតែមួយនៃបណ្ដឹងឧបាស្រ័យចំពោះសាលក្រមកំបាំងមុខនោះ។

## ផ្នែកទី២៖ លក្ខខណ្ឌ និងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍

### ១. លក្ខខណ្ឌនៃបណ្ដឹងឧទ្ធរណ៍

ក្រោយពីបានបកស្រាយនិងពន្យល់អំពីកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍រួចមក ក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ចាំបាច់ ត្រូវអនុលោមទៅតាមល័ក្ខខ័ណ្ឌជាក់លាក់ចំនួនពីរ ហើយគឺត្រូវដឹងផងដែរថា អ្នកណាដែលអាចមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍នេះបាន ប្រសិនបើភាគីដឹងថាខ្លួនមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ហើយ ត្រូវសិក្សាពីអំឡុងពេលក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ ដើម្បីឱ្យការប្ដឹងឧទ្ធរណ៍នោះប្រព្រឹត្តទៅបានត្រឹមត្រូវ និងមានប្រសិទ្ធិភាពតាមដំណើរការនៃនីតិវិធីច្បាប់។

#### ១.១. អ្នកមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍

ជាធម្មតាអ្នកដែលមានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ គឺជាភាគីដែលកើតទុក្ខមិនសុខចិត្តទៅនឹងសាលក្រមចុងក្រោយដែល មិនទាន់ចូលជាស្ថាពររបស់សាលាដំបូង។ នេះបានសេចក្ដីថាបណ្ដឹងឧទ្ធរណ៍អាចធ្វើឡើងបានដោយភាគីដើមចោទ ឬ ភាគីចុងចម្លើយ ដែលមិនពេញចិត្ត និងបាត់បង់ឬខូចខាតនូវផលប្រយោជន៍ដោយសារសាលក្រមនៃការជំនុំជម្រះលើកទី១របស់សាលាដំបូង ។ ប៉ុន្តែជាងនេះទៅទៀត ដរាបណាទាល់តែយកខ្លឹមសារនៃបណ្ដឹងឧទ្ធរណ៍ របស់ដើមចោទ ឬចុងចម្លើយនៃការជំនុំជម្រះលើកទី ១ មកប្រៀបធៀបនឹងសាលក្រមនៃការជំនុំ ជម្រះលើកទី ១ ហើយក្នុងករណីដែលសាលក្រមនោះមានផលប្រយោជន៍តូចជាងការទាមទារ របស់ភាគីទើបផលប្រយោជន៍ក្នុងការប្ដឹងឧបាស្រ័យត្រូវទទួលស្គាល់ ។ ជាទូទៅអ្នកដែលឈ្នះក្ដី ទាំងស្រុងនៅក្នុងការជំនុំជម្រះលើកទី ១ គឺគ្មានផលប្រយោជន៍ក្នុងការប្ដឹងឧបាស្រ័យទេ ដូច្នេះហើយ ភាគីដែលឈ្នះក្ដីនោះគឺគ្មានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ទេ ។ ប្រសិនបើភាគីនោះប្ដឹងឧទ្ធរណ៍ បណ្ដឹង ឧទ្ធរណ៍នោះនឹងត្រូវបានលើកចោល ដោយសារបណ្ដឹងឧទ្ធរណ៍នោះផ្ទុយនឹងច្បាប់។

សិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍អាចកើតឡើងបានចំពោះភាគីដែលបាត់បង់ផលប្រយោជន៍ ពីការជំនុំជម្រះលើកទី ១ តែសិទ្ធិនេះក៏អាចបោះបង់ចោលដែរ ដោយមានការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថាមិនប្ដឹងឧទ្ធរណ៍ នោះសាលក្រមនៃការជំនុំជម្រះលើកទី ១ នឹងចូលជាស្ថាពរ ។ ការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថាមិនប្ដឹងឧទ្ធរណ៍ គឺខុសពីការព្រមព្រៀងគ្នាថាឆ្ពោះទៅ ប្ដឹងសាទុក្ខ ពីព្រោះការព្រមព្រៀងបែបនេះគឺសាលក្រមនៃការជម្រះលើកទី១ មិនទាន់ចូលជាស្ថាពរទេទោះហួសរយៈពេលប្ដឹងក៏ដោយ ។ ការលះបង់សិទ្ធិប្ដឹង

ឧទ្ធរណ៍ត្រូវធ្វើឡើងតាមសេចក្តីថ្លែងការណ៍ ។ តែបើភាគីលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ក្រោយពេលដាក់ពាក្យបណ្តឹងឧទ្ធរណ៍ សេចក្តីថ្លែងការណ៍ស្តីពីការបោះបង់សិទ្ធិប្តឹងឧទ្ធរណ៍ និងការដកពាក្យបណ្តឹងត្រូវធ្វើជាមួយគ្នា។ [19]

### ១.២. អំឡុងពេលក្នុងការធ្វើបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍អាចធ្វើឡើងក្នុងរយៈពេល ១ ខែ ដោយគិតចាប់ពីថ្ងៃដែលបានទទួលនូវការ បញ្ជូនលិខិតសាលក្រម (លិខិតដែលបញ្ជាក់រាល់ចំណុចដែលបានសម្រេចសេចក្តីក្នុងសាលក្រម) នៃការជំនុំជម្រះលើកទី ១ ។ [20] **ឧទាហរណ៍៖** នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ភាគីបានទទួល លិខិតសាលក្រម ច្បាប់ទុករយៈពេលភាគីណាមួយដែលបាត់បង់ផលប្រយោជន៍ ឬមិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់តុលាការជាន់ទាប ក្នុងរយៈពេល ១ ខែ ដូច្នេះផុតអំឡុងពេលប្តឹងឧទ្ធរណ៍នៅ ថ្ងៃទី១ ខែឧសភា ឆ្នាំ ២០២១។

ក៏ប៉ុន្តែ ទោះបីជាមានករណីខាងលើក៏ដោយក៏ភាគីដែលមានសិទ្ធិប្តឹងឧទ្ធរណ៍នៅតែអាចធ្វើបណ្តឹងឧទ្ធរណ៍បាន ដោយគ្រាន់តែដាក់ពាក្យបណ្តឹងឧទ្ធរណ៍ដូចធម្មតាក្នុងរយៈពេលមួយសប្តាហ៍គិតពីថ្ងៃដែលមូលហេតុដែលធ្វើឱ្យខកខាននោះបានរលត់ ហើយមូលហេតុនោះពុំមែនជាកំហុសរបស់ភាគីនោះទេ ។ ជាងនេះទៅទៀត ភាគីនោះក៏ត្រូវតែបញ្ជាក់ និងអះអាងអំពីមូលហេតុ និងភស្តុតាងដែលធ្វើឱ្យមានការយឺតយ៉ាវក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ឱ្យបានច្បាស់លាស់ ។

ចំពោះករណីតុលាការលើកចោល ឬច្រានចោលបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ការប្តឹងឧទ្ធរណ៍អាចធ្វើទៅបានដែលភាគីមានប្រយោជន៍ក្នុងការប្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ ខែ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់នោះ។ ឧទាហរណ៍ ៖ នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២១ ជាថ្ងៃដែលភាគីបាន ទទួលសាលក្រមកំបាំងមុខ ច្បាប់ទុកអំឡុងពេល សម្រាប់ប្តឹងទាស់ចំនួន ១៤ ថ្ងៃ ឬ២ សប្តាហ៍។ នៅថ្ងៃទី ២៣ ខែ មេសាឆ្នាំ ២០២១ ភាគីក៏បានដាក់ពាក្យ បណ្តឹងទាស់ក្រោយមកនៅថ្ងៃទី ០១ ខែ ឧសភាឆ្នាំ ២០២១ ភាគីក៏បានទទួលដំណឹងអំពីការសម្រេចច្រាន ចោលនូវបណ្តឹងទាស់នោះ ដូចនេះ គិតចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០២១ រហូតដល់ថ្ងៃទី ០១ ខែ មិថុនាឆ្នាំ ២០២១ មានរយៈពេល ១ ខែ គឺជាអំឡុងពេលប្តឹងឧទ្ធរណ៍ ចំពោះចាប់ពីថ្ងៃទី ០២ ខែ មិងុនា ឆ្នាំ ២០២១ ត ទៅជាថ្ងៃដែលផុតអំឡុងពេលប្តឹងឧទ្ធរណ៍។

ជាទូទៅអំឡុងពេលប្តឹងឧទ្ធរណ៍មិនអាចពន្យាបានឡើយ ប៉ុន្តែក្នុងករណីដែលភាគីដែលមានសិទ្ធិ ប្តឹងឧទ្ធរណ៍ មិនអាចប្តឹងឧទ្ធរណ៍បានក្នុងអំឡុងពេលនេះ ដោយមូលហេតុដែលមិនមែនជាកំហុសរបស់ខ្លួនទេ ភាគី

[19] មាត្រា២៦៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[20] មាត្រា ២៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

នោះអាចបំពេញនូវសកម្មភាពបណ្ដឹងពេលក្រោយបាន អំឡុងពេល ១ សប្ដាហ៍ ឬ២ ខែ ចំពោះភាគីដែល នៅបរទេសក្រោយពីមូលហេតុនោះបានរលត់ហើយ ។[21]

ក្នុងករណីនេះដើម្បីអាចធ្វើបណ្ដឹងឧទ្ធរណ៍បានភាគីគ្រាន់តែដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ជាធម្មតាក្នុងអំឡុង ពេលមួយ សប្ដាហ៍គិតពីថ្ងៃដែលហេតុ នាំឱ្យខកខាននោះបានរលត់ និងភាគីត្រូវធ្វើការអះអាង និងបញ្ជាក់ ដោយ ភស្តុតាងថា ការមិនអាចធ្វើបណ្ដឹងឧទ្ធរណ៍ ក្នុងអំឡុងពេលកំណត់នោះបាន មិនមែនដោយសារកំហុសរបស់ខ្លួនទេជាការគ្រប់គ្រាន់។ ប្រសិនបើអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍កន្លងហួស ភាគីដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍ បាត់បង់សិទ្ធិនេះ បើពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ ក្រោយអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍កន្លងហួសបណ្ដឹងឧទ្ធរណ៍នោះ នឹងត្រូវបានលើកចោលដោយសាលដីកា ដោយសារបណ្ដឹងឧទ្ធរណ៍នោះមានលក្ខណៈផ្ទុយនឹងច្បាប់។[22] ម្យ៉ាងទៀត ក្រោយពេលសាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រូវបានប្រកាសទោះបីជាមិនទាន់ទទួលការបញ្ជូនសាលក្រមក៏ដោយ ក៏ភាគីអាចប្ដឹងឧទ្ធរណ៍ដោយស្របច្បាប់បានដែរ។ [23] យ៉ាងណាមិញ ក្រោយពេលសាលក្រមនៃការជំនុំជម្រះលើកទី១ ត្រូវបានប្រកាស ទោះបីជាភាគីមិនទាន់ទទួលបានការបញ្ជូនសាលក្រម ក៏ដោយ ក៏ភាគីអាចប្ដឹងឧទ្ធរណ៍ដោយស្របច្បាប់បានដែរ ។ បានសេចក្ដីថាទោះបីជាសិទ្ធិប្ដឹងឧទ្ធរណ៍ត្រូវបាន រលត់ហើយក៏ដោយ ភាគីក៏នៅតែអាចប្ដឹងឧទ្ធរណ៍បានដែរ បណ្ដឹងនេះហៅថា បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ដែលជាបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំធ្វើឡើងដោយឯករាជ្យ។

## ២. នីតិវិធីនៃបណ្ដឹងឧទ្ធរណ៍

ក្រោយពីបានបកស្រាយទាក់ទងនឹងលក្ខខណ្ឌនៃបណ្ដឹងឧទ្ធរណ៍រួចមក ក្នុងចំណុចនេះនឹងបកស្រាយលម្អិតបន្ថែមទាក់ទងនឹងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ ដើម្បីប្ដឹងឧទ្ធរណ៍បាន ភាគីត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការដើមជាមុនសិន ពោលគឺតុលាការនៃការជំនុះជម្រះលើកទី១ ដែលជាសាលាដំបូង ។ ចំពោះពាក្យបណ្ដឹងឧទ្ធរណ៍ ត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ ដោយត្រូវបញ្ជាក់អំពី ១.អត្តសញ្ញាណរបស់ភាគី ២.សេចក្ដីដែលប្ដឹងចំពោះសាលក្រមនោះ ៣.សញ្ញាណនៃសាលក្រមជំនុំជម្រះលើកទី១ និង ៤.មូលហេតុនៃការទាមទារឲ្យលុបចោល ឬផ្លាស់ប្ដូរនូវសាលក្រម។ ឧទាហរណ៍ សាលាដំបូងបានចេញសាលក្រមឲ្យ ភាគី"ខ"ឈ្នះ "ក"មិនពេញចិត្តនឹងសាលក្រមរបស់ សាលាដំបូងក៏អាចធ្វើប្ដឹងឧទ្ធរណ៍បាន។ ជាទូទៅបណ្ដឹងតែងតែមានការទាមទារដែលកម្មវត្ថុនៃបណ្ដឹង ហេតុ នេះបណ្ដឹងឧទ្ធរណ៍ភាគីនៃបណ្ដឹងត្រូវសរសេរជាចាំបាច់ នូវមូលហេតុដែលទាមទារឲ្យលុបចោល ឬ ផ្លាស់ប្ដូរនូវ សាលក្រមនោះ ។[24]

[21] មាត្រា ២៤៥ នៃក្រមនីតិវិធីប្បវេណី ឆ្នាំ ២០០៦

[22] មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[23] មាត្រា ២៦៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[24] មាត្រា២៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

## ២.១. ការដាក់ពាក្យបណ្ដឹងឧទ្ធរណ៍

ចំពោះបណ្ដឹងឧទ្ធរណ៍ អាចធ្វើឡើងបានដោយភាគីដើមចោទ ឬភាគីចុងចម្លើយដែលបានបាត់បង់ផលប្រយោជន៍ ដោយសារសាលក្រមរបស់សាលាដំបូង ពោលគឺភាគីចាញ់ក្ដីមួយផ្នែក ឬទាំងស្រុងភាគីដែលមានផលប្រយោជន៍ក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ ហើយអាចធ្វើបានតែមួយផ្នែក ឬទាំងស្រុងបាន។

**ឧទាហរណ៍៖** សាលាដំបូងបានបង្គាប់ឲ្យ ភាគី "ក" បង់ប្រាក់ចំនួន ១០,០០០ដុល្លារ មកឲ្យភាគី "ខ" ត្រង់ចំណុចនេះ ភាគី "ខ" អាចប្ដឹងឧទ្ធរណ៍បាន។ ហើយសម្រាប់រយៈពេលនេះបណ្ដឹងឧទ្ធរណ៍មានរយៈពេល ១ ខែ គិតចាប់ពីភាគីបានទទួលសាលក្រមនោះ។ ចំពោះរយៈពេលនៃការដាក់ពាក្យបណ្ដឹងមានរយៈពេល ១ ខែ គិតចាប់ពីថ្ងៃភាគីទទួលបានការបញ្ជូន លិខិតសាលក្រមនោះឬថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្ដឹងទាស់ ចំពោះសាលក្រមកំបាំងមុខ។

## ២.២. ការទទួលពាក្យបណ្ដឹងឧទ្ធរណ៍

ភាគីដែលខាតបង់ផលប្រយោជន៍ អំពីសេចក្ដីសម្រេចរបស់សាលាដំបូងនៃការជំនុំជម្រះលើកទី១ អាចដាក់ពាក្យបណ្ដឹងនៅតុលាការដើម គឺសាលាដំបូង ហើយតុលាការនៃសាលាដំបូងនេះ (តុលាការដើម) ត្រូវបញ្ជូនសំណុំរឿងទាំងអស់នោះទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍នោះ។ បន្ទាប់មកតុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវតែទទួលបន្ទុកលើរឿងក្ដីនេះ។

សាលាដំបូងដែលជាតុលាការនៃការជំនុំជម្រះលើកទី១ មានភារកិច្ចទទួលយកពាក្យបណ្ដឹងឧទ្ធរណ៍របស់ភាគីដែលបានដាក់ពាក្យបណ្ដឹង ហើយត្រូវបញ្ជូនសំណុំរឿងទៅ សាលាឧទ្ធរណ៍ដែលជាតុលារការនៃការជំនុំជម្រះលើកទី២ ។ ដូចនេះតុលាការនៃការជំនុំជម្រះលើកទី១ ពុំមានសមត្ថកិច្ចពិនិត្យលើបណ្ដឹងដូចជា ការបង់ពន្ធ មូលហេតុប្ដឹងឧទ្ធរណ៍ អំឡុងពេលនៃការធ្វើបណ្ដឹងឧទ្ធរណ៍ឡើយ ទាំងនេះគឺជាសមត្ថកិច្ចរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

## ២.៣. ការពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍

នៅពេលដែលតុលាការឧទ្ធរណ៍ទទួលបានពាក្យបណ្ដឹងឧទ្ធរណ៍ តុលាការនឹងពិនិត្យលើពាក្យបណ្ដឹង[25] នូវចំណុចដូចជា ៖

- នាម នាមករណ៍ អាសយដ្ឋានភាគី ព្រមទាំង នាម នាមករណ៍ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ សញ្ញាណនៃសាលក្រម, និងសេចក្ដីដែលប្ដឹងឧទ្ធរណ៍នោះ។
- សញ្ញាណសាលក្រមនៃការជំនុំជ្រះលើកទី១
- សេចក្ដីដែលប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនោះនិងមូលហេតុនៃការទាមទារ

[25] មាត្រា២៦៦, កថាខណ្ឌទី១នៃ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

- ការបង់ប្រាក់ប្រដាប់ក្តី ក្នុងករណីដែលភាគីមិនបានបង់ពន្ធ ឬខ្វះខាតចំណុចណាមួយ នោះតុលាការ នឹងបង្គាប់ឲ្យកែតម្រូវ ដោយកំណត់ពេលមួយសមរម្យ ប្រសិនបើក្នុងករណីដែលភាគីមិនដាក់ ឬមិនព្រមកែតម្រូវនោះទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវចេញដីកាសម្រេចលើចោលពាក្យបណ្តឹងឧទ្ធរណ៍ ។[26]

## ២.៤. ការបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍

នៅពេលក្រោយដែលតុលាការនៃបណ្តឹងឧទ្ធរណ៍បានពិនិត្យពាក្យបណ្តឹងរួចហើយ តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅឲ្យចុងបណ្តឹងឧទ្ធរណ៍ ដើម្បីឲ្យភាគីចុងចម្លើយបានដឹង និងបានត្រៀមខ្លួនដើម្បីតទល់ ឆ្លើយតបជាមួយម្ចាស់បណ្តឹងឧទ្ធរណ៍។

## ២.៥. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

ក្រោយពេលដែលបានតុលាការនៃបណ្តឹងឧទ្ធរណ៍ទទួល និងពិនិត្យពាក្យបណ្តឹងរួចរាល់ហើយ ឃើញថាបណ្តឹងនោះធ្វើឡើងដោយគោរពតាមទម្រង់ច្បាប់ហើយ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើការកំណត់នូវកាលបរិច្ឆេទសម្រាប់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់ ឲ្យបានឆាប់រហ័ស និងធ្វើការកោះហៅគូភាគីដើម្បីចូលរួមផងដែរ។[27]

ជាគោលការណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ លើកលែងតែការកំណត់ចំណុចវិវាទរបស់តុលាការជាន់ទាបមានលក្ខណៈមិនត្រឹមត្រូវហើយមានភាពចាំបាច់ពិសេសត្រូវកំណត់ចំណុចវិវាទជាថ្មី។ **ឧទាហរណ៍៖** នៅក្នុងការជំនុំជម្រះលើកទី១ ដើមចោទអះអាងអំពីសិទ្ធិលើបំណុលចំនួន ១០,០០០ ដុល្លារ ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុងចម្លើយបានអះអាងអំពីការរលត់សិទ្ធិលើបំណុលដោយអាជ្ញាយុកាល ហើយតុលាការបានកំណត់ចំណុចវិវាទថា (តើមានអត្ថិភាពនៃសិទ្ធិលើ បំណុលដែរ ឬទេ?) ការកំណត់ចំណុចវិវាទនេះមិនត្រឹមត្រូវទេ ចំណុចវិវាទដែលត្រឹមត្រូវ គឺ (តើសិទ្ធិលើបំណុលនេះត្រូវរលត់ដោយអាជ្ញាយុកាលដែរឬទេ) នាំតុលាការជាន់ទាបបានកំណត់វិវាទដែលមិនត្រឹមត្រូវថា (តើមានអត្ថិភាពនៃសិទ្ធិលើបំណុល ដែរឬទេ) និងបានចេញសេចក្តីសម្រេចបញ្ចប់ បង្គាប់ចុងចម្លើយ បង់ប្រាក់ ១០០០០ ដុល្លារមកដើមចោទ។ លុះពេលដែលបានមកដល់តុលាការនៃបណ្តឹងឧទ្ធរណ៍ឃើញថា មានចំណុចវិវាទមិនត្រឹមត្រូវរលត់ដោយអាជ្ញាយុកាល ដែរ ឬទេ? )។ ដូច្នេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះលើកទី ២ ដោយត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្នុងករណីត្រូវកំណត់វិវាទជាថ្មី។ [28] នៅក្រោយពេលដែលបានកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចរាល់ តុលាការត្រូវធ្វើការបញ្ជូនដីកាកោះទៅភាគីដើម្បីឲ្យភាគីចូលរួមក្នុងនីតិវិធី ព្រោះថាតុលាការចាំបាច់ត្រូវតែគោរពគោលការណ៍ចំពោះមុខ។ ការបញ្ជូនដីកា

[26] មាត្រា២៦៦ កថាខណ្ឌទី២នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
[27] មាត្រា ១១៣ និង ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[28] មាត្រា ១០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

កោះអាចធ្វើការបញ្ជូនទៅភាគីជាមួយគ្នា និងលិខិតទទួលពាក្យបណ្តឹង [29] លើកលែងតែករណីដែលតុលាការលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះ ឬតុលាការចេញដីកាបង្គាប់ឱ្យកែតម្រូវជាអាទិ៍ ។

## ផ្នែកទី៣៖ អានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍អាចមានអានុភាពនៅពេលដែលភាគីបានដាក់ពាក្យបណ្តឹងបានទាន់ពេលវេលាតាមការកំណត់ក្នុងច្បាប់ ដោយអាចមានអានុភាពទៅលើសាលក្រមនៃការជំនុំជម្រះលើកទី១ ដែលអាចបង្អាកការចូលជាស្ថាពរនៃសាលក្រមរបស់សាលាដំបូងបាន។ ចំពោះដំណើរការនៃការជម្រះក្តីនៅតុលាករដើមក៏ត្រូវបានផ្ទេរមកឲ្យតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវបានគេឲ្យឈ្មោះថាអានុភាពនៃការផ្ទេរការជម្រះក្តីដោយបណ្តឹងឧទ្ធរណ៍ដែលតុលាការនៃបណ្តឹងឧទ្ធរណ៍មានសិទ្ធិពេញលេញ ក្នុងការវិនិច្ឆ័យនៃការទាមទាររបស់អ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ ជួនកាល ភាគីនៃបណ្តឹងឧទ្ធរណ៍មិនសុខចិត្តលើសាលក្រមតែផ្នែកណាមួយនៃសាលក្រមប៉ុណ្ណោះ ប៉ុន្តែអានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រមគឺផ្អាកទៅលើចំណុចទាំងមូលនៃសាលក្រមតែម្តង ដែលធ្វើឲ្យមិនមានអានុភាពក្នុងការអនុវត្តសាលក្រមឡើយ នេះហៅថា អវិភាគនៃបណ្តឹងឧទ្ធរណ៍។

### ១. ការផ្អាកការចូលជាស្ថាពរនៃសាលក្រម

នៅពេលដែលការដាក់ពាក្យបណ្តឹងឧទ្ធរណ៍បានបានទាន់ពេលវេលា និងបានធ្វើក្នុងអំឡុងពេលដែលបានកំណត់ទោះបីជាអំឡុងពេលដែលបានកំណត់ឱ្យធ្វើបណ្តឹងឧទ្ធរណ៍នោះបានផុតរយៈពេលហើយក៏ដោយ ក៏សាលក្រមដើម (សាលក្រមនៃការជំនុំជម្រះលើកទី ១) មិនចូលជាស្ថាពរដែរ។ នេះគេហៅថា "អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃបណ្តឹងឧទ្ធរណ៍" ។[30] នេះមានន័យថា អានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រម ជាស្ថានភាពមួយដែលរារាំងការចូលជាស្ថាពរនៃសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ នៅសាលាដំបូង ដោយសារតែអានុភាពនៃការដាក់ពាក្យបណ្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។ ពេលដែលបណ្តឹង ឧទ្ធរណ៍ត្រូវបានធ្វើក្នុងអំឡុងពេលដែលកំណត់អោយធ្វើបណ្តឹងឧទ្ធរណ៍ ទោះជាអំឡុងពេលដែលកំណត់ធ្វើបណ្តឹងឧទ្ធរណ៍នោះបានកន្លងផុតទៅហើយក៏ដោយ ក៏សាលក្រមដើម ឬសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនចូលជាស្ថាពរដែរ។ មិនតែប៉ុណ្ណោះអានុភាពអនុវត្តសាលក្រមក៏មិនអាចកើតមានដែរ ប្រសិនបើសាលក្រមដើមនោះ ពុំមានភ្ជាប់ជាមួយការអនុវត្តជាបណ្តោះអាសន្ន ឬអាជ្ញាអស់ជំនុំពុំទាន់កើតឡើង។ [31] ការអនុវត្តជាបណ្តោះអាសន្ននេះ សំដៅដល់មធ្យោបាយមួយ ដែលតុលាការបានអនុញ្ញាតឲ្យដើមចោទ ដែលឈ្នះក្តីអាចទទួលបានឆាប់នូវផលប្រយោជន៍លើទ្រព្យសម្បត្តិ ដែលសន្មតថាជាកម្មសិទ្ធិរបស់ខ្លួន ទោះបីជាសាលក្រម ឬសាលដីកាពុំទាន់ចូលជាស្ថាពរក៏ដោយ។

[29] មាត្រា ២៦៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[30] មាត្រា ១៩៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[31] មាត្រា ១៩៥ និងមាត្រា ១៩៦ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### ២. ការផ្ទេរការជម្រះក្តី

នៅពេលដែលមានបណ្តឹងឧទ្ធរណ៍កើតឡើង ការចាត់ការនៃការទាមទារដែលបានជំនុំជម្រះក្នុងសាលក្រមដើមត្រូវផ្ទេរពីសាលាជំនុំជម្រះលើកទី ១ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍។ នេះគេហៅថា **"អានុភាពនៃការផ្ទេរការជម្រះក្តីដោយបណ្តឹងឧទ្ធរណ៍"** ដោយសារអានុភាពនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យអំពីការទាមទារនោះ។ បណ្តឹងឧទ្ធរណ៍ដែលបានធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់មានអានុភាពផ្ទេរការទាមទារពីសាលាដំបូងទៅសាលាឧទ្ធរណ៍ គឺមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដើមទៀតទេ ពោលគឺស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍។[32]

### ៣. អវិភាគភាពនៃបណ្តឹងឧទ្ធរណ៍

ចំពោះអានុភាពបង្អាក់ការចូលជាស្ថាពរនៃសាលក្រម និង អានុភាពនៃការផ្ទេរការជម្រះក្តី ខាងលើនេះអាចមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃកាជម្រះក្តីលើកទី ១ គឺក្នុងករណីដែលភាគីដែលបានប្តឹងមិនសុខចិត្តលើផ្នែកណាមួយនៃសាលក្រម ក៏ប៉ុន្តែការធ្វើបណ្តឹងឧទ្ធរណ៍ នឹងធ្វើឱ្យចំណុចទាំងអស់ ព្រមទាំងធ្វើឱ្យចំណុច ដែលបានឯកភាពនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនមានអានុភាពអនុវត្តឡើយ (អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម)។ ទោះបីជាដើមបណ្តឹងឧទ្ធរណ៍ប្តឹងឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រមដើមក៏ដោយក៏ **"អានុភាពនៃការបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម"** និង **"អានុភាពនៃការផ្ទេរការជម្រះក្តី"** កើតមានឡើងចំពោះការទាមទារទាំងអស់ដែលបានសម្រេចនៅក្នុងសាលក្រមដើមដែរ គេហៅថា "ភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍" ។ ហេតុនេះហើយ នៅពេលដែលមានបណ្តឹងឧទ្ធរណ៍ដោយហេតុថាសាលក្រមដើមត្រូវបានរារាំង នូវអានុភាពចូលជាស្ថាពរ ហើយសូម្បីតែផ្នែកដែលដើមបណ្តឹងឧទ្ធរណ៍បានឈ្នះក្តី ក៏ត្រូវបានបង្អាក់ចូលជាស្ថាពរដែរនោះ ដើមបណ្តឹងឧទ្ធរណ៍ មិនអាចនឹងធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមដើមបានទេប្រសិនបើមានការប្រកាសឱ្យធ្វើការអនុវត្តជាបណ្តោះអាសន្នទៅលើផ្នែកដែលខ្លួនឈ្នះនៅក្នុងសាលក្រមនោះ។

ឧទាហរណ៍៖ សាលក្រមលេខ ១០១ ក១ -ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារ ៖

១. បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន ២០០,០០$ មកដើមចោទ។

២. បង្គាប់ឱ្យចុងចម្លើយសងការប្រាក់ចំនួន ១៥% ក្នុងមួយឆ្នាំ។

៣. បង្គាប់ឱ្យចុងចម្លើយសងការប្រាក់ពិន័យស្មើចំនួន ២ដង នៃអត្រាការប្រាក់ក្នុងកិច្ចសន្យា។

[32] មាត្រា ២៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

៤. បង្គាប់ឱ្យចុងចម្លើយសងការខូចខាត ពេលវេលា និងជំងឺចិត្តចំនួន ១០០០$។

ក្រោយមកចុងចម្លើយប្ដឹងឧទ្ធរណ៍ចំនុច ទី២ ទី៣ និងទី៤។ ហេតុនេះក្នុងករណីចុងចម្លើយធ្វើបណ្ដឹងឧទ្ធរណ៍តែចំណុចទី២ ទី៣ និងទី៤ នាំឱ្យសាលក្រមទាំងមូលមិនចូលជាស្ថាពរនោះទេ ដូច្នេះហើយទោះបីជាចំណុចទី១ ដែលចុងចម្លើយមិនប្ដឹងឧទ្ធរណ៍ក៏ដោយ ក៏ចំណុចទី១ នេះមិនចូលជាស្ថាពរដែរ។ សរុបជារួមមកប្រសិនបើដើមបណ្ដឹងឧទ្ធរណ៍ ប្ដឹងឧបាស្រ័យចំពោះតែផ្នែកណាមួយនៃសាលក្រមដើមក៏ដោយក៏នៅតែមានអានុភាពនៃការបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម និងមានអានុភាពនៃការផ្ទេរការជម្រះក្ដីកើតមានឡើងដែរ ចំពោះការទាមទារទាំងអស់នៅក្នុងសាលក្រមដើម ដែលគេហៅថា អានុភាពអវិភាគនៃបណ្ដឹងឧទ្ធរណ៍។

ម្យ៉ាងវិញទៀតនៅក្នុងសាលក្រមដើម ចំពោះផ្នែកដែលបណ្ដឹងឧទ្ធរណ៍មិនបានធ្វើបណ្ដឹងឧទ្ធរណ៍ ភាគីមិនចាំបាច់ធ្វើការទាញហេតុផលឡើយ។ លើសពីនេះទៅតុលាការពុំចាំបាច់ធ្វើការផ្លាស់ប្ដូរការវិនិច្ឆ័យអំពីផ្នែកនោះនៅក្នុងសាលក្រមដើមបានដែរ ប៉ុន្តែការវិនិច្ឆ័យអំពីផ្នែកនោះក៏មិនត្រូវចូលជាស្ថាពរដោយឯកឯងបានដែរ។ ហើយចំពោះផ្នែកណាមួយចំពោះការទាមទារនៃសាលក្រមដើមនឹងត្រូវចូលជាស្ថាពរបើសិនជាភាគី មានការព្រមព្រៀងគ្នាថាមិនប្ដឹងឧទ្ធរណ៍ ឬភាគីទាំងសងខាងលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ និងសិទ្ធិប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំក្នុងផ្នែកនេះ។

ដោយឡែកក្នុងករណីសាលាដំបូងបានចេញសាលក្រម ហើយគូរភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍ចំពោះផ្នែកណាមួយនៃការទាមទារ ឬភាគីទាំងសងខាងលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ និងសិទ្ធិប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះផ្នែកណាមួយនៃការទាមទារ ដែលនាំឱ្យផ្នែកនោះនៃសាលក្រមចុងក្រោយត្រូវចូលជាស្ថាពរ។

ឧទាហរណ៍៖ ដើមចោទ "ក" ប្ដឹងចុងចម្លើយ "ខ" ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីឲ្យចេញសាលក្រមដែលមានខ្លឹមសារ៖

១. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ដើម ៥០,០០០ដុល្លារ ឱ្យដើមចោទ "ក" ។

២.បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ក្នុងអត្រា ១២% ក្នុងមួយឆ្នាំនៃ ទឹកប្រាក់ ១០,០០០ដុល្លារ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ រហូតសងរួច។

៣. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ជាសំណងជំងឺចិត្ត ៥,០០០ដុល្លារ មកឱ្យដើមចោទ "ក"។

**តុលាការចេញសេចក្ដីសម្រេចបញ្ជាប់៖**

១. បង្គាប់ឱ្យចុងចម្លើយ "ខ- បង់ប្រាក់ដើម ៤០,០០០ដុល្លារ ឱ្យដើមចោទ "ក"។

២. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ក្នុងអត្រា១២%ក្នុងមួយឆ្នាំនៃទឹកប្រាក់ ៤០,០០០ដុល្លារ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ រហូតសងរួច។

៣. បង្គាប់ឱ្យចុងចម្លើយ "ខ" បង់ប្រាក់ជាសំណងជំងឺចិត្ត ៥,០០០ដុល្លារ មកឱ្យដើមចោទ "ក"។

ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នា មិនធ្វើបណ្តឹងឧទ្ធរណ៍ និងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំចំពោះចំណុចទី១ និងទី២ នៃសេចក្តីសម្រេចបញ្ចប់របស់សាលក្រមនៃការជំនុំជម្រះលើកទី១ទេ និងត្រូវចូលជាស្ថាពរដោយមិនរង់ចាំផុតអំឡុងពេលនៃការប្តឹងឧទ្ធរណ៍ទេ។ ដូច្នេះដើមចោទអាចដាក់ពាក្យសុំទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ឲ្យប្រកាសការអនុវត្តជាបណ្តោះអាសន្នតែចំណុចទី១ និងទី២ នៃសេចក្តីសម្រេចបញ្ចប់របស់សាលក្រមនៃការជំនុំជម្រះលើកទី១។ ហើយចំពោះចំណុចទី៣វិញ ចុងចម្លើយអាចប្តឹងឧទ្ធរណ៍បាន។ ដូច្នេះការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍ និងប្តឹងឧទ្ធរណ៍បន្ទាប់បន្សំនូវចំណុចណាមួយ ចំណុចដែលបានព្រមព្រៀងនោះនឹងចូលជាស្ថាពរ ទោះបីជាចំណុចផ្សេងទៀត ភាគីបានប្តឹងឧទ្ធរណ៍ក៏ដោយ។

## ផ្នែកទី៤៖ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ និង ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍

ក្រោយពេលដែលតុលាការ នៃបណ្តឹងឧទ្ធរណ៍បានកំណត់នូវកាលបរិច្ឆេទសម្រាប់ការចាប់ផ្តើមជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ គឺតុលាការនឹងធ្វើការទាញហេតុផលដោយផ្ទាល់មាត់យកតែម្តងដោយមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដូចនៅសាលាដំបូងទៀតនោះទេ ដោយសារតែតុលាការទទួលបានសញ្ញាណដែលជាសំណុំរឿងខ្លះទៅហើយដោយផ្អែកទៅលើកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលនៅដំណាក់កាលនៃការជំនុំជម្រះលើកទី១ រួចហើយ។ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំវិញនោះតុលាការនៃបណ្តឹងឧទ្ធរណ៍ ក៏ត្រូវតែធ្វើចំណាត់ការដូចគ្នា។

### ១. បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ

ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺជាបណ្តឹងដែលចុងចម្លើយនៃបណ្តឹងឧទ្ធរណ៍អាចដាក់អមជាមួយនឹងបណ្តឹងឧទ្ធរណ៍ ដើម្បីទាមទារផលប្រយោជន៍ដែលខ្លួនបានបាត់បង់ក្នុងសាលក្រមនៃការជំនុំជម្រះលើកទី ១។ ចុងចម្លើយនៃបណ្តឹងឧទ្ធរណ៍ក៏អាចប្រើយន្តការនេះ ដើម្បីធ្វើបណ្តឹងឧបាស្រ័យ ទាមទារឱ្យផ្លាស់ប្តូរនូវផ្នែកនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលខ្លួនបាត់បង់នូវផលប្រយោជន៍។ ឧទាហរណ៍៖ ដើមចោទ "ក" ទាមទារទៅសាលាដំបូងឱ្យចុងចម្លើយ "ខ" បង់ប្រាក់ ៥០,០០០ដុល្លារ ហើយតុលាការបានសម្រេចឱ្យ ៤០,០០០ ដុល្លារ ក្នុងករណីនេះដើមចោទ "ក" អាចប្តឹងឧទ្ធរណ៍បានចំពោះសាលក្រមនេះ ប៉ុន្តែដើមចោទ "ក" មិនបានធ្វើបណ្តឹងឧទ្ធរណ៍ទេ។ បន្ទាប់មកបើចុងចម្លើយ "ខ" ធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនេះ ពេលនោះដើមចោទក៏បានធ្វើបណ្តឹងឧទ្ធរណ៍ដែរ ដែលបណ្តឹងឧទ្ធរណ៍របស់ដើមចោទហៅថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ អាចធ្វើបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីបណ្តឹងឧទ្ធរណ៍ ប៉ុន្តែត្រូវធ្វើនៅមុនពេលការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍បានបញ្ចប់។ [33] មានន័យថាទោះបីជាសិទ្ធិប្តឹងឧទ្ធរណ៍ត្រូវបានរលត់ក៏ដោយ (ហួសអំឡុងពេលប្តឹងឧទ្ធរណ៍) ក៏ចុងបណ្តឹងឧទ្ធរណ៍អាចធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ។

[33] មាត្រា២៧០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

យ៉ាងណាមិញអំឡុងពេលធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ក៏ដូចគ្នាទៅនឹងបណ្តឹងឧទ្ធរណ៍ដែរ ពោលគឺ ០១ ខែ គិតចាប់ពីថ្ងៃ ដែលភាគីទទួលបានលិខិតសាលក្រម ប៉ុន្តែទោះបីជាអំឡុងពេល ០១ ខែ កន្លងផុតក៏ដោយ ក៏ភាគីចុងបណ្តឹងឧទ្ធរណ៍អាចធ្វើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ។ ក្នុងករណីនេះ បណ្តឹងឧទ្ធរណ៍ត្រូវបាត់បង់អានុភាព នៅពេលដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លើកចោលបណ្តឹងឧទ្ធរណ៍ ឬដើមបណ្តឹងឧទ្ធរណ៍បានដកពាក្យបណ្តឹង នោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំក៏បាត់បង់អានុភាពដែរ ប្រសិនបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងហួសអំឡុងពេលប្តឹងឧទ្ធរណ៍។ មានន័យថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនៅតែអាចធ្វើបានដដែល ប្រសិនបើទោះជាសិទ្ធិប្តឹងឧទ្ធរណ៍របស់ចុងបណ្តឹងឧទ្ធរណ៍បានរលត់ ដោយហេតុថា អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងផុតហើយក៏ដោយ។ក្នុងករណីបែបនោះ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំកាន់តែមានន័យថែមទៀត ព្រោះអំឡុងពេលដែលកំណត់ធ្វើបណ្តឹងឧទ្ធរណ៍ មានរយៈពេល ១ខែ ដោយគិតពីថ្ងៃដែលទទួលការបញ្ជូនលិខិតនៃសាលក្រមចំពោះភាគីនីមួយៗ ហេតុនេះ ថ្ងៃចុងក្រោយនៃអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ អាចនឹងខុសគ្នាចំពោះភាគីម្នាក់ទៅភាគីម្នាក់។

ដោយឡែកក្នុងករណីដែលបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះ ធ្វើឡើងមិនហួសអំឡុងពេលប្តឹងឧទ្ធរណ៍ និងមានលក្ខខណ្ឌ នៃបណ្តឹងឧទ្ធរណ៍គ្រប់គ្រាន់ ករណីនេះហៅថា បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានធ្វើឡើងដោយឯករាជ្យហើយតុលាការនៃបណ្តឹងឧទ្ធរណ៍នេងបន្តចំណាត់ការទៅលើបណ្តឹងឧទ្ធរណ៍នោះ។ ដោយសារតែបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺជាបណ្តឹងឧបាស្រ័យដែលត្រូវបានធ្វើឡើងដោយឆ្លៀតឱកាសដែលមានបណ្តឹងឧទ្ធរណ៍ពីភាគីម្ខាងទៀត ហេតុដូនេះ បើពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានដក ឬ បណ្តឹងឧទ្ធរណ៍លើកចោល នោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ត្រូវបាត់បង់អានុភាព ប៉ុន្តែក្នុងករណីបណ្តឹងឧទ្ធរណ៍ឯករាជ្យទោះបីជាតុលាការលើកចោល ឬដើមបណ្តឹងឧទ្ធរណ៍ដកពាក្យបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏មិនប៉ះពាល់ ឬ បាត់បង់អានុភាពដល់បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែរ ក្នុងករណីនេះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនឹងក្លាយជាបណ្តឹងឧទ្ធរណ៍ឯករាជ្យ ។[34]

ផ្អែកលើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ទំហំនៃឧបាស្រ័យដែលត្រូវបានវិនិច្ឆ័យនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ត្រូវបានពង្រីក មានន័យថា សាលាឧទ្ធរណ៍ ត្រូវវិនិច្ឆ័យមិនមែនតែអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃបណ្តឹងឧបាស្រ័យរបស់ដើមបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ គឺត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃបណ្តឹងឧបាស្រ័យរបស់ចុងចម្លើយឧទ្ធរណ៍ផងដែរ។ ប្រសិនបើមានតែដើមបណ្តឹងឧទ្ធរណ៍ដែលធ្វើឧបាស្រ័យ នោះតុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចផ្លាស់ប្តូរសាលក្រមដើម ដោយខូតខាតផលប្រយោជន៍ចំពោះដើមបណ្តឹងឧទ្ធរណ៍ដោយហួសទំហំនៃសាលក្រមដើមបានឡើយ ប៉ុន្តែបើមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំពីចុងបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ អាចធ្វើការផ្លាស់ប្តូរយ៉ាងដូច្នោះបាន។

[34] មាត្រា ២៧០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

យ៉ាងណាមិញចំពោះរបៀបធ្វើពាក្យបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ និងនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ រមែងត្រូវអនុលោម ទៅតាមបញ្ញត្តិនៃបណ្ដឹងឧទ្ធរណ៍ ពោលគឺត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ។ [35] ហេតុនេះហើយដើមបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ដែលជាចុងបណ្ដឹងឧទ្ធរណ៍ ត្រូវដាក់លិខិតពាក្យបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំទៅតុលាការដើម បន្ទាប់មកបញ្ជូនទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ដើម្បីពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះហើយត្រូវបញ្ជូនពាក្យបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនោះទៅចុងបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ។

## ២. ការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍

បន្ទាប់ពីភាគីបានដាក់បណ្ដឹងទៅតាលគោលការណ៍ដែលបានកំណត់ហើយ នីតិវិធីបន្ទាប់ គឺនីតិវិធីដែលតុលាការទទួលបណ្ដឹង ត្រូវវិនិច្ឆ័យនិងធ្វើការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ដែលនឹងរៀបរាប់ដូចខាងក្រោមនេះ ។ ដោយឡែកក្នុងដំណាក់កាលជំនុំជម្រះលើកទី២ នៅសាលាឧទ្ធរណ៍ត្រូវគោរពតាមគោលការណ៍នៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ និងមានការទាញហេតុផលដោយផ្ទាល់មាត់ ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីត្រៀមទាញហេតុផល ដូចនៅដំណាក់កាលនៃការជំនុំជម្រះលើកទី១ នោះទេ។

### ២.១. គោលការណ៍នៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍

ការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ គឺជាការវិនិច្ឆ័យរកភាពត្រឹមត្រូវ ឬភាពមិនត្រឹមត្រូវនៃបណ្ដឹងឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ យ៉ាងណាមិញតុលាការនៃបណ្ដឹងឧទ្ធរណ៍ក៏ត្រូវពិនិត្យ ឡើងវិញ លើអង្គហេតុ និងអង្គច្បាប់ចំពោះការទាមទារនៃការជំនុំជម្រះលើកទី ១ ទៅតាមទំហំដែលចាំបាច់ ដើម្បីអាចវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការប្ដឹងឧបាស្រ័យនោះ។ ហេតុនេះហើយការប្រព្រឹត្តទៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ គឺមានគោលការណ៍មួយចំនួនដូចខាងក្រោមនេះ ៖

នៅក្នុងការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យអំពីភាពត្រឹម ត្រូវ ឬមិនត្រឹមត្រូវនៃបណ្ដឹងឧបាស្រ័យចំពោះសាលក្រមដើម ម្យ៉ាងទៀតទំហំឧបាស្រ័យនោះ ក៏ត្រូវបានកំណត់ដោយបណ្ដឹងរបស់ដើមបណ្ដឹងឧទ្ធរណ៍ និងចុងចម្លើយនៃបណ្ដឹងឧទ្ធរណ៍ ។ បណ្ដឹងឧបាស្រ័យដែលជាកម្មវត្ថុនៃការវិនិច្ឆ័យគឺ ជាការឧបាស្រ័យចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១។ តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចលុបចោល ឬផ្លាស់ប្ដូរសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ ត្រឹមកម្រិតនៃការ ទាមទារក្នុងបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ (គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី) តែប៉ុណ្ណោះ។ [36] ហេតុនេះចំណុចណាមួយនៃសាលក្រមនៃការជំនុំជម្រះលើកទី១ដែលមិនត្រូវបានប្ដឹងឧទ្ធរណ៍តុលាការនៃបណ្ដឹងឧទ្ធរណ៍

[35] មាត្រា ២៧០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[36] មាត្រា ២៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

មិនអាចសម្រេចបាននោះទេ។ ម្យ៉ាងវិញទៀតដើមបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកនូវសាលដីកា ដែលខូចប្រយោជន៍ច្រើនជាងអ្វីដែលមានសម្រេចនៅក្នុងសាលក្រមនៃការជំនុំជម្រះលើកទី១នោះទេ (គោលការណ៍នៃការហាមឃាត់ការផ្លាស់ប្តូរដោយខូចផលប្រយោជន៍) លើកលែងតែមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ ដោយឡែកនៅក្នុងបណ្តឹងឧទ្ធរណ៍ ភាគីមិនសុខចិត្តមានសិទ្ធអាចធ្វើឧបាស្រ័យចំពោះសេចក្តីសម្រេចអំពីចំណុចដែលជាលក្ខខណ្ឌដើមសម្រាប់សាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ ឬចំណុចដែលទាក់ទងនឹងនីតិវិធី ឬដីកាសម្រេចមិនអនុញ្ញាតឱ្យផ្លាស់ប្តូរ ឬបន្ថែមកម្មវត្ថុបណ្តឹងបានផងដែរ ។[37] ប៉ុន្តែចំណុចទាំងនេះគ្រាន់តែត្រូវបានវិនិច្ឆ័យក្នុងនាមជាមូលដ្ឋាន នៃបណ្តឹងឧបាស្រ័យចំពោះសាលក្រមចុងក្រោយប៉ុណ្ណោះ។

### ២.២. ការទាញហេតុផលដោយផ្ទាល់មាត់

ដោយហេតុថាកម្មវត្ថុចម្បងនៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ គឺជាការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃបណ្តឹងឧទ្ធរណ៍ ហេតុនេះហើយការទាញហេតុផលដោយផ្ទាល់មាត់ គឺធ្វើត្រឹមតែក្នុងទំហំដែលភាគី បានទាមទារឱ្យផ្លាស់ប្តូរនៅសាលក្រមដើមនៃការជំនុំជម្រះលើកទី ១ ប៉ុណ្ណោះ។[38] ដូចនេះ សកម្មភាពបណ្តឹង (ការអះអាងអង្គហេតុការស្នើសុំ សុំពិនិត្យភស្តុតាង ការ សារភាព ជាដើម) ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ មានអានុភាពនៅក្នុងការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ ។[39]

ក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៃការជំនុំជម្រះលើកទី ២ នៅសាលាឧទ្ធរណ៍សមាសភាពក្នុងការធ្វើការជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះដែលមានចៅក្រម ៣ រូប រួមមាន ប្រធានជំនុំជម្រះ ១ រូប និងចៅក្រម ២ រូបទៀត ជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះ និងមានការចូលរួមដោយ ក្រឡាបញ្ជីជាអ្នកកត់ត្រា ១ រូប និងចូលរួមពីសំណាក់អយ្យការ និងមេធាវីតំណាង ឬអ្នកការពារសិទ្ធិ ភាគី ដោយអនុលោមទៅតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី។[40] សម្រាប់រឿងក្តីដែលត្រូវបានតុលាការកំពូលសម្រេចបង្វិលមកវិញ នោះសាលាឧទ្ធរណ៍ចាំបាច់ត្រូវតែធ្វើការជំនុំជម្រះម្តងទៀត ដោយមានក្រុមប្រឹក្សាជំនុំជម្រះដោយមានចៅក្រមចំនួន ៥ រូប និងចៅក្រម ៤ រូបផ្សេងទៀត សុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះកាលពី លើកមុន ។[41]

តុលាការនៃបណ្តឹងឧទ្ធរណ៍ នឹងធ្វើការសម្រេចសេចក្តីដោយ ពិនិត្យមើលទាំងអង្គហេតុ និងអង្គច្បាប់។ ការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃបណ្តឹងឧទ្ធរណ៍ គឺតម្រូវ ឲ្យភាគីធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃការជំនុំជម្រះលើកទី ១ ដោយសារនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ចៅក្រមត្រូវបានផ្លាស់ប្តូរពីចៅក្រមនៃការជំនុំជម្រះលើកទី១។ ហេតុនេះសេចក្តីថ្លែងការណ៍

[37] មាត្រា ៨៤ កថាខណ្ឌទី៤ និងមាត្រា ២៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[38] មាត្រា ២៧២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[39] មាត្រា ២៧៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[40] មាត្រា ២៣ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[41] មាត្រា ៣៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

គ្រាន់តែជាសកម្មភាពរាយការណ៍ដែលមានលក្ខណៈជាទម្រង់ ដើម្បីបំពេញគោលការណ៍វិនិច្ឆ័យដោយផ្ទាល់។ [42] បន្ទាប់មកនឹងមានការបន្តវិនិច្ឆ័យ ដោយបើកឡើងវិញនូវការទាញហេតុផលដោយផ្ទាល់មាត់ជាថ្មី ដែលត្រូវបានបញ្ចប់ម្តងរួចហើយនៅក្នុងការជំនុំជម្រះលើកទី ១ នេះហៅថាការទាញហេតុផលដោយផ្ទាល់មាត់នៅតុលាការនៃបណ្តឹងឧទ្ធរណ៍។ ដូចនេះសកម្មភាពបណ្តឹង ដែលរួមមានការអះអាងអង្គហេតុ ការស្នើសុំឱ្យពិនិត្យភស្តុតាងការសារភាពជាអាទិ៍ ដែលបានធ្វើនៅក្នុងការជំនុំជម្រះលើកទី១ មានអានុភាពនៅក្នុងការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍។ **ឧទាហរណ៍៖** ការជំនុំជម្រះលើកទី១ ភស្តុតាង "ច" មិនត្រូវបានដាក់នោះទេ មកដល់ការជំនុំជម្រះលើកទី២ បានស្នើសុំដាក់ភស្តុតាង "ច" ពេលនោះភស្តុតាង "ច" មិនត្រូវបានអនុញ្ញាតឱ្យដាក់នោះទេ។ ប៉ុន្តែភាគីអាចត្រូវបានផ្តល់ឱកាសឱ្យដាក់មធ្យោបាយតទល់ ឬការពារខ្លួនដែលមិនបានដាក់នៅក្នុងការជំនុំជម្រះលើកទី១ ប្រសិនបើមធ្យោបាយតទល់ ឬការពារខ្លួន (ភស្តុតាង) នោះ មិនផ្ទុយនឹងបញ្ញត្តិនៃមាត្រា១០៨ នៃក្រម នីតិវិធីរដ្ឋប្បវេណី ដែលចែងថា ចំពោះករណីមធ្យោបាយនោះទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬករណីដែលមធ្យោបាយថ្មីនោះមិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង ឬករណីដែលភាគីបានធ្វើសេចក្តីសម្រេចដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះបានមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយគ្មានកំហុសធ្ងន់ធ្ងរឡើយនៅក្នុងការជំនុំជម្រះលើកទី១។ **ឧទាហរណ៍៖** ការជំនុំជម្រះលើកទី១ មិនបានសាកសួរសាក្សី "គ" ការជំនុំជម្រះលើកទី២ អនុញ្ញាតឱ្យសួរសាក្សី "គ" ការដាក់ភស្តុតាងថ្មី ដែលមិនផ្ទុយនឹងបញ្ញត្តិនៃមាត្រា១០៨ នៃក្រមនីតិវិធីប្បវេណី ត្រូវបានអនុញ្ញាតនៅក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ដែលនៅក្នុងការជំនុំជម្រះលើកទី១ ដើមចោទបានដាក់ពាក្យសុំឱ្យសាកសួរសាក្សី "គ" ប៉ុន្តែដោយសារសាក្សី "គ" មានជំងឺធ្ងន់ធ្ងរត្រូវទៅព្យាបាលនៅបរទេស ដោយមិនដឹងពេលណាអាចត្រឡប់មកវិញបាន ហេតុនេះសាក្សី "គ" មិនត្រូវបានសួរនៅក្នុងការជំនុំជម្រះលើកទី១ ទេ ប៉ុន្តែនៅក្នុងការជំនុំម្រះលើបណ្តឹងឧទ្ធរណ៍ សាក្សី "គ" បានជាសះស្បើយពីជំងឺ និងត្រឡប់មកកម្ពុជាវិញ។ [43] ក្នុងករណីនេះតុលាការនៃបណ្តឹងឧទ្ធរណ៍អនុញ្ញាតចំពោះការដាក់ភស្តុតាងថ្មីនេះ។ **បញ្ជាក់៖** ការជំនុំជម្រះ លើកទី២ តុលាការនៃបណ្តឹងឧទ្ធរណ៍ មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ ពីព្រោះសកម្មភាពនៃការជំនុំជម្រះលើកទី១ (សកម្មភាពបណ្តឹងដែលបានធ្វើឡើងនៅក្នុងការជំនុំជម្រះលើកទី១ ដោយរាប់បញ្ចូលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) មានអានុភាពចំពោះការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ ហៅថា របបជំនុំជម្រះបន្ត។[44] ក្រោយពេលការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវប្រកាស និងចេញសាលដីកាចុងក្រោយចំពោះបណ្តឹងឧទ្ធរណ៍ ឬបណ្តឹង

[42] មាត្រា ១៨៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[43] មាត្រា២៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[44] មាត្រា ២៧២ និង ២៧៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ឧទ្ធរណ៍បន្ទាប់បន្សំ ដោយសាលដីកាចុងក្រោយនៃបណ្ដឹងឧទ្ធរណ៍ មាន ៣ (បី) ប្រភេទខុសៗគ្នា។ ក្នុងករណីនេះ តុលាការនៃបណ្ដឹងឧទ្ធរណ៍ធ្វើការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ ចំណែកឯភាគីដែលមិនពេញចិត្តនឹងសេចក្ដីសម្រេចដែលមានក្នុងសាលដីការបស់សាលាឧទ្ធរណ៍ ភាគីអាចប្ដឹងសាទុក្ខទៅតុលាការកំពូលតាមកំណត់របស់ច្បាប់បាន។

## ផ្នែកទី៥៖ ការបញ្ចប់បណ្ដឹងឧទ្ធរណ៍

ក្រោយពីការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់រួចរាល់ ហេតុនេះតុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវតែបញ្ចប់បណ្ដឹងឧទ្ធណ៍ដោយប្រើប្រាស់វិធីពីរយ៉ាងដូចជា ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ និង ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ ដែលនឹងត្រូវបកស្រាយនៅចំណុចបន្ទាប់

### ១. ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ

ចំពោះការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ អាចជាការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ ឬអាចជាការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយសកម្មភាពភាគី

#### ១.១. ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ

ការបញ្ចប់បណ្ដឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិអាចមានលក្ខណៈងាយស្រួលជាងគេ។ ក្នុងអំឡុងពេលដែលនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍កំពុងដំណើរការ ករណីនៅពេលដែលមានភាគីណាម្ខាងបានទទួលមរណភាព ហើយមិនមានអ្នកទទួលបន្តនូវសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹង ដែលអាចនាំឲ្យបណ្ដឹងនោះត្រូវបានបញ្ចប់។ យ៉ាងណាមិញ ប្រសិនបើមានភាគីណាម្ខាងបានទទួលមរណភាពក៏ដោយ សន្តតិជនរបស់ភាគីដែលទទួលមរណភាពនោះ នឹងត្រូវទទួលបន្តនូវនីតិវិធីនៃបណ្ដឹងដែលបានធ្វើពីមុនមក ហើយនីតិវិធីបណ្ដឹងឧទ្ធរណ៍នោះមិនត្រូវបានបញ្ចប់ទេ។ ប្រសិនបើមានករណី ដែលភាគីណាម្ខាងបានទទួលមរណភាពនោះ ប៉ុន្តែពុំមានអ្នកដែលត្រូវទទួលបន្តនូវនីតិវិធីនៃបណ្ដឹងដោយសារសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹង តុលាការនៃបណ្ដឹងឧទ្ធរណ៍នឹងចេញសាលដីកាបញ្ចប់បណ្ដឹងនោះ ដោយស្វ័យប្រវត្តិ ដោយខ្លឹមសារថា បណ្ដឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ដោយសារមរណភាពរបស់ភាគី។

ដោយឡែកក្នុងករណី សិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងបានរលត់ដោយសារតែការរួមបញ្ចូលគ្នានៃនីតិបុគ្គលនាំឲ្យសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងនោះ ត្រូវធ្លាក់លើបុគ្គលតែម្នាក់ ហើយដើមបណ្ដឹងឧទ្ធរណ៍ និងចុងបណ្ដឹងឧទ្ធរណ៍បានក្លាយទៅជាបុគ្គលតែមួយ ដោយសារតែភាគីណាម្ខាងបានទទួលបន្តនូវឋានៈតាមផ្លូវបណ្ដឹងរបស់ភាគីម្ខាងទៀត ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គល ឬដោយសន្តតិកម្ម។ ក្នុងករណីនេះ តុលាការនឹងចេញសាលដីកាបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តិ ដោយសារតែមានភាគីជាបុគ្គលតែមួយ។

### ១.២. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយសកម្មភាពភាគី

ចំពោះការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់ភាគី ក្នុងនោះអាចជាសកម្មភាពនៃការដកពាក្យបណ្តឹង ការលះបង់ ឬការទទួលស្គាល់ការទាមទារ និងការសះជាតាមផ្លូវបណ្តឹងរបស់ភាគី នឹងសកម្មភាពនៃបណ្តឹងត្រូវបានបញ្ចប់ផងដែរ ៖

- ទោះបីជាបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់រួចហើយក៏ដោយ ភាគីក៏នៅតែមានសិទ្ធិនៅក្នុងការដកពាក្យបណ្តឹងវិញនៅពេលណាក៏បានរហូតដល់ពេល ដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបានប្រកាស ដោយមិនចាំបាច់ទទួលការឯកភាពយល់ព្រមពីចុងបណ្តឹងឧទ្ធរណ៍ ។[45] ជាក់ស្តែងក្នុងអំឡុងពេលនៃការដកពាក្យបណ្តឹងឧទ្ធរណ៍ គឺចាប់ពីការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ រហូតដល់ការប្រកាសសាលដីកានៃការជំនុំជម្រះលើកទី២ ឬក្នុងនាមការជំនុំជម្រះលើកទី១ នៅពេលដែលប្រកាស សាលដីការួច សិទ្ធិក្នុងការដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានរលត់។ ការដកពាក្យបណ្តឹងឧទ្ធរណ៍ គឺជាការដកចេញនូវការធ្វើឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ ហេតុនេះអានុភាពនៃការដកបណ្តឹងឧទ្ធរណ៍ នាំឱ្យនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ និងត្រូវបានចាត់ទុកថាគ្មានបណ្តឹងឧទ្ធរណ៍តាំងពីដើមហើយសាលក្រមនៃការជំនុំជម្រះលើកទី១ ត្រូវចូលជាស្ថាពរតាំងពីថ្ងៃផុតអំឡុងពេលនៃការប្តឹងឧទ្ធរណ៍។[46] ក្នុងករណីនេះការចាត់ទុកបណ្តឹងទាំងមូល រួមទាំងសាលក្រមនៃការជំនុំជម្រះលើកទី១ នឹងត្រូវរលត់ដោយអានុភាពប្រតិសកម្ម។ ក្នុងការការដកពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ប៉ុន្តែនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្តឹងឧទ្ធរណ៍អាចធ្វើដោយផ្ទាល់មាត់បាន។ ចំពោះការដកពាក្យបណ្តឹងឧទ្ធរណ៍មួយផ្នែក គឺហៅថាមោឃៈ ដោយសារគោលការណ៍នៃភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍។ ការដកពាក្យបណ្តឹងមិនមានឥទ្ធិពលទៅលើសាលក្រមដើម ឬអានុភាពនៃការជំនុំជម្រះលើកទី១ទេ ហើយមិនឱ្យមានការខូចផលប្រយោជន៍ដល់ចុងបណ្តឹងឧទ្ធរណ៍ទេ ហេតុនេះមិនចាំបាច់មានការយល់ព្រមពីចុងបណ្តឹងឧទ្ធរណ៍ឡើយ។ ក្រោយពីការដកពាក្យបណ្តឹងឧទ្ធរណ៍ ប្រសិនបើអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍មិនទាន់កន្លងផុតទេ នោះភាគីម្ខាងទៀតព្រមទាំងដើមបណ្តឹងឧទ្ធរណ៍ដែលបានដកពាក្យបណ្តឹងរួចហើយ ក៏អាចប្តឹងឧទ្ធរណ៍ម្តងទៀតបានដែរ។ នៅពេលដែលដកពាក្យបណ្តឹងឧទ្ធរណ៍ អាចមានការសងពន្ធដាក់ពាក្យសុំពាក់កណ្តាល លុះត្រានៅក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដកមុនកាលបរិច្ឆេទ នៃការទាញ

[45] មាត្រា២៦៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[46] មាត្រា២៦៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ហេតុផលដោយផ្ទាល់មាត់លើកដំបូងនៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ដូច្នេះដើមបណ្តឹងឧទ្ធរណ៍អាចដាក់ពាក្យសុំឱ្យសងពាក់កណ្តាលនៃពន្ធដាក់ពាក្យសុំ។

- ការលះបង់ ឬការទទួលស្គាល់នូវការទាមទារ[47] ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍ដែលធ្វើ មានការខូចខាតផលប្រយោជន៍របស់ខ្លួនទទួលស្គាល់ថា ការទាមទារ របស់ខ្លួនពុំមានមូលហេតុត្រឹមត្រូវ ឬទទួលស្គាល់ថាការទាមទាររបស់ភាគីម្ខាងទៀតមានមូលហេតុត្រឹមត្រូវចំពោះការទាមទារ។ ដោយឡែកការលះបង់ ឬការទទួលស្គាល់ថាការទាមទារជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងដែលភាគីម្ខាងទទួល ស្គាល់ពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារ ហើយវិវាទរវាងភាគីទាំងសងខាងត្រូវបានដោះស្រាយដោយសេចក្តីថ្លែងការណ៍ នោះសកម្មភាពទាំងនេះនាំឱ្យបណ្តឹងត្រូវបានបញ្ចប់ដោយមិនចាំបាច់រង់ចាំសាលដីកាទេ។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់ក្នុងការទទួលស្គាល់នូវការទាមទារ គឺជាសកម្មភាពបណ្តឹងមួយយ៉ាងសំខាន់ក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹងឧទ្ធរណ៍ ហេតុនេះហើយភាគីចាំបាច់ ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង។ ចំពោះអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើការលះបង់ ឬ ទទួលស្គាល់នូវការទាមទារមានសុពលភាពបាន លុះត្រាតែត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់ លើកលែងតែអនីតិជនដែលអាចធ្វើសកម្មភាពដោយឯករាជ្យ។ ចំណែកឯជននៅក្រោមហិតូបត្ថម្ភ ឬអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវមានការប្រគល់សិទ្ធិពិសេស ដើម្បីធ្វើសកម្មភាពក្នុងការលះបង់ការទាមទារ ឬទទួលស្គាល់នូវការទាមទារនេះ។ ទៀតសោតចំពោះអានុភាពនៃការលះបង់ ឬការទទួលស្គាល់នូវការទាមទារនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ នឹងត្រូវពិនិត្យមើលអំពីលក្ខខណ្ឌនៃបណ្តឹង និង លក្ខខណ្ឌនៃសមត្ថភាពរបស់ភាគីជាមុនសិន ប្រសិនបើពិនិត្យទៅឃើញថាភាគីមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ក្នុងការលះបង់ ឬទទួលស្គាល់នូវការទាមទារ ក្រឡាបញ្ជីត្រូវចុះក្នុងកំណត់ហេតុ ដែលនាំឲ្យបណ្តឹងត្រូវបានបញ្ចប់ ហើយកំណត់ហេតុនោះមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរ។ យ៉ាងណាមិញកំណត់ហេតុដែលបានចុះអំពីការលះបង់នូវការទាមទាររបស់ដើមបណ្តឹងឧទ្ធរណ៍ ក៏មានអានុភាពដូចគ្នាទៅនឹងសាលដីកាដែលច្រានចោលនូវការទាមទារ របស់ដើមបណ្តឹងឧទ្ធរណ៍ដែរ។ រីឯកំណត់ហេតុដែលចុះអំពីការទទួលស្គាល់នូវការទាមទាររបស់ចុងបណ្តឹងឧទ្ធរណ៍ ក៏មានអានុភាពដូចគ្នានឹងសាលដីកា ដែលទទួលស្គាល់នូវការទាមទាររបស់ដើមបណ្តឹងឧទ្ធរណ៍ដែរ។
- ការសះជាតាមផ្លូវបណ្តឹង គឺជាសកម្មភាពមួយដែលដើមបណ្តឹងឧទ្ធរណ៍ និងចុងបណ្តឹងឧទ្ធរណ៍ធ្វើសម្បទានឲ្យគ្នាទៅវិញទៅមកនូវ ការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត

[47] មាត្រា ២៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដែលជាកម្មវត្ថុនៃបណ្តឹង នេះជាការព្រមព្រៀងគ្នាបញ្ចប់វិវាទនៅក្នុងនីតិវិធីបណ្តឹងតាមរយៈការ សម្រុះសម្រួលគ្នាចំពោះទំនាក់ទំនងនៃសិទ្ធិដែលជាចំណុចវិវាទ ដោយភាគីទាំងសងខាងចាំបាច់ត្រូវ បង្ហាញខ្លួននៅចំពោះមុខតុលាការនៃបណ្តឹងឧទ្ធរណ៍ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយ ផ្ទាល់មាត់ ហើយព្រមព្រៀងគ្នាដោយផ្ទាល់មាត់។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្តឹង ក៏ជាសកម្មភាពបណ្តឹងដែរ ហេតុនេះដើម្បីធ្វើការសះជាបាន ភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ដូច្នេះបើមានភាគីណាមួយជាបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពបានធ្វើការសះជា គឺពុំមានអានុភាពឡើយ។ ចំពោះការតំណាងដោយអាណត្តិសម្រាប់ភាគីអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់អនីតិជន ជននៅក្រោយអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភមានលក្ខណៈដូចគ្នានឹងការលះបង់ ឬការទទួលស្គាល់នូវការទាមទារដែរ។ អានុភាពនៃការសះជាមានអានុភាព បញ្ចប់បណ្តឹងដោយការសះជា គឺជាការព្រមព្រៀងបញ្ចប់វិវាទរបស់ភាគីនៃបណ្តឹងឧទ្ធរណ៍ដែលបានកត់ត្រានៅក្នុងកំណត់ហេតុ ដូច្នេះលទ្ធផលនៃការសះជាតាមផ្លូវបណ្តឹងនេះ នាំឱ្យនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ចប់ផងដែរ។[48] កំណត់ហេតុនៃការសះជាកំណត់ហេតុនៃការសះជារបស់ភាគីទាំងសងខាងមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរដែរប្រសិនបើក្នុងកំណត់ហេតុនេះ មានចុះអំពីសិទ្ធិទាមទារផ្តល់តាវកាលិក ជាក់ស្តែងដោយមានការកំណត់ពេលអនុវត្ត និងបែបផែននៃការអនុវត្ត ដូច្នេះ ហើយកំណត់ហេតុសះជា ត្រូវមានអានុភាពអនុវត្ត ហើយកំណត់ហេតុនេះក្លាយទៅជាលិខិតអនុវត្ត ដែលភាគីអាចសម្រេចនូវសិទ្ធិទាមទារតាមរយៈការអនុវត្តដោយបង្ខំបាន។ ក្នុងករណីការសះជាតាមផ្លូវបណ្តឹងមានវិការៈភាគីអាចអះអាងអំពីមោឃភាព ឬការលុបចោលការសះជានោះដោយយកវិការៈ ក្នុងការបង្ហាញឆន្ទៈមកធ្វើជាមូលហេតុនៅពេលក្រោយបាន។ ប្រសិនបើមានជម្លោះអំពីអានុភាពនៃការសះជា នោះនីតិវិធីនៃការដោះស្រាយនេះមិនមែនជាការសុំជំនុំជម្រះសាជាថ្មីដូចករណីសាលដីកាទេ គឺគ្រាន់តែជាការស្នើសុំតុលាការនៃបណ្តឹងឧទ្ធរណ៍ ធ្វើការកំណត់ឡើងវិញនូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីតែប៉ុណ្ណោះ។ បើសិនជាមានពាក្យសុំ តុលាការនៃបណ្តឹងឧទ្ធរណ៍កំណត់នូវកាលបរិច្ឆេទជាថ្មីម្តងទៀត ដោយមានមូលហេតុមានវិការៈក្នុងការសះជា តុលាការនៃបណ្តឹងឧទ្ធរណ៍ ចាំបាច់ត្រូវកំណត់នូវកាលបរិច្ឆេទនោះម្តងទៀតតាមពាក្យសុំរបស់ភាគី ហើយនៅកាលបរិច្ឆេទជាថ្មីនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យជាមុនថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព ឬគ្មានសុពលភាព។ ប៉ុន្តែ បើការវិនិច្ឆ័យឃើញថា ការសះជានោះមានវិការៈតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការបញ្ជាក់ថា បណ្តឹងនោះមិនទាន់ត្រូវបានបញ្ចប់ទេ ហើយត្រូវ

[48] មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បន្តការវិនិច្ឆ័យលើបណ្តឹងនោះ។ ប៉ុន្តែបើ វិនិច្ឆ័យឃើញថា ការសះជាដែលបានធ្វើពីមុននោះមានសុពលភាព តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាដែលប្រកាសអំពីការបញ្ចប់បណ្តឹងដោយការសះជានោះ។ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តីភាគីដែលត្រូវទទួលបន្ទុកនៃប្រាក់ប្រដាប់ក្តី គឺអាស្រ័យទៅលើការព្រមព្រៀងរបស់ភាគីនោះ ដោយឡែកប្រសិនបើភាគីគ្មានការព្រមព្រៀងគ្នាអំពីប្រាក់ប្រដាប់ក្តីទេ នោះភាគីនីមួយៗត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន។ បើការសះជាបានសម្រេចលទ្ធផលមុនពេលធ្វើការទាញហេតុផលមាត់ ដើមបណ្តឹងឧទ្ធរណ៍ទទួលបានការសងវិញនូវចំនួនពាក់កណ្តាលនៃពន្ធដែលបានបង់រួចហើយ។

## ២. ការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

បន្ទាប់ពីបានវិនិច្ឆ័យលើបណ្តឹងស្រ័យឧបាស្រ័យរួចរាល់ហើយ តុលាការត្រូវធ្វើការចេញដីកានៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ដែលជាការបញ្ចប់បណ្តឹងឧទ្ធរណ៍ដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ដោយការចេញសាលដីកាចំពោះបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែលអាចជាដូចជា សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍ សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ និង សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍ដែលនឹងបកស្រាយខាងក្រោមនេះ ។

### ២.១. សាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍

ជាគោលការណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ធ្វើការវិនិច្ឆ័យទៅលើបណ្តឹងឧទ្ធរណ៍នោះថាត្រឹមត្រូវតាមច្បាប់ឬអត់នោះត្រូវតែមានការបើកការទាញហេតុផលដោយផ្ទាល់មាត់។[49] តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាចុងក្រោយ ចំពោះបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងឧទ្ធរណ៍ បន្ទាប់បន្សំ។ ប្រសិនបើបណ្តឹងឧទ្ធរណ៍នោះមិនស្រមច្បាប់ដោយសារខ្វះនូវល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវចេញសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍នោះ។[50] ប៉ុន្តែចំពោះបណ្តឹងឧទ្ធរណ៍មាន លក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតចំពោះល័ក្ខខ័ណ្ឌនោះមិនអាចកែតម្រូវបានទេ តុលាការអាចលើកចោលបណ្តឹងឧទ្ធរណ៍ ដោយសាលដីកា ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន។ តុលាការនៃបណ្តឹងឧទ្ធរណ៍ ចេញសាលដីកាលើកបណ្តឹងឧទ្ធរណ៍ចោល ក្នុងករណីបណ្តឹងឧទ្ធរណ៍មិនស្របច្បាប់ ឬខុសល័ក្ខខណ្ឌនៃបណ្តឹងឧទ្ធរណ៍ដែលមិនអាចកែតម្រូវបាន ដូចជាករណីផុតសិទ្ធិប្តឹងឧទ្ធរណ៍ ឬគ្មានផលប្រយោជន៍នៃបណ្តឹងឧទ្ធរណ៍ជាអាទិ៍ ហេតុនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាលើកបណ្តឹងឧទ្ធរណ៍ចោល ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។ តែចំពោះសិទ្ធិពិនិត្យ ពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍ និងការ

[49] មាត្រា១១៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៦

[50] មាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ គឺត្រូវលើកពាក្យបណ្តឹងឧទ្ធរណ៍ចោលដោយដីកាសម្រេចរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ។[51]

ក្នុងករណីបណ្តឹងឧទ្ធរណ៍ត្រូវបានលើកចោល នោះនាំឱ្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំក៏ត្រូវលើកចោល ដែរ ប្រសិនបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះបានធ្វើឡើងហួសអំឡុងពេលប្តឹងឧទ្ធរណ៍ ដែលនាំឱ្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានបាត់បង់អានុភាព ព្រោះបណ្តឹងឧទ្ធរណ៍មិនស្របនឹងច្បាប់។ ដោយឡែកបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះធ្វើឡើងមិនហួសអំឡុងពេលប្តឹងឧទ្ធរណ៍ និងមានល័ក្ខខ័ណ្ឌនៃបណ្តឹងឧទ្ធរណ៍គ្រប់គ្រាន់ ដែលហៅថាបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដោយឯករាជ្យ ហើយទោះបីជាតុលាការលើកចោលបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏មិនប៉ះពាល់ ឬបាត់បង់អានុភាពដល់បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំដែរ។

## ២.២. សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍

តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាចុងក្រោយ ចំពោះបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ។ នៅពេលដែលតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើក ទី ១ មានភាពត្រឹមត្រូវទោះបីជាសំអាងហេតុនៃសាលក្រមនោះមិនត្រឹមត្រូវ ក៏តុលាការនៃបណ្តឹង ឧទ្ធរណ៍ត្រូវច្រានចោលនូវបណ្តឹងនោះដោយហេតុថាវា គ្មានមូលហេតុក្នុងការធ្វើបណ្តឹងឧបាស្រ័យ ចំពោះសាលក្រមទេ[52] ពីព្រោះគ្មានមូលហេតុក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ចំពោះសាលក្រមនៃការជំនុំ ជម្រះលើកទី ១ ទេ។

ប្រសិនបើទំហំនៃការទាមទារដែលសុំបានដោយពាក្យបណ្តឹង ឬបណ្តឹងនោះតែប៉ុណ្ណោះ ហើយអានុភាពនៃអាជ្ញាអស់ជំនុំមិនអាចមានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រមនោះទេ។ ហេតុដូច្នេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ មិនចាំបាច់ធ្វើសាលដីកាដែលរក្សាទុកសេចក្តី សម្រេចបញ្ចប់ នៃការជំនុំជម្រះលើកទី ១ ដោយគ្រាន់តែប្តូរនូវមូលហេតុឡើយ។ ដូចនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ អាចនឹងច្រានចោលនូវបណ្តឹងឧទ្ធរណ៍បាន។ ក្នុងករណីដែលមានអានុភាព នៃអាជ្ញាអស់ជំនុំមានទៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រមតុលាការ នៃបណ្តឹងឧទ្ធរណ៍ត្រូវ ប្រកាសនូវសាលដីកាដែលមាន នូវសេចក្តីសម្រេចបញ្ចប់ដូចនឹងសាលក្រមដើមដោយប្តូរនូវសំអាងហេតុ។ ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំវិញ តាមមាត្រា ២៧០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ ក៏តុលាការត្រូវច្រានចោលពាក្យបណ្តឹង ឧទ្ធរណ៍បន្ទាប់បន្សំនោះដែរ។ប្រសិនបើសាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ចូលជាស្ថាពរ សាលក្រមដើមក៏ត្រូវចូលជាស្ថាពរដែរ។ ក្នុងករណីនេះប្រសិនបើសាលក្រមដើមជាសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកសាលក្រមដើមក្លាយទៅជាលិខិតអនុវត្ត។[53]

---

[51] មាត្រា ២៦៦ និង មាត្រា ២៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[52] មាត្រា ២៧៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[53] មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធី រដ្ឋប្បវេណី ឆ្នាំ២០០៦

### ២.៣. សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍

យ៉ាងណាមិញ ក្នុងករណីដែលការប្តឹងឧបាស្រ័យចំពោះសាលក្រមនៃការជុំនំជម្រះលើកទី១ មានមូលហេតុត្រឹមត្រូវ ហើយសាលក្រមនៃការជុំនំជម្រះលើកទី ១ មិនត្រឹមត្រូវ ឬប្រសិនបើនីតិវិធីនៃការជំនុំជម្រះលើកទី ១ មានលក្ខណៈខុសច្បាប់ធ្ងន់ធ្ងរ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចយកនីតិវិធីនៃការ ជំនុំជម្រះលើកទី ១ នោះមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យបានទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ហើយត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១នោះ។[54] ផ្ទុយមកវិញប្រសិនបើសាលាឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មានភាពមិនត្រឹមត្រូវ ឬខុសនីតិវិធីធ្ងន់ធ្ងរតុលាការ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍អាចធ្វើការវិនិច្ឆ័យដោយ ខ្លួនឯងជំនួសសាលាដំបូង ឬបញ្ជូនត្រលប់ ឬផ្ទេររឿងក្តី។ ការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ មានន័យថាតុលាការមិនបានឆ្លើយតបទៅតុលាការមិនបានឆ្លើយតបទៅនឹងបណ្តឹងដែលបានប្តឹងមក ហេតុនេះតុលាការត្រូវចាត់វិធានការសមរម្យដូចខាងក្រោមនេះ៖

#### ២.៣.១. ការលុបចោល និងការវិនិច្ឆ័យដោយខ្លួនឯង

ដោយហេតុថាការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ គឺជាការវិនិច្ឆ័យទៅលើអង្គហេតុ ដូច្នេះនៅពេលតុលាការនៃបណ្តឹងឧទ្ធរណ៍ទទួលស្គាល់បណ្តឹងឧទ្ធរណ៍ក្នុងពីរករណី គឺតុលាការនៃបណ្តឹង ឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មានភាពមិនត្រឹមត្រូវ ឬខុសនីតិវិធីធ្ងន់ធ្ងរ ៖

➢ ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ប្រសិនបើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ មានភាពមិនត្រឹមត្រូវគឺជាសាលក្រម ដែលមានកំហុស។[55] ឧទាហរណ៍ ៖ សាលក្រមដើមសម្រេច ដើមចោទឈ្នះក្តីដែលមានខ្លឹមសារថា បង្គាប់ឱ្យចុងចម្លើយលុបចោលនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី L ទាំងមូល ដោយមូលហេតុ រំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី០១ ខែមករា ឆ្នាំ ២០២១ ផ្អែកលើអត្ថិភាពនៃអង្គហេតុរំលាយកិច្ចសន្យា ប៉ុន្តែតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថាគ្មានអត្ថិភាពនៃអង្គហេតុរំលាយទេដែលមិនមានភាពត្រឹមត្រូវ ដោយផ្អែកលើសំអាងហេតុផ្សេង គប្បីឱ្យដើមចោទចាញ់ក្តី (ចុងបណ្តឹងឧទ្ធរណក្នុងករណីនេះតុលាការនៃ បណ្តឹងឧទ្ធរណ៍មិនលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ទាំងស្រុងនោះទេ ប៉ុន្តែធ្វើការផ្លាស់ប្តូរ ឬកែប្រែខ្លឹមសារសាលក្រមនៃការជំនុំជម្រះលើកទី១។ ដូច្នេះករណីនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ជំនុំជម្រះលើសាលក្រមដើម ដោយចេញសេចក្តីសម្រេចបញ្ចប់នៃសាលដីកាដោយកែប្រែ ឬផ្លាស់ប្តូរនូវសាលក្រមដើម។[56]

[54] មាត្រា ២៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[55] មាត្រា ២៧៩ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[56] មាត្រា ២៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

➢ ចំពោះករណីតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី១ ខុសនីតិវិធីធ្ងន់ធ្ងរ។[57] ចំពោះកំហុសនីតិវិធីធ្ងន់ធ្ងរមានដូចជាការសាកសួរសាក្សីនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬការប្រកាសសាលក្រមដោយចៅក្រមដែលមិនមែនជាអ្នកវិនិច្ឆ័យជាអាទិ៍។ ឧទាហរណ៍៖ តុលាការនៃការជំនុំជម្រះលើកទី១ នៅដំណាក់នីតិវិធីត្រៀមទាញហេតុផល បានធ្វើការសាកសួរសាក្សីដែលជាកំហុសនៃនីតិវិធី ដំណាក់កាលនេះជាដំណាក់កាលរៀបចំការអះអាង ចំណុចវិវាទ និងភស្តុតាង។ ប៉ុន្តែតុលាការនៃការជំនុំជម្រះលើកទី១ ទទួលស្គាល់ចម្លើយរបស់សាក្សី "គ"។ មកដល់តុលាការនៃបណ្តឹងឧទ្ធរណ៍នឹងធ្វើការសាកសួរសាក្សី "គ" ជាថ្មីម្តងទៀត។ ក្នុងករណីតុលាការនៃបណ្តឹងឧទ្ធរណ៍មិនជឿលើចម្លើយរបស់សាក្សី "គ" តុលាការនឹងលុបចោលសាលក្រមដើម។ ប៉ុន្តែប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍ជឿលើចម្លើយរបស់សាក្សី "គ" តុលាការនឹងច្រានចោលបណ្តឹងឧទ្ធរណ៍។ ម៉្យាងទៀតក្នុងករណីតុលាការយល់ឃើញថាមានភាពចាំបាច់ក្នុងការកំណត់ចំណុចវិវាទថ្មី តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញដីកាសម្រេចបង្វិលមកនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីនៅតុលាការដើម។[58] ដូច្នេះករណីនេះតុលាការនៃបណ្តឹងឧទ្ធរណ៍ជំនុំជម្រះលើសាលក្រមដើមដោយចេញសេចក្តីសម្រេចបញ្ចប់នៃសាលដីកា ដោយលុបចោលនូវសាលក្រមដើម។

### ២.៣.២. ការលុបចោល និងការបញ្ជូនត្រលប់ទៅតុលាការដើមវិញ

ក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ បានទទួលពាក្យបណ្តឹងចំពោះសាលក្រម នៃការជំនុំជម្រះលើកទី១ បើតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា បណ្តឹងនោះមិនត្រឹមត្រូវតាមច្បាប់ ឬសាលក្រមនៃការជំនុំជម្រះលើកទី១ មិនត្រឹមត្រូវតាមច្បាប់ ហើយមានភាពចាំបាច់ត្រូវទាញហេតុផលបន្ថែមទៀតចំពោះរឿងក្តី នោះតុលាការនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី១ ដោយបញ្ជូនត្រឡប់ទៅតុលាការដើម នោះគឺជាសាលាដំបូងរាជធានីខេត្តវិញ។[59] លើសពីនេះទៅទៀត តុលាការអាចលើកចោលបណ្តឹង ដោយមូលហេតុខ្វះលក្ខខណ្ឌនៃបណ្តឹងជួយច្បាប់ដែលមិនអាចកែតម្រូវបាន។ យ៉ាងណាមិញ នៅពេលដែលតុលាការនៃបណ្តឹងឧទ្ធរណ៍ទទួលស្គាល់លើបណ្តឹងឧទ្ធរណ៍ ហើយលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះការប្តឹងរបស់ដើមចោទនឹងត្រឡប់ទៅស្ថានភាពដែលគ្មានការឆ្លើយតបវិញ។ ហេតុនេះនៅក្រោមប្រព័ន្ធបន្តការវិនិច្ឆ័យ ជាគោលការណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះដោយខ្លួនឯងទៅលើការទាមទារនោះថាតើត្រឹមត្រូវឬអត់។ ប៉ុន្តែនៅក្នុងករណីដែល សាលក្រមរបស់តុលាការនៃការជំនុំជម្រះលើកទី ១ លើកចោលបណ្តឹងដោយ

[57] មាត្រា ២៧៩ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[58] មាត្រា១១៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[59] មាត្រា ២៨០ កថាខណ្ឌទី ១ និង ទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ខ្វះលក្ខខណ្ឌនៃបណ្ដឹង នោះអាចមានករណីដែលតុលាការនៃការជំនុំជម្រះលើកទី ១ បានវិនិច្ឆ័យទៅលើអង្គហេតុ ពុំបានគ្រប់គ្រាន់ទេ ហេតុដូចនេះដើម្បីរក្សាផលប្រយោជន៍របស់ភាគីនៅដំណាក់កាលវិនិច្ឆ័យ ពោលគឺដើម្បីធានាទៅលើឱកាសដែលអាចធ្វើនីតិវិធីបាន ២ ដង ក្នុងការវិនិច្ឆ័យរឿងពិត ទម្រាំទៅដល់ការវិនិច្ឆ័យនៅតុលាការនៃបណ្ដឹងឧទ្ធរណ៍។ ជាគោលការណ៍ តុលាការនៃបណ្ដឹងឧទ្ធរណ៍បញ្ជូនត្រឡប់ទៅតុលាការនៃការជំនុំជម្រះលើកទី ១ វិញ (សាលាដំបូង) ហើយធ្វើនីតិវិធីនោះសាសជាថ្មីឡើងវិញ។ ប៉ុន្តែក្នុងករណីដែលការវិនិច្ឆ័យទៅលើអង្គហេតុនោះគ្រប់គ្រាន់ហើយ ឬក្នុងករណីដែលគូភាគីពុំមានវិវាទអំពីទំនាក់ទំនងនៃអង្គហេតុទេ តុលាការនៃបណ្ដឹងឧទ្ធរណ៍ពុំចាំបាច់បញ្ជូនត្រឡប់ទៅវិញឡើយ ។[60]

### ២.៣.៣. ការលុបចោល និងការផ្ទេររឿងក្ដីទៅតុលាការផ្សេង

តុលាការនៃបណ្ដឹងឧទ្ធរណ៍លុបចោលសាលក្រមដើម និងផ្ទេររឿងក្ដីទៅតុលាការដែលមានសមត្ថកិច្ច ក្នុងករណីតុលាការនៃការជំនុំជម្រះលើកទី១ បានធ្វើការជំនុំជម្រះលើរឿងក្ដីដែលខ្លួនគ្មានសមត្ថកិច្ច។[61] ទោះបីជាខុសសមត្ថកិច្ចផ្ដាច់មុខក៏ដោយ ក៏រឿងនេះ មិនអាចក្លាយទៅជាមូលហេតុនៃការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែរ។ ក្នុងករណីដែលបានលុបចោលនូវសាលក្រមរបស់សាលាដំបូង ដោយមូលហេតុខុសសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវផ្ទេររឿងក្ដីនោះ ទៅតុលាការដែលមានសមត្ថកិច្ចវិញ ដោយមិនចាំបាច់បញ្ជូនរឿងក្ដីនោះត្រឡប់ទៅតុលាការដែលបានចេញសាលក្រមនៃការជំនុំជម្រះលើកទី ១ ទេ។ នៅក្នុងរឿងក្ដីទាក់ទងនឹងឋានៈបុគ្គល សមត្ថកិច្ចជម្រះក្ដី ជាសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចលើលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល ឬលំនៅឋានរបស់ភាគីនោះទទួលមរណភាព។ ក្នុងករណីលំនៅឋានរបស់ភាគីមិនច្បាស់លាស់ គឺកំណត់យកទីសំណាក់ បើគ្មានទីសំណាក់គឺកំណត់យកទីតាំងស្នាក់ការចុងក្រោយប់មិនអាចកំណត់បានទេបណ្ដឹងឋានៈបុគ្គលស្ថិតក្រោមសមត្ថកិច្ចរបស់សាលាដំបូងរាជធានីភ្នំពេញ។ **ឧទាហរណ៍៖** ដើមចោទ "ក" ប្ដឹងលែងលះជាមួយនឹងចុងចម្លើយ "ខ"។ "ក" មានលំនៅឋានខេត្តកំពង់ចាម ហើយ "ខ" មានលំនៅឋាននៅខេត្តកណ្ដាល ពួកគេបានចុះសំបុត្រអាពាហ៍អាពាហ៍នៅ ខេត្តកណ្ដាល បន្ទាប់មក អ្នកទាំងពីរបានរស់នៅខេត្តកណ្ដាលអស់រយៈពេល៥ឆ្នាំ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយ អ្នកទាំងពីរមានភាពមិនចុះសម្រុងនឹងគ្នា "ខ" បានចាកចេញពីកំពង់ចាមមករស់នៅភ្នំពេញ។ "ក" បានប្ដឹងលែងលះ "ខ" មកសាលាដំបូងរាជធានីភ្នំពេញ ហើយសាលាដំបូងនេះ ក៏បានចាត់ការលើបណ្ដឹង និងចេញសាលក្រម បន្ទាប់មក "ខ" បានប្ដឹងឧទ្ធរណ៍នឹងសាលក្រមនេះ។ ក្នុងករណីតុលាការនៃបណ្ដឹងឧទ្ធរណ៍យល់ឃើញថា តុលាការនៃការជំនុំជម្រះលើកទី១បានធ្វើការជំនុំជម្រះលើរឿងក្ដី ដែលខ្លួនគ្មានសមត្ថកិច្ច

[60] មាត្រា ២៨០ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[61] មាត្រា ២៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដូចនេះ តុលាការនៃបណ្ដឹងឧទ្ធរណ៍នឹងលុបចោលសាលក្រមដើម ហើយផ្ទេររឿងក្ដីទៅតុលាការ ដែលមានសមត្ថកិច្ចគឺសមត្ថកិច្ចរបស់សាលាដំបូងខេត្តកំពង់ចាម។ ដោយសារនៅក្នុងរឿងក្ដីទាក់ទងនឹងឋានៈបុគ្គលនេះ សមត្ថកិច្ចជម្រះក្ដី ជាសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចលើលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល។

# ជំពូកទី ៣
# បណ្តឹងសាទុក្ខ

# ជំពូកទី ៣
# បណ្តឹងសាទុក្ខ

ក្រោយពេលដែលសាលាឧទ្ធរណ៍បានចេញនូវសេចក្តីសម្រេច (សាលដីកា) ភាគីដែលចាញ់ក្តី ដែលនៅតែមិនសុខចិត្តទៅនឹងសេចក្តីសម្រេចនោះ ភាគីមានសិទ្ធិធ្វើបណ្តឹងសាទុក្ខទៅតុលាការកំពូល ដែលជាតុលាការនៃការជំនុំជម្រះលើកចុងក្រោយ។ បណ្តឹងសាទុក្ខនេះ ក៏ត្រូវតែគោរពទៅតាមកម្មវត្ថុ និងលក្ខខណ្ឌគ្រប់គ្រាន់ប្រកបដោយមូលហេតុត្រឹមត្រូវ។ លើសពីនេះទៅទៀត ចំពោះបណ្តឹងសាទុក្ខចាំបាច់គោរពទៅតាមលំហូរនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខផងដែរ។ ដើម្បីមានភាពងាយស្រួលក្នុងការសិក្សាលើបណ្តឹងសាទុក្ខ យើងគួរគប្បីសិក្សាចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

## ផ្នែកទី១៖ សញ្ញាណទូទៅនៃបណ្តឹងសាទុក្ខ

### ១. និយមន័យ

បណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការ ដែលប្តឹងចំពោះសាលក្រម ឬសាលដីកាចុងក្រោយ ដែលទាមទារ វិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយ ចំពោះការអនុវត្តច្បាប់ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត បណ្តឹងសាទុក្ខ គឺជាប្រភេទមួយនៃបណ្តឹងឧបាស្រ័យ ដែលធ្វើទៅតុលាការជាន់ខ្ពស់និងជាបណ្តឹងដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចចុងក្រោយរបស់សាលាឧទ្ធរណ៍ ឬធ្វើឡើងប្រឆាំងនឹងសាលក្រមរបស់សាលាដំបូងរាជធានី/ខេត្តក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍។ ជាគោលការណ៍ទូទៅ បណ្តឹងសាទុក្ខ ភាគីអាចធ្វើបានចំពោះសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ ក៏ប៉ុន្តែ ក្នុងករណីពិសេសមួយទៀតដែលមានការព្រមព្រៀងស្តីពីការប្តឹងសាទុក្ខផ្លោះ [62] ទៅតុលាកំពូល និងក្នុងករណីដែលសាលាឧទ្ធរណ៍ជាតុលាការនៃការជំនុំជម្រះលើទី១។ ការជំនុំជម្រះនៃបណ្តឹងសាទុក្ខ គឺជាការជំនុំជម្រះលើអង្គច្បាប់ ដែលតុលាការកំពូលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ មិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាដើមចុងក្រោយ ក្នុងនាមតុលាការនៃបណ្តឹងសាទុក្ខហេតុដូច្នេះខុសគ្នាពីការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៅក្នុងការជំនុំជម្រះបណ្តឹងសាទុក្ខ តុលាការធ្វើការពិនិត្យមើលជាថ្មីម្តងទៀតនៅលើសាលក្រម ឬសាលដីកាដើម ដោយផ្អែកទៅលើធនធានដែលបានប្រើប្រាស់សម្រាប់វិនិច្ឆ័យនៅក្នុងសាលក្រម ឬសាលដីកានោះ។ តុលាការនៃបណ្តឹងសាទុក្ខមិនធ្វើការទទួលស្គាល់នូវអង្គហេតុឡើងវិញទេ គឺគ្រាន់តែវិនិច្ឆ័យលើអង្គច្បាប់តែប៉ុណ្ណោះ។

### ២. មូលហេតុនៃបណ្តឹងសាទុក្ខ

មូលហេតុនៃបណ្តឹងសាទុក្ខ ត្រូវបានបែងចែកជា ២ ប្រភេទគឺ៖ មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ និងមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ។

[62] មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

## ២.១. មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ

នៅប្រទេសកម្ពុជា ក្នុងករណីដែលមានរឿងក្តីពាក់ព័ន្ធនឹងអំពើអធម្មនុញ្ញភាព នោះត្រូវធ្វើបណ្តឹងទៅលើអធម្មនុញ្ញភាពទៅក្រុមប្រឹក្សាធម្មនុញ្ញ។ ការបញ្ជូនរឿងនេះ ត្រូវឆ្លងកាត់តាមតុលាការកំពូល (ប្រធានតុលាការ) ទៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយក៏អាចបញ្ជូនទៅដោយឆន្ទានុសិទ្ធិបានដែល។ ការវិនិច្ឆ័យនេះ គឺវិនិច្ឆ័យលើបញ្ហាថា តើមានភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្តិដែរឬទេ?

បណ្តឹងសាទុក្ខ អាចធ្វើបានដោយយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តិដែលមានឥទ្ធិពលលើសាលដីកា ឬសាលក្រម។[63] បើនៅក្នុងករណីដែលមានភាពផ្ទុយដូចនេះមែន តុលាការនៃបណ្តឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកាដើម។ ផ្ទុយទៅវិញ ប្រសិនបើគ្មានមូលហេតុដូចនេះទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវចោលនូវបណ្តឹងសាទុក្ខនោះ។

ក្នុងសាលដីកាចុងក្រោយនៃសាលាឧទ្ធរណ៍ជាអាទិ៍ ភាគីចាញ់ក្តីមិនអាចធ្វើបណ្តឹងបានដោយគ្រាន់តែផ្អែកលើមូលហេតុថា ខ្លួនទទួលរងនូវការខាតប្រយោជន៍ពីសាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងសាទុក្ខបានទេ។ ដើមបណ្តឹងសាទុក្ខត្រូវតែអះអាងមូលហេតុនៃបណ្តឹងសាទុក្ខថា មានភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្ត ដែលជះឥទ្ធិពលទៅដល់សាលក្រម ឬសាលដីកា។ បានសេចក្តីថា ដើម្បីប្រើប្រព័ន្ធនៃបណ្តឹងសាទុក្ខមិនគ្រាន់តែមានប្រយោជន៍ក្នុងប្តឹងឧបាស្រ័យ តែត្រូវមានមូលហេតុដូចបានចែងខាងបន្ថែមទៀតទើបជាបណ្តឹងសាទុក្ខដែលត្រូវតាមគតិច្បាប់។ ហេតុដូច្នេះ បើភាគីដែលឈ្នះក្តីទាំងស្រុងនៅការជំនុំជម្រះដើម គ្មានផលប្រយោជន៍ក្នុងការប្តឹងសាទុក្ខទេនោះ បណ្តឹងសាទុក្ខនេះនឹងត្រូវបានលើកចោលជាដាច់ខាតដោយសារបណ្តឹងនោះមានលក្ខណៈផ្ទុយច្បាប់។ ប្រសិនបើតុលាការទទួលស្គាល់ថាមានកំហុស ឬបំពានច្បាប់ ឬបទដ្ឋានគតិយុត្តិផ្សេងទៀត នៅក្នុងការចាត់ចែងនីតិវិធី ឬក្នុងការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ ហើយការធ្វើបែបនេះមានឥទ្ធិពលទៅលើការវិនិច្ឆ័យ ដែលបានបង្ហាញក្នុងសេចក្តីសម្រេចបញ្ឈប់នៃសាលដីកានោះពិតប្រាកដមែន ទើបបណ្តឹងសាទុក្ខនោះមានមូលហេតុត្រឹមត្រូវ។ ទាំងអស់នេះគេហៅថា **មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ**។ ដោយមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ យើងសង្កេតឃើញថា លក្ខខណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខ មានដូចជា៖

១. **សេចក្តីសម្រេចដើមមានលក្ខណៈអាចប្តឹងសាទុក្ខបាន៖** ត្រង់នេះចង់បង្ហាញថា ភាគីមិនសុខចិត្តមិនអាចប្តឹងសាទុក្ខចំពោះសាលក្រមរបៀប ឬចំពោះដីកាសម្រេច ដែលចេញនៅមុនពេលចេញសាលដីកា ឬសាលក្រមសម្រេចអង្គសេចក្តីដោយឯករាជ្យដាច់តែឯងទេ។ ប្រសិនបើមានការខកខានក្នុងការសម្រេច សេចក្តីនូវការទាមទារណាមួយ តុលាការត្រូវចេញសាលដីកា ឬសាលក្រមបន្ថែម។

[63] មាត្រា ២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

២. **មានការដាក់ពាក្យបណ្តឹងសាទុក្ខទៅតុលាការ៖** ប្រសិនបើ ដើមបណ្តឹងសាទុក្ខមានសេចក្តីឧបាស្រ័យចំពោះការសម្រេចសេចក្តីរបស់តុលាការដើម ការប្តឹងសាទុក្ខ ភាគីត្រូវធ្វើជាលិខិតលាយលក្ខណ៍អក្សរដាក់ទៅកាន់រដ្ឋបាលនៃតុលាការដែលមានសមត្ថកិច្ច។ ពាក្យបណ្តឹងសាទុក្ខ និងលិខិតបញ្ជាក់ពីមូលហេតុនៃបណ្តឹងសាទុក្ខ ត្រូវបានផ្ញើទៅតាមទម្រង់ស្របហើយត្រូវបានដាក់ក្នុងអំឡុងពេលដែលបានកំណត់ទៅតុលាការនៃបណ្តឹងសាទុក្ខ។ បណ្តឹងសាទុក្ខនេះ មានសុពលទៅលើការដាក់ និងបញ្ជូនពាក្យបណ្តឹងជាអាទិ៍។ ដើមបណ្តឹងសាទុក្ខមិនបានលះបង់ចោលនូវសិទ្ធិប្តឹងសាទុក្ខរបស់ខ្លួនឬមិនមានការព្រមព្រៀងថាមិនប្តឹងសាទុក្ខ។ លើសពីនេះទៀត ភាគីមិនត្រូវធ្វើបណ្តឹងសាទុក្ខត្រួតគ្នា មិនបំពានសិទ្ធិប្តឹងសាទុក្ខ និងមានលក្ខខណ្ឌនៃបណ្តឹងត្រឹមត្រូវ។

## ២.២. មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ

មូលហេតុដាច់ខាតនេះ គឺជាការសំដៅទៅដល់ការខុសនីតិវិធីធ្ងន់ធ្ងរ។[64] ប្រសិនបើពិនិត្យឃើញថាមានកំហុសធ្ងន់ធ្ងរផ្នែកនីតិវិធី នោះដើមបណ្តឹងសាទុក្ខអាចយកមូលហេតុនេះ មកធ្វើជាមូលហេតុនៃបណ្តឹងសាទុក្ខបានដោយពុំចាំបាច់បញ្ជាក់អំពីឥទ្ធិពលនៃការបំពាននោះមកលើសាលក្រម ឬសាលដីកាដែលតុលាការចេញ។ មូលហេតុដាច់ខាងនៃបណ្តឹងសាទុក្ខ ដែលផ្ទុយពីនីតិវិធីធ្ងន់ធ្ងរ មានដូចជា៖

១. **ចៅក្រមដែលចេញសាលក្រម ឬសាលដីកា មិនត្រូវបានចាត់តាំងស្របទៅតាមច្បាប់៖** ជាករណីមានបញ្ហាអំពីបញ្ហាចៅក្រមនៃក្រុមប្រឹក្សាជំនុំជម្រះ ធ្វើឡើងផ្ទុយនឹងមាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬករណីចៅក្រមមិនត្រូវបានចាត់តាំងជាចៅក្រមជំនុំជម្រះតាមច្បាប់ដូចមានចែងក្នុងមាត្រា ២៦ និងមាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីជាដើម។

២. **ចៅក្រមដែលច្បាប់មិនអនុញ្ញាត ចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាបានចូលរួម៖** តាមច្បាប់មានតែចៅក្រម ដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ ទើបអាចចេញសាលក្រម ឬសាលដីកាបានតាមការកំណត់ច្បាប់។ ក្នុងករណីដែលចៅក្រមមិនបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីជាមូលដ្ឋាននៃការចេញសាលក្រមឬសាលដីកានោះ ដើមបណ្តឹងសាទុក្ខ អាចយកបញ្ហានេះមកធ្វើជាមូលហេតុនៃការប្តឹងសាទុក្ខបាន។[65]

៣. **ភាពផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ៖** សមត្ថកិច្ចផ្តាច់មុខ គឺជាសមត្ថកិច្ចដែលកំណត់ដោយបញ្ញត្តិច្បាប់ដោយមិនទទួលស្គាល់សមត្ថកិច្ចតុលាការផ្សេង ហើយក៏មិនអនុញ្ញាតផ្តល់សមត្ថកិច្ចនេះទៅតុលាការណាមួយដោយឆន្ទៈរបស់ភាគីឡើយ។ **ឧទាហរណ៍៖** បណ្តឹងលែងលះ និង

[64] មាត្រា ២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[65] មាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

បណ្តឹងទាមទារបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃបុគ្គភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គល ដែលពាក់ព័ន្ធនឹងបណ្តឹងនោះ។

៤. **ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្តឹង៖** ជាគោលការណ៍ ជនដែលអាចក្លាយជាអ្នកតំណាងដោយអាណត្តិមានតែមេធាវីប៉ុណ្ណោះ ដោយត្រូវបង្កើតឡើងតាមរយៈការបង្ហាញឆន្ទៈរបស់ភាគី ដែលបានផ្តល់នូវសិទ្ធិក្នុងការតំណាងដោយអាណត្តិក្នុងរឿងក្តីនីមួយៗ ដោយលិខិតជាលាយល័ក្ខណ៍អក្សរដើម្បីកំណត់ឱ្យបានច្បាស់អំពីសិទ្ធិរបស់អ្នកតំណាង។ ក្នុងករណីដែលជននោះមិនមែនជាមេធាវីបានធ្វើសកម្មភាពបណ្តឹងក្នុងនាមជាអ្នកតំណាងដោយអាណត្តិ នោះគឺជាអំពើខុសច្បាប់ ហើយតុលាការត្រូវបំបាត់ចោលនូវការពាក់ព័ន្ធរបស់អ្នកនោះ។ ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៣ បានទទួលស្គាល់ជនដែលអាចជ្រើសតាំង ក្រៅពីមេធាវីឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិបានដូចជា ទី១ ករណីដែលច្បាប់ដទៃទៀត បានអនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្តឹងជំនួសភាគី។ ទី២ ករណីដែលភាគីជារដ្ឋ ស្ថាប័ននីតិរដ្ឋបាល ឬស្ថាប័នរដ្ឋដទៃទៀត និងដែលស្ថាប័ននោះ ឬអ្នកតំណាងនៃស្ថាប័ននោះតែងតាំងបុគ្គលិកនៃស្ថាប័ននោះជាអ្នកតំណាង។ ទី៣ ករណីដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជនដែលមិនមែនជាមេធាវី ក្នុងរឿងក្តីដែលតម្លៃនៃបណ្តឹងតិចជាង ១.០០០.០០០ (មួយលាន) រៀល។ ដូចនេះ ក្នុងករណីខាងលើជាមូលហេតុចាំបាច់ដាច់ខាតនៃបណ្តឹងសាទុក្ខ។

៥. **ភាពផ្ទុយនឹងបញ្ញត្តិស្តីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសារណៈ៖** ជាទូទៅ សវនាការត្រូវបើកជាសាធារណៈ ដោយអនុញ្ញាតឱ្យសាធារណជនអាចចូលរួមស្តាប់សវនាការបាន ប៉ុន្តែករណីដែលតុលាការធ្វើជាសាធារណៈនូវការទាញហេតុផល តែផ្ទុយនឹងបញ្ញត្តិមាត្រា ១១៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងថា៖ ***ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងនៅសាលសវនាការ ជាសាធារណៈ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាពជាសាធារណៈនេះបណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។*** នេះគឺជាភាពផ្ទុយច្បាប់នៃការបើកការទាញហេតុផលខាងលើ។

៦. **សាលក្រម ឬសាលដីកាគ្មានសំអាងហេតុ ឬមានសំអាងហេតុតែផ្ទុយនឹងគ្នា៖** សំអាងហេតុនៃសាលក្រម សំដៅដល់ផ្នែកមួយនៃសាលក្រម ដែលបង្ហាញអំពីយោបល់របស់ចៅក្រម ក្នុងក្របខណ្ឌនៃអង្គហេតុ ចំណុចវិវាទ និងច្បាប់ដែលត្រូវយកមកអនុវត្តក្នុងដំណើរការវិនិច្ឆ័យសេចក្តី។ ក្នុងសាលក្រម ឬ

សាលដីការបស់តុលាការដាច់ខាតត្រូវតែមានសំអាងហេតុ ហើយសំអាងហេតុនោះ ត្រូវតែស្របទៅនឹងសេចក្តីសម្រេច។ ប្រសិនបើពុំមានសំអាងហេតុ ឬសំអាងហេតុមានលក្ខណៈមិនត្រឹមត្រូវ ផ្ទុយគ្នា នោះសាលក្រម ឬសាលដីកា មិនត្រឹមត្រូវតាមច្បាប់ឡើយ។ ភាពដែលមានសំអាងហេតុផ្ទុយគ្នា គឺជាសំអាងហេតុ ដែលសរសេរខ្លឹមសារមុនក្រោយផ្ទុយគ្នា ចំពោះចំណុចសំខាន់ដែលមានឥទ្ធិពលខ្លាំងដល់សាលក្រម ឬសាលដីកា។ ឧទាហរណ៍៖ ខ្លឹមសារដែលសរសេរក្នុងសំអាងហេតុផ្ទុយគ្នានឹងចំនួនទឹកប្រាក់ដែលត្រូវបង្គាប់បង់។

### ៣. កម្មវត្ថុនៃបណ្តឹងសាទុក្ខ

កម្មវត្ថុនៃបណ្តឹងសាទុក្ខ គឺសំដៅលើសេចក្តីសម្រេច ដែលអាចប្តឹងសាទុក្ខបាន មានតែសេចក្តីសម្រេចចុងក្រោយ ដែលចេញពីសាលាដំបូង ឬសាលាឧទ្ធរណ៍ ប៉ុន្តែការចេញសេចក្តីសម្រេចនេះមិនទាន់ចូលជាស្ថាពរ។ តួយ៉ាង ក្នុងករណីពិសេស ប្រសិនបើគូភាគីមានការព្រមព្រៀងគ្នាប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូល ថាមិនធ្វើបណ្តឹងឧទ្ធរណ៍នៅក្រោយពេលដែលសាលាដំបូងចេញសាលក្រម ដោយរក្សាសិទ្ធិធ្វើបណ្តឹងសាទុក្ខ ហើយបានធ្វើជាលាយលក្ខណ៍អក្សរនោះ ភាគីអាចធ្វើបណ្តឹងសាទុក្ខទៅតុលាការកំពូលបានតែម្តងដោយមិនចាំបាច់ឆ្លងកាត់សាលាឧទ្ធរណ៍។ ចំពោះការយល់ព្រមដើម្បីផ្លោះសាលាឧទ្ធរណ៍ទៅតុលាការកំពូលនេះបាន ក្នុងករណីដែលជារឿងក្តីផ្នែករដ្ឋប្បវេណី ឬពាណិជ្ជកម្មដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥លានរៀល។ ម្យ៉ាងវិញទៀត កម្មវត្ថុដែលមិនអាចប្តឹងសាទុក្ខបានគឺប្រភេទនៃសាលក្រមរបៀប ឬដីកាសម្រេច ឬសេចក្តីសម្រេចដែលមិនមែនជាសាលក្រម ឬសាលដីកាមិនអាចយកមកធ្វើបណ្តឹងសាទុក្ខបាននោះឡើយ។ ចំពោះសាលក្រមរបៀប មិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ធ្វើបណ្តឹងសាទុក្ខដោយឯករាជ្យបានឡើយ ការប្តឹងត្រូវផ្អែកលើសាលក្រម ឬសាលដីកាចុងក្រោយ។ ប្រសិនបើគេបានប្តឹងសាទុក្ខចំពោះសាលក្រមចុងក្រោយ ឬសាលដីកាចុងក្រោយ សាលក្រមរបៀបនោះមិនក៏ជាកម្មវត្ថុនៃការវិនិច្ឆ័យជាមួយគ្នានៅតុលាការកំពូលផងដែរ។ ដូច្នេះចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី ដែលជាប់ជាមួយសាលក្រម ឬសាលដីកាចុងក្រោយក៏មិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការធ្វើបណ្តឹងសាទុក្ខដោយឯករាជ្យតែឯងបានឡើយ។

## ផ្នែកទី២៖ លក្ខខណ្ឌ និងនីតិវិធីនៃបណ្តឹងសាទុក្ខ

### ១. លក្ខខណ្ឌនៃបណ្តឹងសាទុក្ខ

ជាគោលការណ៍ ដើម្បីឱ្យបណ្តឹងមួយមានសុពលភាពទៅបាន លុះត្រាតែបណ្តឹងនោះបានធ្វើឡើងស្របទៅតាមលក្ខខណ្ឌច្បាប់ដែលនៅជាធរមាន។ ចំពោះបណ្តឹងសាទុក្ខវិញ ដើម្បីឱ្យបណ្តឹងសាទុក្ខមានសុពលភាពទៅបាន លុះត្រាតែបណ្តឹងនោះត្រឹមត្រូវទៅតាមលក្ខខណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខ។ លក្ខខណ្ឌស្របច្បាប់នៃបណ្តឹងសាទុក្ខមានលក្ខខណ្ឌនៃរយៈពេល និងសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបាន។

### ១.១. អ្នកមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ

ជាទូទៅ អ្នកដែលមានសិទ្ធិប្តឹងសាទុក្ខ គឺជាភាគីដែលមិនពេញចិត្ត និងសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង ឬសាលដីកាចុងក្រោយនៃសវនាការជំនុំជម្រះលើកទី២ របស់សាលាឧទ្ធរណ៍ ឬសាលដីកាចុងក្រោយក្នុងនាមការជំនុំជម្រះលើកទី១ របស់សាលាឧទ្ធរណ៍ដែលមិនទាន់ចូលជាស្ថាពរ។ នៅក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខត្រូវបានហៅថា ដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខ។ ត្រង់នេះមានន័យថាបណ្តឹងសាទុក្ខអាចធ្វើឡើងដោយដើមចោទ ឬចុងចម្លើយ ឬដើមបណ្តឹងឧទ្ធរណ៍ ឬចុងបណ្តឹងឧទ្ធរណ៍ និងបាត់បង់នូវផលប្រយោជន៍ដោយមានសាលក្រមនៃការជំនុះជម្រះលើកទី១ របស់សាលាដំបូង ឬសាលដីកានៃការជំនុំជម្រះលើកទី២ របស់សាលាឧទ្ធរណ៍។ ម្យ៉ាងទៀត ភាគីដែលបាត់បង់ផលប្រយោជន៍ គឺជាភាគីដែលចាញ់ក្តីទាំងស្រុង ឬមួយផ្នែក ភាគីនោះមានសិទ្ធិក្នុងការធ្វើបណ្តឹងសាទុក្ខ ហេតុនេះ ភាគីដែលឈ្នះក្តីទាំងស្រុងគ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងសាទុក្ខឡើយ។ ជានិច្ចកាល សិទ្ធិប្តឹងសាទុក្ខកើតឡើង ក្នុងករណីដែលមានការព្រមព្រៀងរវាងភាគីទាំងសងខាងជាមុនថាមិនប្តឹងឧទ្ធរណ៍ការព្រមព្រៀង មិនប្តឹងឧទ្ធរណ៍នោះគឺជាការព្រមព្រៀងផ្លោះទៅបណ្តឹងសាទុក្ខតែម្តង។ ចំពោះ ការយល់ព្រមដើម្បីផ្លោះ សាលាឧទ្ធរណ៍ទៅតុលាការកំពូលនេះអាចធ្វើបានក្នុងករណីដែលជា រឿងក្តីផ្នែករដ្ឋប្បវេណី ឬពាណិជ្ជកម្មដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥,០០០,០០០ (ប្រាំ លាន) រៀល។[66]

### ១.២. អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ

អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ គឺជាស្ថានភាពមួយ ដែលសំដៅទៅលើថេរវេលាកំណត់ក្នុងការធ្វើបណ្តឹងសាទុក្ខ។ ដើម្បីមានភាពងាយស្រួល សិក្សាលើចំណុច អំឡុងពេលនៃបណ្តឹងសាទុក្ខ យើងត្រូវពិភាក្សាលើចំណុចសំខាន់ៗដូចខាងក្រោម៖

#### ១.២.១. អំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ

នីតិវិធីបណ្តឹងសាទុក្ខ អនុវត្តដូចគ្នានឹងនីតិវិធីបណ្តឹងឧទ្ធរណ៍ ដូច្នេះអំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខក៏ដូចគ្នា គឺមានអំឡុងពេល ០១ ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូលលិខិតសាលក្រម ឬសាលដីកា ឬថ្ងៃដែលបានជូនដំណឹងអំពីការសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។[67] នៅត្រង់នេះមានន័យថាប្រសិនបើភាគីណាមួយ ដែលបានទទួលការបញ្ជូននូវលិខិតសាលក្រមរបស់សាលាដំបូង ឬសាលដីការបស់សាលាឧទ្ធរណ៍ បើភាគីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលារការជាន់ទាបនោះ ដោយមូលហេតុថាការសម្រេចនោះផ្ទុយពីច្បាប់ ឬមិនស្របតាមរដ្ឋធម្មនុញ្ញ ឬបទដ្ឋានគតិយុត្តផ្សេងទៀត ឬ

[66] មាត្រា ២៨៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[67] មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ខុសនីតិវិធីធ្ងន់ធ្ងរ ភាគីអាចមានសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេចនៅរយៈពេល ០១ ខែ។ ផ្ទុយមកវិញ ប្រសិនបើភាគីមិនបានធ្វើប្ដឹងសាទុក្ខក្នុងអំឡុងពេលដែលច្បាប់បានកំណត់នោះទេ មានន័យថា សេចក្ដីសម្រេចរបស់តុលាការជាន់ទាបបានស្ថាពរ ដែលមានអានុភាពអនុវត្ត។ កាលណាសេចក្ដីសម្រេចរបស់តុលាការជាន់ទាបចូលជាស្ថាពរ ដែលអាចមានអានុភាពហើយនោះ មានន័យថា ភាគីដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចនោះ នឹងបាត់បង់សិទ្ធិក្នុងការធ្វើបណ្ដឹងសាទុក្ខ ហើយភាគីដែលមិនសុខចិត្តនឹងសេចក្ដីនោះ នឹងបាត់បង់សិទ្ធិក្នុងការធ្វើបណ្ដឹងសាទុក្ខហើយ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលភាគីបានទទួលនូវការជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬលើកចោលនូវបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ ហើយភាគីមិនបានធ្វើការនៅក្នុងរយៈពេល ០១ ខែ ដូចដែលច្បាប់បានកំណត់នោះទេ ភាគីក៏បាត់បង់នូវសិទ្ធិធ្វើបណ្ដឹងសាទុក្ខនេះដែរ ចំពោះដីកាសម្រេចត្រង់នេះ គឺសំដៅទៅលើតែសម្រេចដែលចេញដោយសាលាដំបូង ដែលជាតុលាការនៃនីតិវិធីជំនុំជម្រះលើកទី ១ ប៉ុណ្ណោះ។ បន្ថែមពីនេះ សេចក្ដីសម្រេចនេះមិនមែនចេញដោយសាលាឧទ្ធរណ៍នោះទេ ព្រោះថាសាលាឧទ្ធរណ៍មិនអាចចេញសាលក្រមកំបាំងមុខទេ។ ក្នុងករណី អនុវត្តដូចគ្នាទៅនឹងករណីភាគីមានការព្រមព្រៀងគ្នា ជាលាយលក្ខណ៍អក្សរភាគីនឹងមិនប្ដឹងឧទ្ធរណ៍ ហើយរក្សាសិទ្ធិទុក្ខប្ដឹងសាទុក្ខ។

### ១.២.២. អំឡុងពេលនៃការដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ

ចំពោះការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ ប្រសិនបើមិនបានសរសេរនូវមូលហេតុនៃបណ្ដឹងសាទុក្ខក្នុងពាក្យបណ្ដឹងសាទុក្ខទេ ដើមបណ្ដឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខនេះ ជូនទៅតុលាការនៃបណ្ដឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបានទទួលការ បញ្ជូននូវលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ។[68] ដើមបណ្ដឹងសាទុក្ខត្រូវ សរសេរមូលហេតុនៃបណ្ដឹងសាទុក្ខនេះ ដោយបញ្ជាក់អំពីបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្ត និង ហេតុដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្តនោះ។[69] នៅក្នុងករណីនេះ ប្រសិនបើហេតុនោះមានទំនាក់ទំនងនឹងនីតិវិធីនៃបណ្ដឹង ត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ នូវអង្គហេតុដែលផ្ទុយនោះ ។

## ២. នីតិវិធីនៃបណ្ដឹងសាទុក្ខ

### ២.១. ការទទួលពាក្យបណ្ដឹងសាទុក្ខ

ដើម្បីប្ដឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្ដឹងសាទុក្ខទៅតុលាការដើម។ នៅក្នុងករណីនេះ តុលាការដើមត្រូវផ្ញើឱ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងសាទុក្ខ និងសំណុំរឿងទៅតុលាការនៃបណ្ដឹងសាទុក្ខ។[70]

[68] មាត្រា ២៨៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[69] មាត្រា ២៨៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[70] មាត្រា ២៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដើម្បីធ្វើបណ្ដឹងសាទុក្ខភាគីដែលមិនសុខចិត្តនឹងសាលក្រម ឬសាលដីកាដែលតុលាការ បានចេញនោះ ត្រូវសរសេរពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរ ហើយត្រូវយកពាក្យបណ្ដឹងសាទុក្ខ នោះទៅដាក់នៅតុលាការ ដែលបានចេញសាលក្រម ឬសាលដីកានោះ ក្នុងអំឡុងពេលកំណត់សម្រាប់ធ្វើបណ្ដឹងសាទុក្ខ។ បន្ទាប់មក តុលាការដើមត្រូវធ្វើការផ្ញើឱ្យបានឆាប់រហ័សនូវពាក្យបណ្ដឹងសាទុក្ខនោះ និងសំណុំរឿងទៅតុលាការនៃបណ្ដឹង សាទុក្ខ។

### ២.២. ការពិនិត្យពាក្យបណ្ដឹង

នៅក្រោយពេលដែលបានទទួលពាក្យបណ្ដឹងសាទុក្ខពីតុលាការដើម តុលាការនៃបណ្ដឹងសាទុក្ខត្រូវធ្វើ ការត្រួតពិនិត្យពាក្យបណ្ដឹងនោះ។ ក្នុងករណីដែលពិនិត្យឃើញថាពាក្យបណ្ដឹងនោះ មិនបានសរសេរនូវចំណុច ដែលត្រូវសរសេរ ដែលបានរៀបរាប់ខាងលើនេះទេ តុលាការនៃបណ្ដឹង សាទុក្ខត្រូវកំណត់អំឡុងពេលសមរម្យ មួយ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនោះ។ ប្រសិនបើ ដើមបណ្ដឹងសាទុក្ខមិនបានកែតម្រូវចំណុចខ្វះខាត នោះក្នុងរយៈពេលកំណត់ទេ តុលាការនៃបណ្ដឹងសាទុក្ខត្រូវលើកចោលពាក្យបណ្ដឹងសាទុក្ខនោះ ដោយអំណាច នៃដីកាសម្រេច។

### ២.៣. ការបញ្ជូនពាក្យបណ្ដឹងសាទុក្ខ

ប្រសិនបើ ពាក្យបណ្ដឹងសាទុក្ខត្រឹមត្រូវតាមទម្រង់ច្បាប់ តុលាការត្រូវបញ្ជូនពាក្យបណ្ដឹងសាទុក្ខទីឱ្យចុង បណ្ដឹងសាទុក្ខ។ ក្នុងករណីដែលមិនអាចបញ្ជូនពាក្យបណ្ដឹងសាទុក្ខ ត្រូវអនុលោមតាមករណីដែលពាក្យបណ្ដឹង សាទុក្ខ មិនត្រឹមត្រូវតាមទម្រង់ច្បាប់។[71] ការបញ្ជូន គឺជាការជូនដំណឹងអំពីដំណើរការក្នុងការដោះស្រាយវិវាទរដ្ឋ ប្បវេណី ដែលការជូនដំណឹងនេះ មានដូចជា ដីកាកោះ លិខិតអញ្ជើញ និងសេចក្ដីសម្រេច របស់តុលាការទៅ ភាគីវិវាទ ដោយអនុវត្តស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី។ ដើម្បីធ្វើការបញ្ជូនត្រឹមត្រូវតាមច្បាប់ លុះត្រាតែវិធីនៃការ បញ្ជូននោះធ្វើឡើងស្របទៅតាមច្បាប់។ នៅក្នុងបញ្ញត្តិច្បាប់ វិធីនៃការបញ្ជូនមាន ៣ របៀបសំខាន់ៗ គឺ ការប ញ្ជូនដោយប្រគល់ ការបញ្ជូនទៅបរទេស និងការបញ្ជូនតាមការផ្សាយជាសាធារណៈ។

### ២.៤. ការកំណត់កាលបរិច្ឆេទនីតិវិធីទាញហេតុផលផ្ទាល់មាត់

នៅក្រោយពេលដែលបានទទួលពាក្យបណ្ដឹងសាទុក្ខ និងពិនិត្យឃើញថាបណ្ដឹងនោះធ្វើឡើងត្រឹមត្រូវ ហើយតុលាការនៃបណ្ដឹងសាទុក្ខ ត្រូវធ្វើការកំណត់នូវកាលបរិច្ឆេទសម្រាប់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់ មាត់ឱ្យបានឆាប់រហ័ស និងធ្វើការកោះហៅគូភាគីឱ្យចូលរួម ។ គួរបញ្ជាក់ ផងដែរថាបណ្ដឹងសាទុក្ខធ្វើឡើងដោយ ផ្អែកលើមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬសាល ក្រម និងអនិយតភាពនៃនីតិវិធីប៉ុណ្ណោះ ដូច្នេះតុលាការធ្វើការវិនិច្ឆ័យតែទៅលើអង្គច្បាប់ប៉ុណ្ណោះ ហេតុនេះ

[71] មាត្រា ២៦៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

តុលាការមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីរៀបចំនូវសេចក្ដីអះអាងរបស់ភាគីកំណត់ចំណុចវិវាទ និងរៀបចំភស្តុតាងទេ ព្រោះនីតិវិធីនេះបានធ្វើនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១ រួចហើយ។ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់តែម្ដង។ នៅក្រោយពេល ដែលបានកំណត់កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចរាល់ តុលាការត្រូវធ្វើការបញ្ជូនដីកាកោះទៅភាគីដើម្បីឱ្យភាគីចូលរួមក្នុងនីតិវិធី។ ការបញ្ជូនដីកាកោះអាចធ្វើការបញ្ជូន ទៅភាគីជាមួយគ្នានឹងលិខិតទទួលពាក្យបណ្ដឹង លើកលែងតែករណីដែលតុលាការលើកចោលពាក្យបណ្ដឹងសាទុក្ខនោះ ឬតុលាការបង្គាប់ឱ្យដើមបណ្ដឹងសាទុក្ខដាក់លិខិតបញ្ជាក់អំពីមូលហេតុ នៃបណ្ដឹងសាទុក្ខ ឬមួយតុលាការចេញដីកាបង្គាប់ឱ្យកែតម្រូវជាដើម។

## ផ្នែកទី៣ ៖ អានុភាពនៃពាក្យបណ្ដឹងសាទុក្ខ

នៅក្រោយពេលដែល ពាក្យបណ្ដឹងសាទុក្ខត្រូវបានដាក់ទៅដល់តុលាការកំពូលនោះ វានឹងបង្កើតឱ្យមាននូវអានុភាព៖ ទី១ បង្អាក់នូវការចូលជាស្ថាពរនៃសាលដីកា ឬសាលក្រមរបស់តុលាការដើម ទី២ អនុភាពនៃការផ្ទេរការជម្រះក្ដី និងទី៣ អានុភាពអវិភាគនៃបណ្ដឹងសាទុក្ខ។

### ១. អានុភាពបង្អាក់ការចូលជាស្ថាពរ

នៅក្រោយពេលដែលបណ្ដឹងសាទុក្ខត្រូវបានធ្វើឡើងត្រឹមត្រូវតាមអំឡុងពេលកំណត់ច្បាប់ នោះវានឹងរារាំងអានុភាពនៃការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា។ មានន័យថានៅពេលដែលដើមបណ្ដឹងសាទុក្ខបានធ្វើបណ្ដឹងក្នុងអំឡុងពេលមួយខែបន្ទាប់ពីបានទទួលលិខិតសាលក្រម ឬសាលដីកា ទោះបីជារយៈពេលនៃការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកាបានចូលមកដល់ ឬបានកន្លងផុតក៏ដោយក៏សាលក្រម ឬសាលដីកានោះមិនអាចចូលជាស្ថាពរដែរ។

### ២. អានុភាពនៃការផ្ទេរការជំនុំជម្រះក្ដី

នៅពេលដែលមានពាក្យបណ្ដឹងសាទុក្ខ នោះការជំនុំជម្រះដោយតុលាការថ្នាក់ក្រោម (សាលាដំបូង ឬសាលាឧទ្ធរណ៍) នឹងត្រូវផ្ទេរទៅតុលាការនៃបណ្ដឹងសាទុក្ខជាអ្នកមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យនិងចេញសេចក្ដីសម្រេច។

### ៣. អានុភាពអវិភាគនបណ្ដឹងសាទុក្ខ

ទោះបីជាដើមបណ្ដឹងសាទុក្ខបានធ្វើឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រម ឬសាលដីកាដើមក៏ដោយក៏បណ្ដឹងនោះមានអានុភាពបង្អាក់ការចូលជាស្ថាពរ និងមានការផ្ទេរការជំនុំជម្រះត្រូវកើតមានឡើងទៅលើការទាមទារទាំងអស់ដែលមាននៅក្នុងសាលក្រម ឬសាលដីកានោះ ។ នេះគេហៅថាភាពអវិភាគនៃបណ្ដឹងសាទុក្ខបានសេចក្ដីថាទោះបីជាដើមបណ្ដឹងសាទុក្ខធ្វើបណ្ដឹងតែមួយផ្នែកនៅក្នុងសាលក្រម ឬសាលដីកាដើមក៏ផ្នែកដែលមិនបានធ្វើឧបាស្រ័យមិនអាចចូលជាស្ថាពរហើយក៏មិនអាចយកទៅអនុវត្តបានឡើយ។

# ផ្នែកទី៤៖ បណ្តឹងសាទុក្ខផ្លោះ និងការជំនុំជម្រះនៃបណ្តឹងសាទុក្ខ

## ១. បណ្តឹងសាទុក្ខផ្លោះ

ចំពោះសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី១ នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍នៅក្រោយពេល ដែលតុលាការបានចេញសាលក្រមនោះ ដោយរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ បណ្តឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលដោយផ្ទាល់បាន។[72]

បណ្តឹងសាទុក្ខផ្លោះ អាចធ្វើចំពោះសាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដែលបានកំណត់ខាងក្រោមនេះ៖

- គូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកសិទ្ធិប្តឹងសាទុក្ខ ក្រោយពេលតុលាការបានចេញសាលក្រមចុងក្រោយ។
- សេចក្តីព្រមព្រៀងដែលបានកំណត់ក្នុងចំណុច ក នៃកថាខណ្ឌទី១ ខាងលើនេះ ពុំមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើលិខិតជាលាយល័ក្ខណ៍អក្សរ។[73]

ចំពោះការតាក់តែងលិខិតព្រមព្រៀងនេះ ភាគីត្រូវប្រុងប្រយ័ត្ននូវចំណុចមួយចំនួន រួមមាន៖

- ការព្រមព្រៀងជាលាយល័ក្ខណ៍អក្សរ នៅក្រោយពេលតុលាការចេញសាលក្រមចុងក្រោយ
- គូរភាគីរក្សាទុកនូវសិទ្ធិប្តឹងសាទុក្ខ (មិនមានវិវាទអំពីការទទួលស្គាល់អង្គហេតុនៅក្នុងសាលក្រមជំនុំជម្រះលើកទី១)
- ទាមទារឲ្យសម្រេចក្នុងការវិនិច្ឆ័យបណ្តឹងសាទុក្ខអំពីបញ្ហាផ្លូវច្បាប់ ដោយរំលងការវិនិច្ឆ័យបណ្តឹងឧទ្ធរណ៍។
- ចំណុចដែលអាចស្រាវជ្រាវដោយឆន្ទានុសិទ្ធិចំពោះការវិនិច្ឆ័យបណ្តឹងសាទុក្ខ។[74]

## ២. ការជំនុំជម្រះនៃបណ្តឹងសាទុក្ខ

គោលការណ៍នៃបណ្តឹងសាទុក្ខទៅតុលាការកំពូល គឺត្រូវបានគ្រប់គ្រងដោយរចនាសម្ព័ន្ធ និងនីតិវិធីដែលមានចែងនៅក្នុងប្រព័ន្ធតុលាការ។ អង្គជំនុំជម្រះតុលាការកំពូល មានតួនាទីជាស្ថាប័នបណ្តឹងជាន់ខ្ពស់បំផុតក្នុងប្រទេស។ នៅពេលដែលសំណុំរឿងមួយត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះតុលាការកំពូល វាឆ្លងកាត់ការត្រួតពិនិត្យយ៉ាងម៉ត់ចត់លើបញ្ហាផ្លូវច្បាប់ និងភស្តុតាងដែលបានបង្ហាញក្នុងអំឡុងពេលសវនាការ។ ចៅក្រមសាលាឧទ្ធរណ៍វាយតម្លៃថាតើមានកំហុសក្នុងការអនុវត្តច្បាប់ ឬភាពមិនប្រក្រតីនៃនីតិវិធី ដែលអាចប៉ះពាល់ដល់លទ្ធផលនៃសំណុំរឿងនៅថ្នាក់ក្រោម។ គោលការណ៍នៃបណ្តឹងសាទុក្ខរបស់តុលាការកំពូលក្នុងប្រទេសកម្ពុជា

[72] មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[73] មាត្រា ២៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[74] មាត្រា ២៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

រក្សានូវគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ និងការប្រកាន់ខ្ជាប់នូវនីតិរដ្ឋ។ វាផ្តល់ឱ្យភាគីវិវាទនូវឱកាសមួយ ដើម្បីស្វែងរកការដោះស្រាយ ប្រសិនបើពួកគេជឿថាកំហុសត្រូវបានធ្វើឡើងនៅក្នុងការជំនុំជម្រះដំបូងរបស់ពួកគេ ឬប្រសិនបើពួកគេមានអារម្មណ៍ថាសិទ្ធិរបស់ពួកគេមិនត្រូវបានធានាត្រឹមត្រូវ។

### ២.១. គោលការណ៍នៃការជំនុំជម្រះបណ្តឹងសាទុក្ខ

ជាគោលការណ៍ ដើម្បីធ្វើការវិនិច្ឆ័យ និងចេញសាលដីកានៃបណ្តឹងសាទុក្ខតុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីដែលតុលាការច្រានចោលបណ្តឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់។[75] ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងត្រឹមទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្តូរនៅក្នុងសាលក្រម ឬសាលដីកានៃតុលាការដើមតែប៉ុណ្ណោះ។[76]

ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើបន្តទៅលើចំណុចណាដែលបានធ្វើការឧបាស្រ័យតែប៉ុណ្ណោះ ចំពោះចំណុចណា ដែលភាគីមិនបានធ្វើឧប្រាស្រ័យតុលាការមិនអាចយកមកធ្វើការវិនិច្ឆ័យឡើយ។ ការកំណត់បែបនេះ គឺទាញចេញពីគោលការណ៍ហាមឃាត់មិន ឱ្យផ្លាស់ប្តូរដែលធ្វើឱ្យខូចប្រយោជន៍ភាគី។ មានន័យថាការផ្លាស់ប្តូរសាលក្រម ឬសាលដីការបស់តុលាការដើមអាចធ្វើបានត្រឹមតែកម្រិត ដែលបានធ្វើឧបាស្រ័យបណ្តឹងសាទុក្ខតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមានពាក្យបណ្តឹងសាទុក្ខបន្ទាប់បន្សំ ការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងសាទុក្ខក៏ត្រូវប្រែប្រួលតាមការទាមទារនោះដែរ។

### ២.២. ការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី១

ដើម្បីចេញសាលក្រម ឬសាលដីកាទៅលើបណ្តឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់។ ការទាញហេតុផលដោយផ្ទាល់មាត់លើកទី១ សំដៅទៅលើការទទួលពាក្យបណ្តឹងសាទុក្ខរបស់ភាគីដើមបណ្តឹងសាទុក្ខយកមកវិនិច្ឆ័យ។ ដើម្បីធ្វើការវិនិច្ឆ័យ និងចេញសាលដីកានៃបណ្តឹងសាទុក្ខតុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីដែលតុលាការច្រានចោលបណ្តឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងត្រឹមទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្តូរនៅក្នុងសាលក្រម ឬសាលដីកានៃតុលាការដើមតែប៉ុណ្ណោះ។ ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើតែទៅលើចំណុចណា ដែលបានធ្វើឧបាស្រ័យតែប៉ុណ្ណោះ ចំពោះចំណុចណា ដែលភាគីមិនបានធ្វើឧប្រាស្រ័យតុលាការមិនអាចយកមកធ្វើការវិនិច្ឆ័យឡើយ។ ការកំណត់បែបនេះ គឺទាញចេញពីគោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្តូរដែលធ្វើខូចប្រយោជន៍ មានន័យថាការផ្លាស់ប្តូរសាលក្រម ឬសាលដីការបស់តុលាការដើមអាចធ្វើបានត្រឹមតែកម្រិត ដែលបានធ្វើឧបាស្រ័យបណ្តឹងសាទុក្ខតែប៉ុណ្ណោះ។ ប៉ុន្តែ ប្រសិនបើមានពាក្យ

[75] មាត្រា ២៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[76] មាត្រា ២៧២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

បណ្តឹងសាទុក្ខបន្ទាប់បន្សំ ការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងសាទុក្ខក៏ត្រូវប្រែប្រួលតាមការទាមទារនោះដែរ។ តុលាការមិនត្រូវធ្វើការវិនិច្ឆ័យទៅលើចំណុចណាដែលភាគីមិនបានទាមទារឡើយ។

សភារដ្ឋប្បវេណីនៃតុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ចំពោះសាលដីកាផ្នែករដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ឬសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង។ ការជំនុំជម្រះក្តី ត្រូវធ្វើឡើងដោយមានចៅក្រមចំនួន ០៥(ប្រាំ) រូប ក្នុងនោះមានចៅក្រម ០១(មួយ) រូប ត្រូវបានចាត់ តាំងឱ្យធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះដើម្បីធ្វើជាអ្នកដឹកនាំកិច្ចដំណើរការនៃនីតិវិធី។ [77]

## ២.៣. ការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី២

ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខ បានបដិសេធនូវសាលក្រមដើមហើយបានបញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ ឬផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា ដើម្បីឱ្យធ្វើការជំនុំជម្រះរឿងក្តីនោះម្តងទៀត បន្ទាប់មកនៅពេលដែលតុលាការដើមដែលទទួលការបញ្ជូនរឿងក្តីត្រឡប់មកវិញ ឬតុលាការដែលបានទទួលការផ្ទេររឿងក្តីនោះបានចេញសាលដីកា ហើយបើភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ ហើយបានប្តឹងសាទុក្ខម្តងទៀត ពេលនោះនីតិវិធីតុលាការនៃបណ្តឹងសាទុក្ខនឹងធ្វើការជំនុំជម្រះដោយសភាពេញអង្គ។ សភាពេញអង្គ ត្រូវបង្កើតឱ្យមានដំណើរការដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូលដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទីពីរ និងបណ្តឹងជំនុំជម្រះសាជាថ្មី ក្នុងករណីដែលមានការស្នើសុំឱ្យមានការពិនិត្យនិងសម្រេចឡើងវិញចំពោះរឿងក្តីណាមួយពីព្រះមហាក្សត្រ ដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញ របស់ប្រធានតុលាការកំពូលសភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩(ប្រាំបួន) រូប ដែលមានចៅក្រមជាតំណាងនៃសភាទាំងអស់នៃតុលាការកំពូល [78] ហើយសភាពេញអង្គនឹងត្រូវដំណើរការ ក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល។ សកម្មភាពទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងករណីបណ្តឹងសាទុក្ខលើកទី ២ នេះ គឺធ្វើទៅតាមលំដាប់លំដោយដូចគ្នានឹងសកម្មភាពទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងបណ្តឹងសាទុក្ខលើកដំបូងដែរ ប៉ុន្តែអាចមានសាក្សី និងអ្នកជំនាញចូលរួមក្នុងសវនាការដែរ ដោយប្រធានក្រុមប្រឹក្សា អាចអញ្ជើញសាក្សី និងអ្នកជំនាញនោះមកឈរមុខតុលាការ ដើម្បីឱ្យអ្នកទាំងនោះជួយបំភ្លឺដល់រឿងក្តី ដើម្បីឱ្យតុលាការងាយស្រួលក្នុងការវិនិច្ឆ័យ និងចេញសាលដីកា។ ករណីមានបន្ថែមសាក្សី និងអ្នកជំនាញនេះដោយសារតែបណ្តឹងសាទុក្ខលើកទីពីរនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការពិនិត្យឡើងវិញទាំងអង្គហេតុ និងអង្គច្បាប់។ តុលាការអាចសាកសួរជនណាមួយជាសាក្សីក៏បានឱ្យចូលខ្លួនទៅតុលាការ ដើម្បីឆ្លើយជាកសិណសាក្សីនៅពេលដែលតុលាការកោះហៅ។ [79]

---

[77] មាត្រា៥៩ និងមាត្រា៦៥ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

[78] មាត្រា៦២ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

[79] មាត្រា ១៣២ កថាខណ្ឌទី១ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ២០០៧

សាក្សី គឺជាតតិយជនដែលបានឃើញហេតុការណ៍វិវាទរបស់គូភាគីនៃបណ្ដឹង។ គោលដៅចម្បងនៃការសួរសាក្សី គឺដើម្បីឲ្យសាក្សីធ្វើសេចក្ដីថ្លែងការណ៍នូវអង្គហេតុពិតដែលខ្លួនបានដឹងតាមរយៈការពិសោធន៍របស់ខ្លួននៅចំពោះមុខតុលាការ ហើយចម្លើយរបស់សាក្សី គឺជាភស្តុតាង។

## ផ្នែកទី៥៖ ការបញ្ចប់បណ្ដឹងសាទុក្ខ

នៅក្នុងប្រព័ន្ធតុលាការ គេសង្កេតឃើញជាញឹកញាប់ថា ខណៈពេលដែលដើមបណ្ដឹងបន្តបណ្ដឹងដោយចេតនាពិតប្រាកដក្នុងការស្វែងរកយុត្តិធម៌ អ្នកផ្សេងទៀតអាចរៀបចំដំណើរការនេះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍ជាយុទ្ធសាស្ត្រ។ បាតុភូតនេះគឺស្រដៀងទៅនឹងការបង្ហាញពីការបោកបញ្ឆោតផ្នែកនយោបាយនៅក្នុងអក្សរសិល្ប៍ ដែលជួនកាលស្នេហាជាតិពិតប្រាកដត្រូវបានគ្របដណ្ដប់ដោយចេតនាទុច្ចរិត។ ការបញ្ចប់បណ្ដឹងនៅក្នុងតុលាការ ស្រដៀងគ្នានេះ អាចឆ្លុះបញ្ចាំងពីអន្តរកម្មដ៏ស្មុគស្មាញនៃការលើកទឹកចិត្ត និងកាលៈទេសៈ ដូចដែលមាននៅក្នុងទិដ្ឋភាពតុលាការ។ តើកត្តាអ្វីខ្លះដែលឈានដល់ការបញ្ចប់បណ្ដឹងនៅតុលាការ?

### ១. ការបញ្ចប់បណ្ដឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ

ការបញ្ចប់បណ្ដឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្ដីសម្រេចរបស់តុលាការ នេះអាចកើតមានក្នុងរូបភាពជាច្រើន ដូចជា៖

#### ១.១. ការបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តិ

ក្នុងករណីដែលនីតិវិធីបណ្ដឹងសាទុក្ខកំពុងដំណើរការ ហើយភាគីណាមួយបានទទួលមរណភាព ដោយគ្មានអ្នកទទួលសិទ្ធិបន្ត ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងនោះ បណ្ដឹងសាទុក្ខនឹងត្រូវបានបញ្ចប់។ តាមធម្មតាប្រសិនបើទោះបីជាមានភាគីណាម្ខាងបានទទួលមរណភាពក៏ដោយ ក៏សន្តតិជនរបស់ភាគីនោះនឹងត្រូវទទួលបន្តនូវនីតិវិធីនៃបណ្ដឹងដែលបានធ្វើពីមុនមក ហើយនីតិវិធីបណ្ដឹងសាទុក្ខនោះមិនត្រូវបានបញ្ចប់ទេ ប៉ុន្តែបើមានករណីដែលភាគី ដែលបានទទួលមរណភាពនោះពុំមានអ្នកត្រូវទទួលបន្តនូវនីតិវិធីនៃបណ្ដឹងដោយសារសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុបណ្ដឹង តុលាការកំពូលនឹងចេញសាលដីកាបញ្ចប់បណ្ដឹងនោះដោយស្វ័យប្រវត្តដោយមានខ្លឹមសារថាបណ្ដឹងសាទុក្ខត្រូវបានបញ្ចប់ដោយសារមរណភាពរបស់ភាគី។ នៅក្នុងករណី សិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងបានរលត់ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គលនាំឱ្យសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងត្រូវធ្លាក់លើបុគ្គលតែម្នាក់ ហើយដើមបណ្ដឹងសាទុក្ខ និងចុងបណ្ដឹងសាទុក្ខបានក្លាយទៅជាបុគ្គលតែមួយដោយសារតែភាគីណាម្ខាងបានទទួលបន្តនូវឋានៈ តាមផ្លូវបណ្ដឹងរបស់ភាគីម្ខាងទៀត ដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គល ឬដោយសន្តតិកម្ម។ ករណីនេះតុលាកាកំពូលនឹងចេញសាលដីកាបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តដោយសារតែមានភាគីជាបុគ្គលតែមួយ។ ***ឧទាហរណ៍:*** ភាគីមួយបាន ប្ដឹងលែងលះភាគីម្ខាងទៀត ករណីនេះបើភាគីណាមួយស្លាប់ គឺបញ្ចប់បណ្ដឹងហើយ។ ករណីមួយទៀត គោលការណ៍នៃបណ្ដឹងគឺឆន្ទៈរបស់

ភាគីក្នុងការដកបណ្តឹង។ ***ឧទាហរណ៍:*** ឪពុកប្តឹងកូនដែលជំពាក់ប្រាក់ ១០០ដុល្លារ ពេលដែលដាក់ពាក្យប្តឹង ឪពុកស្លាប់ ករណីនេះ គឺការបញ្ចប់បណ្តឹង ដោយស្វ័យប្រវត្តិ ដោយសារឋានៈនៅក្នុងបណ្តឹង គឺព្យាកុលភាព (ម្ចាស់បំណុល និងកូនបំណុលតមួយ ។

### ១.២. ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី

ការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់ភាគី ក្នុងនេះអាចជាសកម្មភាពរួមមាន៖

១. **ការដកពាក្យបណ្តឹង៖** ដើមបណ្តឹងសាទុក្ខអាចធ្វើការដកពាក្យបណ្តឹងទាំងអស់ ឬមួយផ្នែកបានដែរ រហូតដល់ពេលដែលតុលាការនៃបណ្តឹងសាទុក្ខចេញសាលដីកាចុងក្រោយ។ ដោយហេតុថាបណ្តឹងជាសកម្មភាពរបស់ដើមបណ្តឹងសាទុក្ខ ក្នុងការទាមទារឱ្យតុលាការនៃបណ្តឹងសាទុក្ខចេញសេចក្តីសម្រេចលុបចោល ឬ កែប្រែសាលដីកាដើម ឬសាលក្រមដើម។ ដូច្នេះការដកពាក្យបណ្តឹង សាទុក្ខធ្វើឡើងតាមឆន្ទៈរបស់ដើមបណ្តឹងសាទុក្ខប៉ុណ្ណោះ ហេតុនេះចុងបណ្តឹងសាទុក្ខពុំមានសិទ្ធិដកពាក្យបណ្តឹងទេ។

២. **ការលះបង់ ឬ ការទទួលស្គាល់៖** ការលះបង់ ឬទទួលស្គាល់នូវការទាមទារជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងដែលភាគីម្ខាងទទួលស្គាល់ពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារ ហើយវិវាទរវាងភាគីទាំងសងខាងត្រូវបានដោះស្រាយ ដោយសេចក្តីថ្លែងការណ៍នេះ សកម្មភាពទាំងនេះនាំឱ្យបណ្តឹងត្រូវបានបញ្ចប់ដោយមិនចាំបាច់រងចាំសាលដីកាទ។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់ក្នុងការទទួលស្គាល់នូវការទាមទារ ភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង។

៣. **ការសះជាតាមផ្លូវបណ្តឹង៖** ជាសកម្មភាពមួយ ដែលដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខធ្វើការសម្រុះសម្រួលគ្នាបញ្ចប់នូវនីតិវិធីបណ្តឹងសាទុក្ខ ដោយត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការនៃបណ្តឹងសាទុក្ខនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះល័ក្ខខ័ណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្តឹងក៏ភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងសាទុក្ខ ដូច្នេះបើមានភាគីណាមួយជាបុគ្គល ដែលត្រូវបានកម្រិតសមត្ថភាពបានធ្វើការសះជានោះពុំមានអានុភាពឡើយ។

## ២. ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

### ២.១. ការលើកចោលនូវបណ្តឹងសាទុក្ខដោយដីកាសម្រេច

បណ្តឹងសាទុក្ខនឹងត្រូវតុលាការលើកចោល ដោយដីកាសម្រេច ប្រសិនបើបណ្តឹងសាទុក្ខនោះធ្វើឡើងមិនសមស្របច្បាប់ និងមិនអាចកែតម្រូវបានដូចជា៖

- ភាគីខ្វះសមត្ថភាពធ្វើបណ្តឹង
- បណ្តឹងធ្វើឡើងហួសអំឡុងពេលដែលកំណត់ដោយច្បាប់

- ដើមបណ្ដឹងមិនបានដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ
- មិនបានកែតម្រូវតាមដីកាសម្រេចឱ្យកែតម្រូវនូវលិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ។

### ២.២. សាលដីកាច្រានចោលបណ្ដឹងសាទុក្ខ

ការជំនុំជម្រះបណ្ដឹងសាទុក្ខ គឺតុលាការធ្វើការវិនិច្ឆ័យតែទៅលើអង្គច្បាប់តែប៉ុណ្ណោះ ហេតុនេះហើយ តុលាការអាចសម្រេចច្រានចោលបណ្ដឹងសាទុក្ខបាន ដោយគ្រាន់តែពិនិត្យមើលឯកសារជាលាយល័ក្ខណ៍អក្សរ ក៏ជាការគ្រប់គ្រាន់។ ប្រសិនបើក្រោយពីបានពិនិត្យពាក្យបណ្ដឹងសាទុក្ខ ឬ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ឬមួយឯកសារត្រៀមដែលចុងបណ្ដឹងសាទុក្ខបានដាក់លើកដំបូង ឬឯកសាផ្សេងទៀត ហើយពិនិត្យឃើញថា បណ្ដឹងសាទុក្ខនោះធ្វើឡើងដោយមិនសំអាងលើមូលហេតុទូទៅនៃបណ្ដឹងសាទុក្ខ ឬមូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ ដើម្បីធ្វើបណ្ដឹងសាទុក្ខទេ តុលាការអាចច្រានចោលបណ្ដឹងនោះដោយសាលដីកា ដោយមិនចាំបាច់ឆ្លងកាត់ការ ទាញហេតុផលដោយផ្ទាល់មាត់ក៏បាន។ ប៉ុន្តែ ប្រសិនបើតុលាការនៃបណ្ដឹងសាទុក្ខបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយពិនិត្យឃើញថា បណ្ដឹងនោះមិនមានមូលហេតុទូទៅ ឬមូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ ឬមួយពិនិត្យឃើញថាសំអាងហេតុនៅក្នុងសាលក្រម ឬសាលដីកា របស់តុលាការដើមមិនត្រឹមត្រូវក៏ដោយក៏តុលាការនៃបណ្ដឹងសាទុក្ខត្រូវច្រានចោលនូវបណ្ដឹងសាទុក្ខ នោះដែរបើយល់ឃើញថា សេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ឬសាលដីកានោះត្រឹមត្រូវដោយផ្អែកលើសំអាងហេតុផ្សេងទៀត។

### ២.៣. សាលដីកាទទួលស្គាល់បណ្ដឹងសាទុក្ខ

កាលណា តុលាការកំពូល ទទួលស្គាល់បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងចាត់ទុកថា មានភាពត្រឹមត្រូវ នោះតុលាការត្រូវបដិសេធចោលនូវសាលក្រម ឬសាលដីការបស់តុលាការដើម ហើយតុលាការត្រូវបញ្ជូនរឿងនោះត្រឡប់ទៅតុលាការដើមវិញ ឬផ្ទេររឿងក្ដីនោះទៅតុលាការផ្សេងទៀត ដែលមានថ្នាក់ដូចគ្នាមកវិនិច្ឆ័យដោយខ្លួនឯង។

#### ២.៣.១. ការបដិសេធចោល និងបញ្ជូនត្រឡប់ទៅតុលាការដើម

ក្នុងករណីដែលតុលាការនៃបណ្ដឹងសាទុក្ខទទួលស្គាល់ថា ពាក្យបណ្ដឹងសាទុក្ខនោះមានមូលហេតុត្រឹមត្រូវ (មូលហេតុទូទៅ ឬមូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ) តុលាការនៃបណ្ដឹងសាទុក្ខត្រូវបដិសេធចោលនូវសាលដីកា ឬសាលក្រមដើមហើយត្រូវបញ្ជូនរឿងក្ដីនោះត្រឡប់ទៅតុលាការដើមវិញ។ តុលាការនោះត្រូវតែជាតុលាការដែលមានថ្នាក់ដូចគ្នា។ [80] តុលាការដែលបានទទួលរឿងក្ដីដោយការបញ្ជូនត្រឡប់មកវិញ ត្រូវធ្វើការសម្រេចសេចក្ដី ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីម្ដងទៀត។ ចំនួនចៅក្រម និងសមាសភាពចៅក្រមនៃតុលាការដែលទទួលការបញ្ជូនត្រឡប់មកវិញត្រូវមានការផ្លាស់ប្ដូរ។ ករណីដែលបញ្ជូន

[80] មាត្រា ២៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

សាលដីការបស់សាលាឧទ្ធរណ៍ត្រឡប់មកវិញ ការជំនុំជម្រះលើកទី២ របស់សាលាឧទ្ធរណ៍នេះ ត្រូវធ្វើឡើងដោយមានចៅក្រម ០៥(ប្រាំ) រូប ហើយត្រូវតែជាចៅក្រមដែលមិនបានចូល រួមជំនុំជម្រះលើកមុន។ ករណីការបញ្ជូនសាលក្រមត្រឡប់មកសាលដំបូងវិញ ទោះបីជាការជំនុំជម្រះលើកមុនត្រូវបានធ្វើឡើងដោយចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមក្តី ក៏ចំនួនចៅក្រមនៃការជំនុំជម្រះលើកទី២ មិនមានការផ្លាស់ប្តូរដែរ ប៉ុន្តែមិនមែនជាចៅក្រមដែលបានចូលរួមជំនុំជម្រះលើកមុនឡើយ។ ចំពោះសេចក្តីវិនិច្ឆ័យលើអង្គហេតុ និងអង្គច្បាប់ដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធចោលសាលក្រម ឬសាលដីការបស់តុលាការដើម ត្រូវមានចំណងទៅលើតុលាកា រដែលបានទទួលការបញ្ជូន ឬការផ្ទេរអានុភាពចងនៃសេចក្តី។ វិនិច្ឆ័យលើអង្គច្បាប់ គឺតុលាការដែលបានទទួលការបញ្ជូន ឬការផ្ទេរនោះមិនអាចធ្វើសេចក្តីវិនិច្ឆ័យអំពីចំណុចដែលពាក់ព័ន្ធនឹងអង្គច្បាប់ ដែលមាននៅក្នុងសាលដីកាដើម ឬសាលក្រមដើមបានទេដោយសារវាបានក្លាយទៅជាមូលហេតុនៃការបដិសេធចោលរបស់តុលាការនៃបណ្តឹងសាទុក្ខ។ រីឯ អានុភាពចងនៃសេចក្តីវិនិច្ឆ័យលើអង្គហេតុ ត្រូវបានកម្រិតតែសេចក្តីវិនិច្ឆ័យអំពីអង្គហេតុដែលតុលាការនៃបណ្តឹងសាទុក្ខអាចវិនិច្ឆ័យបាន។

### ២.៣.២. ការផ្ទេររឿងក្តីទៅតុលាការផ្សេង

ជាគោលការណ៍ ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលក្រមដើម ឬសាលដីកាដើម តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងនោះត្រឡប់ទៅតុលាការដើមវិញ ក៏ប៉ុន្តែក្នុងករណីពិសេសដែលតុលាការមិនអាចស្វែងរកចៅក្រមជំនួស ដោយសារចំនួនចៅក្រមនៅក្នុងតុលាការដើមនោះមិនគ្រប់គ្រាន់ តុលាការនៃបណ្តឹងសាទុក្ខត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា។ ការកំណត់បែបនេះក្នុងគោល បំណងជៀសវាងការយឺតយ៉ាវ ឬការរាំងស្ទះដល់ដំណើការនៃនីតិវិធីបណ្តឹងចំពោះតុលាការ[81] ដែលទទួលការផ្ទេររឿងក្តីនេះ ត្រូវធ្វើការសម្រេចសេចក្តីដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់សារជាថ្មីហើយចំនួនចៅក្រមត្រូវអនុវត្តដូចគ្នានឹងករណីបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញដែរ។ ចំណែកឯភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក ។

### ២.៣.៣. ការបដិសេធចោល ហើយធ្វើការវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបដិសេធសាលក្រមដើម ឬសាលដីកាដើម ហើយយករឿងក្តីនោះមកធ្វើការសម្រេចសេចក្តីដោយខ្លួនឯងវិញ ប្រសិនបើ ក្រោយពីបានពិនិត្យទៅឃើញថា ការជំនុំជម្រះរបស់តុលាការដើមមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្តចំពោះអង្គហេតុ ដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តី អំពីរឿងក្តីនោះដោយផ្អែកលើអង្គហេតុនេះបាន។ មានន័យថាតុលាការ នៃបណ្តឹងសាទុក្ខអាចធ្វើការវិនិច្ឆ័យដោយខ្លួនឯងជំនួសសាលក្រម ឬសាលដីកាដើមនោះ

[81] មាត្រា ២៩៩ នៃសេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

បានក្នុងករណីដែលសាលក្រម ឬសាលដីកានោះធ្វើឡើងដោយមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តលើអង្គហេតុដែលបានកំណត់ជាស្ថាពរនៅក្នុងសាលក្រម ឬសាលដីកាដើមនោះប៉ុណ្ណោះ។ ការជំនុំជម្រះរឿងក្តីរបស់តុលាការដើមមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ។ មានន័យថា តុលាការដើមបានធ្វើការជំនុំជម្រះលើរឿងក្តីដែលខ្លួនគ្មានសិទ្ធិដើម្បីធ្វើការជំនុំជម្រះលើរឿងក្តីនោះ ជាឧទាហរណ៍មានដូចជាករណីដែលមានអភ័យឯកសិទ្ធិជម្រះក្តីរបស់តុលាការបរទេស និងករណីដែលគ្មានសមត្ថកិច្ចជម្រះក្តីអន្តរជាតិជាដើម។

# ជំពូកទី ៤
# បណ្ដឹងជំទាស់

# ជំពូកទី ៤
# បណ្តឹងជំទាស់

ជាទូទៅ ប្រភេទនៃសេចក្តីសម្រេចត្រូវបានបែងចែកជាច្រើនប្រភេទទៅតាមនីតិវិធីច្បាប់។ ក្នុងនោះ '**ដីកាសម្រេច**' ក៏ជាប្រភេទមួយនៃសេចក្តីសម្រេចដែរ ដែលដីកាសម្រេចត្រង់នេះ សំដៅដល់ការសម្រេចសេចក្តីមួយប្រភេទ ដែលតុលាការ ឬចៅក្រមអាចធ្វើដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយវាមិនមែនជាសាលក្រមនោះទេ។ កាលណា ភាគីណាមួយមិនពេញចិត្តនឹងសេចក្តីសម្រេចប្រភេទពិសេសនេះ នោះភាគីមិនអាចធ្វើការប្តឹងឧបាស្រ័យ ដោយអំណាចនៃបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខទៅនឹងដីកាសម្រេចនេះទេ ពីព្រោះវាជាសេចក្តីសម្រេចពិសេស ដែលមិនមែនសាលក្រម។

ដូចនេះ ដើម្បីធ្វើការប្តឹងឧបាស្រ័យចំពោះសេចក្តីសម្រេចប្រភេទនេះ គូភាគីដែលមិនសុខចិត្តនឹងសេចក្តីសម្រេច ត្រូវធ្វើបណ្តឹងពិសេសមួយគឺ **បណ្តឹងជំទាស់**។ តទៅនេះ យើងនឹងសិក្សាស្វែងយល់លំអិតពីបណ្តឹងជំទាស់ក្នុងផ្នែកខាងក្រោម។

## ផ្នែកទី១៖ សញ្ញាណទូទៅនៃបណ្តឹងជំទាស់

ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់យ៉ាងច្បាស់អំពីសិទ្ធិក្នុងការប្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូង ឬសាលាឧទ្ធរណ៍ ទៅតុលាការជាន់ខ្ពស់ ដោយបណ្តឹងជំទាស់នេះជាប្រភេទនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។

### ១. និយមន័យ

បណ្តឹងជំទាស់ គឺជាប្រភេទនៃបណ្តឹងឧបាស្រ័យទៅកាន់តុលាការជាន់ខ្ពស់ ដែលធ្វើឡើងទៅនឹងដីកាសម្រេច ដែលមិនមែនជាសាលក្រម ឬសាលដីកា។ ក្នុងករណីនេះ បណ្តឹងជំទាស់អាចមានភាពងាយស្រួល និងឆាប់រហ័សជាងបណ្តឹងឧបាស្រ័យផ្សេងៗទៀត។ បណ្តឹងជំទាស់ គឺជាបណ្តឹងមួយ ដែលជាប្រព័ន្ធនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលឯករាជ្យ និងសង្ខេបដែលអាចធ្វើឡើងចំពោះដីកាសម្រេចតែប៉ុណ្ណោះ និងបញ្ចប់ដោយដីកាសម្រេចដូចគ្នា។ ប្រសិនបើ យើងធ្វើការប្រៀបធៀបបណ្តឹងជំទាស់ជាមួយនឹងបណ្តឹងផ្សេងទៀត ដែលស្ថិតក្នុងប្រភេទបណ្តឹងឧបាស្រ័យ ដែលមានបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខនោះយើងឃើញថា នីតិវិធីរបស់បណ្តឹងជំទាស់មានភាពឆាប់រហ័ស និងងាយស្រួលជាង។ ចំពោះតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់ គឺមានតែតុលាកាជាន់ខ្ពស់ជាងតុលាការដែលចេញដីកាសម្រេចនោះ។ **ឧទាហរណ៍៖** ប្រសិនបើសាលាឧទ្ធរណ៍ចេញដីកាសម្រេច ដូចនេះ មានន័យថាតុលាការកំពូល គឺជាតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់។ យ៉ាងណាមិញដីកាសម្រេចលើបណ្តឹងជំទាស់ គឺមិនអាចប្តឹងជំទាស់ទៀតបានទេ។[82]

[82] មាត្រា ២៥៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

## ២. មូលហេតុនៃបណ្តឹងជំទាស់

បណ្តឹងជំទាស់ ក៏ជាប្រភេទនៃបណ្តឹងឧបាស្រ័យ ដូចគ្នានឹងបណ្តឹងឧបាស្រ័យផ្សេងៗទៀតដែរ ដែលមូលហេតុនៃបណ្តឹងនោះ គឺភាគីមិនសុខចិត្តនឹងសេចក្តីសម្រេច (ដីកាសម្រេច) របស់តុលាការដែលចេញដោយតុលាការថ្នាក់ក្រោម។

## ៣. កម្មវត្ថុនៃបណ្តឹងជំទាស់

ការប្តឹងជំទាស់អាចធ្វើបាន លុះត្រាតែមានប្បញ្ញត្តិយ៉ាងជាក់ច្បាស់ថា អាចប្តឹងជំទាស់បាន។ ក្នុងនេះ មានន័យថា ប្រសិនបើដីកាសម្រេចមួយបានសម្រេចសេចក្តីថា អនុញ្ញាតឱ្យភាគីអាចធ្វើការប្តឹងជំទាស់តាមកំណត់ច្បាប់ ទើបភាគីអាចធ្វើការប្តឹងបាន តែប្រសិនបើដីកាសម្រេចនេះមិនបានកំណត់អំពីលទ្ធភាពនៃការប្តឹងជំទាស់ទេ នោះដីកាសម្រេចនេះមិនអាចធ្វើការប្តឹងជំទាស់បានឡើយ។

ក្នុងនោះ ដីកាសម្រេចដែលភាគីអាចប្តឹងជំទាស់បានរួមមាន៖

**ដីកាសម្រេចបដិសេធ៖**

- ដីកាសម្រេចឱ្យលុបចោលដីកាសម្រេចជួយសង្គ្រោះលើពាក្យបណ្តឹង[83]
- ដីកាសម្រេចឱ្យលុបចោលប្រាតិភោគ[84]
- ដីកាសម្រេចលើកបណ្តឹងចោល[85]
- ដីកាសម្រេចលើកចោលពាក្យសុំឱ្យរក្សាការពារភស្តុតាង[86]
- ដីកាសម្រេចលើកចោលពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹង[87]
- ដីកាសម្រេចលើកចោល និងច្រានចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី[88]
- ដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន[89]
- ដីកាសម្រេចការលុបចោលការរឹបអូស[90]
- ដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ[91]

---

[83] មាត្រា ៧០ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[84] មាត្រា ៧៣ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[85] មាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[86] មាត្រា ១៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[87] មាត្រា ១៧៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[88] មាត្រា ១៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[89] មាត្រា ៣២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[90] មាត្រា ៣៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[91] មាត្រា ៤១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

- ដីកាសម្រេចលើកចោលការទាមទារឱ្យចែករំលែក[92]

**ដីកាសម្រេចអនុញ្ញាត មិនអនុញ្ញាត និងបញ្ជា៖**

- ដីកាសម្រេចនូវការអនុញ្ញាត ឬមិនអនុញ្ញាតឱ្យចូលអន្តរាគមន៍[93]
- ដីកាសម្រេចឱ្យជួយសង្គ្រោះលើពាក្យបណ្ដឹង[94]
- ដីកាសម្រេចបង្គាប់ឱ្យនាំខ្លួនសាក្សី និងដីកាសម្រេចពិន័យសាក្សីជាសាច់ប្រាក់ដោយមិនចូលតាមដីកាកោះ[95]
- ដីកាសម្រេចពិន័យភាគីដែលបន្លំសេចក្ដីថ្លែងការណ៍[96]
- ដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ[97]
- ដីកាសម្រេចឱ្យតតិយជនបង់ប្រាក់ពិន័យ ដោយមិនគោរពដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ[98]

## ផ្នែកទី២៖ លក្ខខណ្ឌ នីតិវិធី និងអានុភាពនៃបណ្ដឹងជំទាស់

### ១. លក្ខខណ្ឌនៃបណ្ដឹងជំទាស់

បណ្ដឹងជំទាស់ មានលក្ខខណ្ឌជាច្រើនដើម្បីឱ្យក្លាយជាបណ្ដឹងត្រឹមត្រូវទៅតាននគតិច្បាប់ ក្នុងនោះរួមមានលក្ខខណ្ឌនៃអ្នកមានសិទ្ធិប្ដឹងជំទាស់។

#### ១.១. អ្នកមានសិទ្ធិប្ដឹងជំទាស់

បុគ្គលទទួលឥទ្ធិពល ដែលខូចប្រយោជន៍ដល់សិទ្ធិ ឬឋានៈគតិយុត្តរបស់ខ្លួនដោយសារ ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អំពីរឿងក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អាចប្ដឹងជំទាស់ចំពោះដីកាសម្រេចនោះបានលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

ក្នុងករណីដែលត្រូវចេញដីកាសម្រេចតាមពាក្យសុំ មានតែអ្នកដាក់ពាក្យសុំ ទើបអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន។

លើសពីនេះ អ្នកតំណាងស្របច្បាប់ ដូចជាមេធាវីតំណាងដោយអាណត្តិ អ្នកទទួលសិទ្ធិស្របច្បាប់ ជាអាទិ៍ អាចធ្វើការប្ដឹងជំទាស់បាន ដោយភ្ជាប់ជាមួយនឹងលិខិតប្រគល់សិទ្ធិឱ្យប្ដឹងជំទាស់ជាចាំបាច់។

[92] មាត្រា ៤០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[93] មាត្រា ៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[94] មាត្រា ៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[95] មាត្រា ១៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[96] មាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[97] មាត្រា ១៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[98] មាត្រា ១៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ១.២. អំឡុងពេលសម្រាប់ប្តឹងជំទាស់

ការប្តឹងជំទាស់ ត្រូវធ្វើក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃ ដែលភាគីបានទទួលដំណឹងអំពីដីកាសម្រេច ហើយអំឡុងពេល ១ (មួយ) សប្តាហ៍នេះ មិនអាចពន្យារបានឡើយ។[99]

## ២. នីតិវិធីនៃបណ្តឹង

ការប្តឹងជំទាស់ត្រូវធ្វើទៅតុលាការដើម (ត្រង់នេះ តុលាការដើម សំដៅដល់តុលាការដែលចេញដីកាសម្រេច និងជាតុលាការដែលបញ្ជូនសំណុំរឿងទៅតុលាការជាន់ខ្ពស់)។ តុលាការដើមត្រូវធ្វើឱ្យឆាប់រហ័សនូវពាក្យបណ្តឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់។ ក្រោយបញ្ជូនសំណុំរឿងសាលាជម្រះក្តីជាន់ខ្ពស់ (សាលាឧទ្ធរណ៍ ឬតុលាការកំពូល ជាអ្នកមានសមត្ថកិច្ចចាត់ការ)។

ចំពោះបណ្តឹងជំទាស់ដែលមានលក្ខណៈពេញលេញ បន្ទាប់ពីធ្វើការវិនិច្ឆ័យ តុលាការដែលមានសមត្ថកិច្ចអាចធ្វើការទាញហេតុផលតាមឆន្ទៈរបស់ចៅក្រម (៣០៤) ឬនិងការសួរភាគី(អសាធារណៈ) ជាលទ្ធផលដីកាសម្រេចលើបណ្តឹងជំទាស់ មិនអាចប្តឹងជំទាស់បានទៀតឡើយ។ ក្នុងករណីដែលពាក្យបណ្តឹងជំទាស់មានចំណុចខ្វះខាត ដូចជាខ្វះចំណុចអត្តសញ្ញាណរបស់ភាគី និងអ្នកតំណាងតាមច្បាប់កំណត់(២៦៥) និងសញ្ញាណដីកាសម្រេចដែលត្រូវប្តឹងជំទាស់ និងសេចក្តីប្តឹងជំទាស់(២៦៦) តុលាការដែលមានសមត្ថកិច្ចត្រូវចេញដីកាសម្រេចបង្គាប់អោយកែតម្រូវ ក្នុងករណីភាគីមិនកែតម្រូវចំណុចខ្វះខាត តុលាការដែលមានសមត្ថកិច្ចចេញដីកាសម្រេចលើកចោលពាក្យបណ្តឹងជំទាស់ ដីកាសម្រេចលើកពាក្យបណ្តឹងជំទាស់នេះ អាចប្តឹងជំទាស់បាន។ ផ្ទុយទៅវិញបើភាគីបានកែតម្រូវចំណុចខ្វះខាត គឺតុលាការដែលមានសមត្ថកិច្ចបន្តនីតិវិធីធម្មតា។

### ២.១. ការទទួលពាក្យបណ្តឹងជំទាស់

ពាក្យបណ្តឹងជំទាស់ត្រូវដាក់នៅតុលាការដើមចំពោះដីកាសម្រេចនោះ ក្នុងអំឡុងពេលកំណត់សម្រាប់ធ្វើបណ្តឹងជំទាស់។ ដោយឡែកតុលាការដើមពុំមានសមត្ថកិច្ចពិនិត្យពាក្យបណ្តឹងជំទាស់ទេ គ្រាន់តែជាតុលាការដែលទទួលពាក្យបណ្តឹងជំទាស់របស់ភាគីតែប៉ុណ្ណោះ។ បន្ទាប់មកតុលាការដើមត្រូវធ្វើការធ្វើឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងជំទាស់នោះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់ ឬ តុលាការជាន់ខ្ពស់។

### ២.២. ការពិនិត្យពាក្យបណ្តឹងជំទាស់

តុលាការនៃបណ្តឹងជំទាស់ត្រូវធ្វើការពិនិត្យ ប្រសិនបើមានចំណុចណាមិនសមស្រប តុលាការត្រូវតែបង្គាប់ឱ្យដើមបណ្តឹងជំទាស់ធ្វើការកែប្រែ។ ក្នុងករណីដែលភាគីនោះមិនធ្វើតាមការបង្គាប់ឱ្យកែប្រែរបស់តុលាការទេតុលាការនឹងមានសិទ្ធិលើកចោលពាក្យបណ្តឹងជំទាស់នោះដោយដីកាសម្រេច។

[99] មាត្រា ៣០៣ កថាខណ្ឌទី១, កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ប្រសិនបើពាក្យបណ្តឹងជំទាស់ត្រឹមត្រូវតាមទម្រង់ច្បាប់ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងជំទាស់នោះទៅឱ្យចុងបណ្តឹងជំទាស់។

### ៣. អានុភាពនៃបណ្តឹងជំទាស់

បណ្តឹងជំទាស់ត្រូវផ្អាកអានុភាពនៃដីកាសម្រេចដើម។ ត្រង់នេះមានន័យថា កាលការភាគីធ្វើការប្តឹងជំទាស់នូវដីកាសម្រេចអ្វីមួយ។

ឧទាហរណ៍ ដីកាសម្រេចបង្កកទ្រព្យសម្បត្តិ ត្រូវមានអានុភាពបង្កកទ្រព្យសម្បត្តិ ភាគីក្នុងសំណុំរឿង ដែលអាចយកមកអនុវត្តដោយបង្ខំបាន តែប្រសិនបើភាគីណាមួយមិនសុខចិត្តនឹងដីកាសម្រេចនេះ ភាគីនោះអាចធ្វើការប្តឹងជំទាស់នឹងដីកាសម្រេចបង្កកទ្រព្យសម្បត្តិនេះ ហើយនឹងផ្អាកអានុភាពនៃដីកាសម្រេចនេះ ដោយរង់ចាំការសម្រេចសេចក្តីពីសាលាជាន់ខ្ពស់នៃបណ្តឹងជំទាស់ជាមុនសិន ទើបអាចបន្តនីតិវិធីបាន។

## ផ្នែកទី៣៖ វិសាលភាពនៃការជំនុំជម្រះលើបណ្តឹងជំទាស់

### ១. វិសាលភាពការជម្រះលើបណ្តឹងជំទាស់ដីកាសម្រេចនៃសាលាឧទ្ធរណ៍

បើទោះជាការប្តឹងជំទាស់អាចធ្វើឡើងទៅតាមការកំណត់ក្នុងបញ្ញត្តិច្បាប់ក៏ដោយ ក៏ប៉ុន្តែចំពោះដីកាសម្រេច ចុងក្រោយនៃការជំនុំជម្រះបណ្តឹងជំទាស់ដែលតុលាការនៃបណ្តឹងជំទាស់បានចេញ មិនអាចប្តឹងជំទាស់ទៀតបានឡើយ។ ឧទាហរណ៍៖ ប្រសិនបើមានបណ្តឹងជំទាស់ចំពោះដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារដែលបានចេញដោយសាលាដំបូងក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ ភាគីអាចប្តឹងជំទាស់បានទៅសាលាឧទ្ធរណ៍ ប៉ុន្តែ នៅពេលតុលាការនៃបណ្តឹងឧទ្ធរណ៍ចេញដីកាសម្រេចចុងក្រោយនៃបណ្តឹងជំទាស់នោះហើយ គឺមិនអាចប្តឹងជំទាស់ទៅតុលាការកំពូលថែមទៀតបានទេ។ ការអនុវត្តបែបនេះ គឺដើម្បីសម្រាលនូវបន្ទុករបស់តុលាការកំពូល។ ផ្ទុយមកវិញចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើឡើង ក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ អាចប្តឹងជំទាស់ទៅតុលាការកំពូលបាន បើមានបញ្ញត្តិច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ចំពោះដីកាសម្រេចនោះ។ បណ្តឹងជំទាស់ត្រង់ចំណុចនេះ គឺជាបណ្តឹងជំទាស់ទៅតុលាការកំពូល ដែលជាតុលាការវិនិច្ឆ័យទៅលើអង្គច្បាប់ ហើយនីតិវិធីនៃការប្តឹងជំទាស់ទៅតុលាការកំពូលក្នុងករណីនេះ គឺស្រដៀងគ្នាទៅនឹងការអនុវត្តបណ្តឹងសាទុក្ខ ចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ ដោយហេតុនេះបញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និងនីតិវិធីទាក់ទងទៅនឹងការជំនុំជម្រះបណ្តឹងសាទុក្ខទាំងនោះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី១ និងនីតិវិធីដែលទាក់ទងនឹងបណ្តឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានការផ្ទុយនឹងលក្ខណៈនៃបណ្តឹង ឬនីតិវិធីនោះ។ ហេតុដូច្នេះបណ្តឹងជំទាស់នេះអាច

ធ្វើទៅបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើដីកាសម្រេចដើមតែប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត មានករណីខ្លះដែលសាលាឧទ្ធរណ៍អាចចេញដីកាសម្រេច ក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍។ ក្នុងករណីនេះភាពអាច ឬមិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍ចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ អាស្រ័យទៅលើការអនុវត្តតាមបញ្ញត្តិនៃមាត្រា២៥៩។ ដូចនេះ លើកលែងតែករណីដែលមានបញ្ញត្តិច្បាប់អនុញ្ញាតឱ្យប្តឹងជំទាស់ ភាគីមិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាឧទ្ធរណ៍បានឡើយ។ ក្នុងករណីដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេចជាដំបូងក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ប្រសិនបើបណ្តឹងជំទាស់ចំពោះដីកាសម្រេចត្រូវបានធ្វើឡើងផ្អែកលើបញ្ញត្តិនៃគន្ថីទី១ ដែលអាចអនុវត្តដោយផ្ទាល់ចំពោះបណ្តឹងឧទ្ធរណ៍ ភាគីអាចប្តឹងជំទាស់បាន។ **ឧទាហរណ៍៖** ចំពោះដីកាសម្រេច ដែលសម្រេចថាការដកហូត ឬបណ្តឹងជិតចិត្តចៅក្រមនៃសាលាឧទ្ធរណ៍មិនត្រឹមត្រូវ អាចប្តឹងជំទាស់បានដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៦ មាត្រា៣០ នៅក្នុងគន្ថីទី១។ ផ្ទុយមកវិញចំពោះដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ដែលសាលាឧទ្ធរណ៍បានចេញ ក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍មិនអាចប្តឹងជំទាស់បានឡើយ ដោយសារបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា១៥២ មិនត្រូវអនុវត្តដោយផ្ទាល់ចំពោះបណ្តឹងឧទ្ធរណ៍ទេ ហើយត្រូវអនុវត្តដូចគ្នាផងដែរ ក្នុងនាមជាបញ្ញត្តិដែលទាក់ទងនឹង **គន្ថីទី២ ស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី១ ដោយយោងតាមបញ្ញត្តិនៃមាត្រា២៧២។**

## ២. វិសាលភាពការជំនុំជម្រះបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលការបញ្ជា ឬ ការប្រគល់សិទ្ធិ

ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬ ចៅក្រមទទួលបន្ទុកនេះគឺខុសគ្នានឹងដីកាសម្រេចរបស់តុលាការ ដោយនៅទីនេះ គេតម្រូវឱ្យមានការគ្រប់គ្រងពិនិត្យដោយតុលាការដែលទទួលបណ្តឹង។ ហេតុនេះ បើភាគីមានការតវ៉ា តុលាការដែលទទួលបណ្តឹងត្រូវសម្រេចសេចក្តីដោយដីកាសម្រេច។ ចំពោះដីកាសម្រេចរបស់ចៅក្រមទទួលបញ្ជា ឬចៅក្រមទទួលបន្ទុក ដែលត្រូវបានជ្រើសតាំងចំពោះរឿងក្តីសាលាឧទ្ធរណ៍ ឬតុលាការកំពូលកំពុងចាត់ការវិញក៏ដូចគ្នានឹងករណីដែលសាលាដំបូងជាតុលាការទទួលបណ្តឹង ដែលភាគីអាចដាក់ពាក្យសុំប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ឬតុលាការកំពូលដែលជាតុលាការទទួលបណ្តឹង។ ចំពោះការស្នើសុំប្តឹងតវ៉ាដែលមានចែង ក្នុងមាត្រា៣០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើដីកាសម្រេចនោះត្រូវបានធ្វើឡើងដោយតុលាការទទួលបណ្តឹងនោះ ភាគីត្រូវធ្វើបណ្តឹងជំទាស់ ហេតុនេះភាគីត្រូវធ្វើបណ្តឹងតវ៉ានៅក្នុងអំឡុងពេល ០១ សប្តាហ៍ក្រោយថ្ងៃទទួលដំណឹងអំពីដីកាសម្រេច ដែលមានចែងក្នុងមាត្រា៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។ ប្រសិនបើតុលាការ ទទួលបណ្តឹងជាសាលាឧទ្ធរណ៍ ចំពោះតែករណីនៃកថាខណ្ឌទី២ នៃមាត្រា៣០៤ (ការអនុវត្ត

ដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ) អាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើពាក្យសុំដែលមានចែងក្នុងកថាខណ្ឌទី១ មាត្រា៣០២ បានតែប្រសិនបើតុលាការទទួលពាក្យបណ្តឹងជាតុលាការកំពូលវិញ មិនអាចប្តឹងជំទាស់បានឡើយ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សា និងបកស្រាយយ៉ាងស៊ីជម្រៅទៅលើទ្រឹស្តីគតិយុត្តិពាក់ព័ន្ធទៅនឹងប្រធានបទស្តីពី "**បណ្តឹងឧបាស្រ័យក្នុងរឿងរដ្ឋប្បវេណី**" រួចមក យើងអាចធ្វើការសន្និដ្ឋានបានថា បណ្តឹងឧបាស្រ័យនៅក្នុងរឿងក្តីរដ្ឋប្បវេណីនេះគឺជាបណ្តឹងមួយធ្វើឡើងដោយភាគីដែលមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចណាមួយរបស់ចៅក្រម ដែលជាសាលក្រម ឬសាលដីកា ឬដីកាសម្រេច ដើម្បីទាមទារឱ្យតុលាការលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចដើមដែលបានចេញដោយតុលាការថ្នាក់ក្រោម។ យ៉ាងណាមិញបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ភាគីអាចធ្វើទៅបាននៅមុនពេលដែលសេចក្តីសម្រេចចូលជាស្ថាពរប៉ុណ្ណោះ។ នៅពេលដែលភាគីបានដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នោះតុលាការនឹងដំណើការនៃការចាត់នីតិវិធីនៃបណ្តឹងឧបាស្រ័យ ហេតុនេះនាំឲ្យសេចក្តីសម្រេចទាំងមូលមិនអាចចូលជាស្ថាពរបានទេ រហូតដល់ដំណើការឧបាស្រ័យទៅតុលាការជាន់ខ្ពស់នោះបានបញ្ចប់។ យ៉ាងណាមិញឃើញថាការចូលជាស្ថាពរនៃសេចក្តីសម្រេចនៅតុលាការថ្នាក់ក្រោម គឺជាស្ថានភាពមួយដែលសេចក្តីសម្រេចនោះមិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ។ ផ្ទុយទៅវិញក្នុងករណី នៅពេលដែលសេចក្តីសម្រេចដែលចេញដោយតុលាការថ្នាក់ក្រោម បានចូលជាស្ថាពររួចហើយ ភាគីក៏នៅតែអាចធ្វើបណ្តឹងតវ៉ាបានតែក្នុងករណីបណ្តឹងនោះគឺជាបណ្តឹងទាមទារឲ្យជំនុំជម្រះសារជាថ្មី។

ជាទូទៅ ដោយផ្អែកទៅតាមលក្ខណៈគតិយុត្តិ តាមរយៈការអនុញ្ញាតឲ្យភាគីដែលមានសិទ្ធិធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តែងតែមានរឿងក្តីជាច្រើនដែលត្រូវបានតុលាការពិនិត្យ និង ធ្វើការជំនុំជម្រះសារឡើងវិញ ដោយតុលាការជាន់ខ្ពស់មួយចំនួនតូច ហើយចុងក្រោយបំផុតត្រូវជម្រះដោយតុលាការជាន់ខ្ពស់ ហើយចុងក្រោយគេបំផុតនោះគឺតុលាការកំពូល។ ជាលទ្ធផល ការបកស្រាយ និងអនុវត្តទៅលើព្រព័ន្ធច្បាប់តែមួយដោយឡែកពីគ្នានៅតុលាការជាន់ទាបដ៏ច្រើននោះ អាចនឹងត្រូវបានបង្រួបបង្រួមឱ្យក្លាយទៅជាការបកស្រាយ និងអនុវត្តតែមួយដោយតុលាការកំពូល ។ បានសេចក្តីថា ក្នុងការរួមបញ្ចូលគ្នានូវ ប្រព័ន្ធជម្រះក្តី ដែលមានបីថ្នាក់របបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានតួនាទីធ្វើការរួមបញ្ចូលនូវការបកស្រាយច្បាប់នៃប្រទេសកម្ពុជា ហើយដោយសារប្រព័ន្ធនោះ គឺអាចធានាបាននូវប្រព័ន្ធគតិយុត្តដែលប្រកបទៅដោយស្ថិរភាព មានសណ្តាប់ធ្នាប់ និងប្រកបដោយគុណភាព យុត្តិធម៌ សម្រាប់ពលរដ្ឋកម្ពុជា។ ការសម្រេចសេចក្តីចំពោះការទាមទារតាមផ្លូវបណ្តឹង ដែលត្រូវបានធ្វើឡើងដោយតុលាការ ដែលមានចៅក្រមជាអ្នកធ្វើសេចក្តីសម្រេច។ ចៅក្រមគឺជាមនុស្សធម្មតាដូចយើងទាំងអស់គ្នាដែរ ដែលជៀសមិនផុតពីការបង្កើតនូវកំហុសដោយចេតនា ឬអចេតនា ហើយកំហុសនេះអាចបំពានសិទ្ធិរបស់ភាគី និងអាចធ្វើឱ្យបាត់ទំនុកចិត្តជា សាធារណៈចំពោះប្រព័ន្ធតុលាការ ឬប៉ះពាល់ដល់យុត្តិធម៌សង្គម។ ហេតុនេះ តម្រូវឱ្យមានប្រព័ន្ធមួយសម្រាប់ត្រួតពិនិត្យនូវសេចក្តីសម្រេចចុងក្រោយរបស់សាលាដំបូង (តុលាការជាន់ទាប) គឺតុលាការនៃបណ្តឹងឧទ្ធរណ៍ (សាលាឧទ្ធរណ៍) ក្នុងករណីមានបណ្តឹង

ឧទ្ធរណ៍។ បណ្ដឹងឧទ្ធរណ៍ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង ក្នុងគោលបំណងឱ្យតុលាការជាន់ខ្ពស់លុបចោល ឬផ្លាស់ប្ដូរនូវសាលក្រមចុងក្រោយ។ តុលាការដែលជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ ត្រូវហៅថា តុលាការនៃបណ្ដឹងឧទ្ធរណ៍ ហើយការជំនុំជម្រះដោយតុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវហៅថាការជំនុំជម្រះលើកទី២។ ចំណែកឯបណ្ដឹងសាទុក្ខនៃរឿងក្ដីរដ្ឋប្បវេណីគឺជាប្រភេទមួយនៃបណ្ដឹឧបាស្រ័យទៅតុលាការជាន់ខ្ពស់។ បណ្ដឹងសាទុក្ខក្នុងរឿងក្ដីរដ្ឋប្បវេណី មានលក្ខណៈពិសេសខុសពីបណ្ដឹងផ្សេងៗទៀតត្រង់ថា បណ្ដឹងនេះធ្វើបានចំពោះតែសាលក្រម ឬសាលដីកាចុងក្រោយដែលមិនទាន់ចូលជាស្ថាពរ ហើយការធ្វើបណ្ដឹងនេះ គឺធ្វើទៅតុលាការកំពូលដែលជាអង្គកំពូលនៃស្ថាប័នយុត្តាធិការ។ ជាងនេះទៅទៀត ដើម្បីធ្វើបណ្ដឹងនេះបានត្រឹមត្រូវតាមច្បាប់ និងទទួលបានការវិនិច្ឆ័យពីសំណាក់តុលាការតាមការធ្វើឧបាស្រ័យរបស់ភាគី លុះណាតែបណ្ដឹងនោះបានធ្វើឡើងដោយផ្អែកលើមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តិដែលមានឥទ្ធិពលលើសាលក្រម ឬសាលដីកា ឬការចេញសាលក្រម ឬសាលដីការបស់តុលាការដើមផ្ទុយនឹងបញ្ញត្តិនៃក្រមនីតិវិធី រដ្ឋប្បវេណីមានដូចជា តុលាការដែលបានចេញសាលក្រម ឬសាលដីកាមិនត្រូវបានចាត់តាំងទៅតាមច្បាប់ ឬចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចេញសាលក្រម ឬសាលដីកាបានចូលរួមក្នុងការចេញសាលក្រម ឬសាលដីកា ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដាច់មុខ ការខ្វះសិទ្ធិតំណាងដើម្បីធ្វើសកម្មភាពបណ្ដឹង ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ និងករណីដែលសាលក្រម ឬសាលដីកានោះគ្មានសំអាងហេតុ ឬសំអាងហេតុនោះផ្ទុយគ្នា។ បណ្ដឹងជំទាស់អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់ ប៉ុន្តែចំពោះដីកាសម្រេចលើបណ្ដឹងជំទាស់ មិនអាចប្ដឹងជំទាស់ទៀតបានឡើយ បានសេចក្ដីថា ភាគីណាមួយអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចរបស់តុលាការបាន លុះត្រាតែច្បាប់បើកសិទ្ធិឱ្យភាគីនោះប្ដឹងជំទាស់។ ក្នុងករណីភាគីនោះបានប្ដឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងទៅសាលាឧទ្ធរណ៍ ដោយសាលាឧទ្ធរណ៍បានសម្រេចទៅលើបណ្ដឹងជំទាស់រួចរាល់ ប៉ុន្តែភាគីដែលជាម្ចាស់បណ្ដឹងជំទាស់ នៅតែមិនសុខចិត្តទៅនឹងការសម្រេចរបស់សាលាឧទ្ធរណ៍ទៀត ដូចនេះភាគីនោះ មិនអាចបណ្ដឹងជំទាស់ចំពោះដីកាសម្រេចនោះ ទៅតុលាការកំពូលទៀតបានឡើយ។ បណ្ដឹងជំទាស់ ជាប្រភេទនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលជានីតិវិធីមួយ ដែលមានកំណត់យ៉ាងច្បាស់លាស់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីសម្រាប់នីតិវិធីបណ្ដឹងនៃរឿងក្ដីរដ្ឋប្បវេណី។ ក្នុងករណី ភាគីណាមួយ ដែលមិនអនុវត្តតាមបញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទេនោះ នឹងធ្វើឱ្យភាគីនោះថ្លោះសិទ្ធិក្នុងការធ្វើសកម្មភាពបណ្ដឹងជំទាស់នោះ ពោលគឺចាញ់ក្ដីដោយពុំទាន់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ឬការសួរជាមិនខាន។

សរុបជារួមមក ថ្វីត្បិតតែបណ្ដឹងឧបាស្រ័យមានលក្ខណៈស្មុកស្មាញក្នុងដំណើរការនៃនីតិវិធីក្នុងរឿងក្ដីរដ្ឋប្បវេណី និងបានធ្វើឲ្យមានការលំបាកក្នុងការអនុវត្តដោយស្របទៅតាមនីតិវិធីដែលមានចែងក្នុងច្បាប់ក៏ពិតមែន

ក៏ប៉ុន្តែ ក្រោយពីតុលាការបានបញ្ចប់នីតិវិធីនៃបណ្តឹងឧបាស្រ័យ ក៏បានផ្តល់នូវផលប្រយោជន៍ជាច្រើនទៅភាគីដែលកើតមាននូវវិវាទ និងការមិនពេញចិត្តទៅលើការវិនិច្ឆ័យសម្រេចសេចក្តីរបស់តុលាការជាន់ទាប ឬតុលាការនៃបណ្តឹងឧទ្ធរណ៍។ យ៉ាងណាក៏ដោយ ទោះជាមានការខិតខំប្រឹងប្រែងអនុវត្តការវិនិច្ឆ័យសេចក្តីដើម្បីស្វែងរកយុត្តិធម៌ជូនភាគីនៃវិវាទក៏ដោយមន្ត្រីនៃស្ថាប័នតុលាការមួយចំនួន នៅមិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយតាមច្បាប់នីតិវិធី ដែលបានកំណត់បានគ្រប់ជ្រុងជ្រោយបានល្អឥតខ្ចោះនៅឡើយទេ ព្រោះថានៅពេលខ្លះដោយសារមានការមមាញឹកក្នុងការងារច្រើនពេក ឬការធ្វេសប្រហែសដោយអចេតនា ឬដោយសារភាពខ្វះចន្លោះត្រង់ចំណុចណាមួយ ដែលជាហេតុនាំឲ្យមានការសម្រេចសេចក្តី ដោយមិនបានគោរពគោលការណ៍នីតិវិធីពេញលេញឡើយ ក៏បានសម្រេចធ្វើតាមអ្វីៗដែលធ្លាប់តែអនុវត្ត ដោយមិនបានគិតពីនីតិវិធីចាំបាច់ ។ អាស្រ័យហេតុនេះ ការស្រាវជ្រាវនេះផ្តល់ជាមតិដល់មន្ត្រីតុលាការ គួរតែប្រតិបត្តិ ការងារផ្សំនឹងបទពិសោធន៍ ព្រមទាំងកុំឃ្លាតឆ្ងាយពីច្បាប់នីតិវិធីដែលបានកំណត់ផ្លូវសំរាប់ប្រតិបត្តិ ក្នុងវិស័យតុលាការ ដែលជានីតិវិធីមួយដែលការពារនូវភាពលំអៀង ឬមានការភាន់ច្រឡំ របស់តុលាការនៅពេលដំណើរការរឿងក្តីណាមួយ។ ជាពិសេសជាងនេះទៅទៀត គឺមានវិធានការក្នុងការទប់ស្កាត់នូវការចេញសេចក្តីសម្រេចរបស់តុលាការទៅតាមទំនើងចិត្តរបស់ចៅក្រមតុលាការជាន់ទាប និងតុលាការជាន់ខ្ពស់ណាមួយ ដែលជួយឱ្យមានភាពល្អប្រសើរចំពោះការចេញសេចក្តីសម្រេចគ្រប់តុលាការជាន់ទាប និងតុលាការជាន់ខ្ពស់ទាំងអស់ត្រូវតែគោរពតាម និងអនុលោមទៅតាមច្បាប់ដែលបានកំណត់ទើបការសម្រេចសេចក្តីនោះអាចប្រកបដោយភាពយុត្តិធម៌ ភាពត្រឹមត្រូវ មិនលំអៀង និងមានភាពច្បាស់លាស់ជូនប្រជាពលរដ្ឋ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវអំពី បណ្ដឹងឧបាស្រ័យ ពួកយើងបានទទួលនូវបទពិសោធន៍ និងចំណេះដឹងថ្មីៗជាច្រើនពាក់ព័ន្ធនឹងប្រភេទនៃបណ្ដឹងឧបាស្រ័យ ទាំងអស់ រួមមាន បណ្ដឹងឧទ្ធរណ៍ បណ្ដឹងសាទុក្ខ និងបណ្ដឹងជំទាស់។ សិស្ស និស្សិតមួយចំនួន គប្បីស្វែងយល់ឱ្យច្បាស់ និងលំអិតអំពីប្រភេទបណ្ដឹងឧបាស្រ័យទាំងនេះ ព្រោះជាអាចជាសារៈសំខាន់ និងជាចំណេះដឹងទូទៅមួយសម្រាប់ខ្លួន។ ជាងនេះទៅទៀត ស្ថាប័នពាក់ព័ន្ធនានា ទាំងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន គប្បីផ្ដល់នូវឯកសារជំនួយស្មារតីបន្ថែមទៀតទុកសម្រាប់សិស្ស និស្សិតអាន និងសិក្សាស្វែងយល់ ដើម្បីបង្កើនចំណេះដឹង ទុកជាពុទ្ធិ។

យើងដឹងហើយថា វិស័យច្បាប់ គឺជាវិស័យមួយ ដែលដើរតួនាទីយ៉ាងសំខាន់សម្រាប់រក្សាស្ថិរភាព និងការអភិវឌ្ឍសង្គមជាតិ ហើយក៏ជាវិស័យមួយដ៏សំខាន់សម្រាប់ការដឹកនាំប្រទេស ក៏ដូចជាការគ្រប់គ្រងប្រទេសជាតិឱ្យមានសុខសន្តិភាព សណ្ដាប់ធ្នាប់ របៀបរៀបរយល្អ។ ប្រជាជនគ្រប់រូប ត្រូវតែគោរពច្បាប់។ ដូចនេះ គ្រប់ស្ថាប័ន ឬអង្គភាព ដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងវិស័យច្បាប់ ដូចជាតុលាការ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ត្រូវធ្វើយ៉ាងណាដើម្បីឱ្យការអនុវត្តច្បាប់តឹងរឹង ត្រឹមត្រូវ និងមានប្រសិទ្ធភាព។ កាន់តែពិសេសនោះគឺចៅក្រមដែលជាអ្នកកាត់សេចក្ដីក្នុងប្រព័ន្ធតុលាការ និងជាតំណាងឱ្យស្ថាប័នតុលាការត្រូវជៀសឱ្យឆ្ងាយអំពីឆន្ទាគតិភាពលំអៀងទៅកាន់ភាគីណាម្នាក់ ដោយគ្រប់ហេតុផល។

លើសពីនេះ ប្រព័ន្ធតុលាការ គប្បីពន្លឿននីតិវិធីបណ្ដឹងគ្រប់ប្រភេទ ដើម្បីជាការផ្ដល់យុត្តិធម៌ទាន់ហេតុការណ៍ មិនបាច់រង់ចាំរាប់ខែរាប់ឆ្នាំ ទម្រាំតែមានការផ្ដល់យុត្តិធម៌នេះទេ។ សាលាជម្រះក្ដីជាន់ខ្ពស់ រួមមាន សាលាឧទ្ធរណ៍ គួរតែបង្កើតឱ្យមានបន្ថែមទៀតនៅតាមបណ្ដាតំបន់ធំៗមួយចំនួនទៀតនៅប្រទេសកម្ពុជា ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ក្នុងការធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់ កាត់បន្ថយការចំណាយ និងពេលវេលាក្នុងការស្វែងរកយុត្តិធម៌។ ដោយហេតុថា សាលាឧទ្ធរណ៍គឺមាននៅរាជធានីភ្នំពេញ និងតំបន់ចំនួនតែប៉ុណ្ណោះ ដូច្នេះនៅពេលភាគីណា មួយមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់សាលាជម្រះក្ដីជាន់ទាប គឺពិតជាមានការលំបាកក្នុងការប្ដឹងឧទ្ធរណ៍មកកាន់សាលាឧទ្ធរណ៍ណាស់ ជាពិសេសប្រជាជនក្រីក្រដែលរស់នៅតំបន់ដាច់ស្រយាល និងប្រជាពលរដ្ឋនៅមានកម្រិតផង នោះ ធ្វើឱ្យពួកគាត់ទទួលបាននូវភាពយុត្តិធម៌មិនដូចគ្នាទេ។ ប្រសិនបើធ្វើការពង្រីកបន្ថែមនូវសាលាឧទ្ធរណ៍ទៅ តាមបណ្ដាតំបន់នានា គឺមានន័យថាជាការធ្វើឱ្យមានសមភាពផ្នែកយុត្តិធម៌សម្រាប់ប្រជាជននៅទីក្រុង និងជនបទ។

សរុបមក ដើម្បីឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសមានប្រព័ន្ធច្បាប់ខ្លាំងក្លា ជាប្រទេសមានប្រព័ន្ធយុត្តិធម៌ល្អប្រសើរជាងនេះ នោះគ្រប់ស្ថាប័ននានា មិនថា ស្ថាប័នតុលាការ ស្ថាប័នរដ្ឋ ស្ថាប័នឯកជន ព្រមទាំងគ្រប់ប្រជា

ពលរដ្ឋ ត្រូវរួមគ្នាសិក្សាស្វែងយល់អំពីច្បាប់ ជាពិសេសគឺបណ្តឹងឧបាស្រ័យ នីតិវិធីនានានៃបណ្តឹង ព្រមទាំងរួមគ្នាលុបបំបាត់នូវអំពីពុករលួយ សូកប៉ាន់ ដែលនាំឱ្យប្រយោជន៍ និងកិត្តិយសជាតិអន់ថយ។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្តិ

- ក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/ ១២០៧/០៣១ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។
- ច្បាប់ស្តីពីនីតិវីធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ នស/រមក/០៧១០/០១៣, ០៩ មិថុនា ឆ្នាំ២០១០។
- ច្បាប់ស្តីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ ។

## ២. សៀវភៅ បទបង្ហាញ និងឯកសារផ្សេងៗ

- សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ក្រសួងយុត្តិធម៌ ភាគ១ និងភាគ២ បោះពុម្ពឆ្នាំ ២០០៨ ។
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយ ក្រុមការងារ ជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៩។
- បទបង្ហាញស្តីពីបណ្តឹងឧបាស្រ័យក្នុងនីតិវិធីរដ្ឋប្បវេណី ដោយលោក សេង នាង ចៅក្រមតុលាការកំពូល (ឆ្នាំសិក្សា ២០១៩-២០២០) ។
- វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ ឆ្នាំ២០១៨ របស់ សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ ។

# បញ្ជីរាយនាមឧបសម្ព័ន្ធ

**បញ្ជីរាយនាមឧបសម្ព័ន្ធ**

**ឧបសម្ព័ន្ធទី១.គំរូពាក្យបណ្ដឹង**

- ពាក្យបណ្ដឹងក្នុងរឿងរដ្ឋប្បវេណី
- ពាក្យបណ្ដឹងឧទ្ធរណ៍
- ពាក្យបណ្ដឹងសាទុក្ខ
- ពាក្យបណ្ដឹងជំទាស់
- ពាក្យសុំអនុវត្តដោយបណ្ដោះអាសន្ន
- ពាក្យសុំដកពាក្យបណ្ដឹង

**ឧបសម្ព័ន្ធទី២៖ គំរូសាលក្រម សាលដីកា ដីកាសម្រេច**

- គំរូសាលក្រមរដ្ឋប្បវេណីដែលអាចប្ដឹងឧទ្ធរណ៍
- គំរូសាលដីការដ្ឋប្បវេណីដែលអាចប្ដឹងសារទុក្ខ
- គំរូដីកាសម្រេចដែលអាចប្ដឹងជំទាស់

**ឧបសម្ព័ន្ធទី៣៖ លិខិតជូនដំណឹង និងដីកាបង្គាប់ផ្សេងៗ**

- ដីកាបង្គាប់ឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ
- លិខិតជូនដំណឹងអំពីការទទួលពាក្យបណ្ដឹងជំទាស់ និងឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងជំទាស់
- លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹង
- ដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដី

# ឧបសម្ព័ន្ធទី១
# គំរូពាក្យបណ្តឹង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្ដឹង

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តរតនគិរី[1]។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ..................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ...................................................

លេខទូរស័ព្ទ ៖ ...................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................. [2]

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ ដូច្នេះ ត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគី។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ប្រសិនបើពុំមានការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូនទេ ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅឋានរបស់ដើមចោទ ជាអាទិ៍។ ហេតុនេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ដើមចោទមានបំណងធ្វើការបញ្ជូនទៅកាន់ទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ដើមចោទជាអាទិ៍ គឺមានភាពចំបាច់ក្នុងការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូននៅក្នុងលិខិតពាក្យបណ្ដឹងជាអាទិ៍។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងខេត្តរតនគិរី**[3]

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ[4]៖

(១) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។[5]

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។[6]

---

[3] ដើមចោទត្រូវតែដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច (មាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមពេលដាក់ពាក្យបណ្តឹង (មាត្រា ១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងរឿងក្តីនេះ លំនៅឋានរបស់ចុងចម្លើយ នៅរាជធានីភ្នំពេញ ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញមានសមត្ថកិច្ចជម្រះក្តី (ចំណុច ក មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ម្យ៉ាងវិញទៀត ដោយសារតែរឿងក្តីនេះ គឺជារឿងក្តីដែលទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ (បណ្តឹងទាក់ទងនឹងការចុះបញ្ជី) ដូច្នេះ តុលាការដែលមានសមត្ថកិច្ចទៅលើ "ទីកន្លែងដែលត្រូវចុះបញ្ជី" មានសមត្ថកិច្ចជម្រះក្តី (ចំណុច ជ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ "ទីកន្លែងដែលត្រូវចុះបញ្ជី" គឺជា "រដ្ឋបាលសុរិយោដី រាជធានី ខេត្តដែលអចលនវត្ថុស្ថិតនៅ (ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ ដោយសារតែអចលនវត្ថុស្ថិតនៅខេត្តរតនគិរី ដូច្នេះហើយ រដ្ឋបាលសុរិយោដីខេត្តរតនគិរី គឺជា "ទីកន្លែងដែលត្រូវចុះបញ្ជី" ហើយសាលាដំបូងខេត្តរតនគិរីដែលមានសមត្ថកិច្ចនៅទីនោះ ក៏មានសមត្ថកិច្ចជម្រះក្តីដែរ។

ដើមចោទ អាចដាក់ពាក្យបណ្តឹងទៅតុលាការណាមួយក៏បានដូចជាសាលាដំបូងរាជធានីភ្នំពេញ ឬ សាលាដំបូងខេត្តរតនគិរី ប៉ុន្តែ នៅក្នុងរឿងក្តីនេះ ដោយសារតែដើមចោទកំពុងរស់នៅខេត្តរតនគិរី ហេតុនេះក៏បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងខេត្តរតនគិរី។

[4] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[5] អ្នកចុះបញ្ជី គឺជាមន្ត្រីសុរិយោដី (ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី (តទៅនៅពេលដែលហៅដោយសង្ខេបថា "ប្រកាសអន្តរក្រសួង" ដែលសំដៅទៅលើប្រកាសអន្តរក្រសួងនេះ ) មាត្រា ៩០) មិនមែនជាចុងចម្លើយទេ។ ចុងចម្លើយមានកាតព្វកិច្ចធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី (មាត្រា ១០ កថាខណ្ឌទី ១ នៃប្រកាសអន្តរក្រសួង) ពោលគឺ ចុងចម្លើយមានកាតព្វកិច្ចមិនលើសពីការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជីឡើយ។ នៅពេលដែលសាលក្រមបង្គាប់ទៅចុងចម្លើយអំពីការត្រូវធ្វើការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជី (ធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី) បាន ចូលជាស្ថាពរ នឹងត្រូវបានចាត់ទុកថា ចុងចម្លើយបានធ្វើការបង្ហាញឆន្ទៈនៅពេលចូលជាស្ថាពរនោះ (មាត្រា ៥២៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ជាងនេះទៅទៀត ដើមចោទដែលជាអ្នកមានសិទ្ធិចុះបញ្ជីនៅពេលដែលទទួលបានសាលក្រមស្ថាពរដែលបង្គាប់អំពីនីតិវិធីចុះបញ្ជីមកធ្វើជាលិខិតអនុវត្ត គឺអាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន (មាត្រា ១០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ មន្ត្រីសុរិយោដីនឹងមានកាតព្វកិច្ចចុះបញ្ជីនៅពេលដែលចាប់ផ្តើមមានពាក្យសុំ (ប្រកាសដដែល មាត្រា ៦ កថាខណ្ឌទី ២)។ វានឹងមិនអាចទៅរួចឡើយដែលមន្ត្រីសុរិយោដីមានកាតព្វកិច្ចចុះបញ្ជី ទាំងពុំមានពាក្យសុំពីភាគី។

[6] តុលាការត្រូវសម្រេចសេចក្តីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ (កថាខណ្ឌទី ៣ មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយ ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី (មាត្រា ៦៤ កថាខណ្ឌទី ១)។

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ [7]

### ខ.១. ការបង្កើតកិច្ចសន្យាលក់ទិញ [8]

**ខ.១.១.** នៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដើមចោទបានលក់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដី L") ក្នុងតម្លៃ ១០០.០០០ (មួយសែន) ដុល្លារអាមេរិកទៅឲ្យចុងចម្លើយ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ") ។ **(ភស្តុតាង $X_1$)**

**ខ.១.២.** ដើមចោទ និង ចុងម្លើយបានធ្វើលិខិតយថាភូត (លិខិតលក់ផ្តាច់) ចំពោះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ។ **( ភស្តុតាង $X_1$)**

**ខ.១.៣.** ចំពោះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងគ្នាដូចខាងក្រោមអំពីកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់៖

- **ក.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនៃថ្លៃលក់ នឹងបង់នៅពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។
- **ខ.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះ នឹងត្រូវបង់នៅក្នុងអំឡុងពេល ១ខែ គិតចាប់ពីពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

---

[7] អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមរដ្ឋប្បវេណី)។

ម្យ៉ាងទៀត នៅក្នុងពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង (កថាខណ្ឌទី ៣ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[8] កិច្ចសន្យាលក់ទិញ អាចត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ (មាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី)។ ចំពោះ "បញ្ញត្តិពិសេសក្នុងច្បាប់" មានដូចជា កថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី។ ពោលគឺ ក្នុងករណីកិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាដែល "ភាគីម្ខាងមានករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ" កិច្ចសន្យានេះ នឹងមានអានុភាពលុះត្រាតែបានធ្វើលិខិតយថាភូត (កថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី)។ ចំពោះអត្ថន័យនៃ "លិខិតយថាភូត" ក្នុងកថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី ត្រូវបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

## ខ.២. ការរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុចុងចម្លើយមិនអនុវត្តកាតព្វកិច្ច [9]

ខ.២.១. នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដើមចោទ និង ចុងចម្លើយបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលទៅរដ្ឋបាលសុរិយោដីខេត្តរតនគិរីដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ"។ **(ភស្តុតាង $X_2$)**

ខ.២.២. ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ បានកន្លងផុត។

ខ.២.៣. នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ ដើមចោទបានដាស់តឿន[10]ទៅចុងចម្លើយឲ្យបង់ប្រាក់ថ្លៃលក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះ

---

[9] ភាគីម្ខាងនៃកិច្ចន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀត "បំពានកិច្ចសន្យាធ្ងន់ធ្ងរ" (មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី)។

ជាដំបូង កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាដែលភាគីម្ខាងហៅថា អ្នកលក់មានករណីកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់ (មាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ កិច្ចសន្យានេះ គឺជាកិច្ចសន្យាអញ្ញមញ្ញ។

បន្ទាប់មកទៀត ចំពោះខ្លឹមសារនៃ "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" គឺត្រូវបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី។ ភាគីម្ខាងនៃកិច្ចសន្យាដែលចង់រំលាយកិច្ចសន្យាអញ្ញមញ្ញ ចាំបាច់ត្រូវអះអាងអំពីមូលហេតុដែលត្រូវបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រាដដែលនេះ។

ហើយ ភាគីម្ខាងនៃកិច្ចសន្យាដែលមានសិទ្ធិរំលាយកិច្ចសន្យា អាចរំលាយកិច្ចសន្យាដោយការបង្ហាញឆន្ទៈអំពីការរំលាយទៅភាគីម្ខាងទៀតបាន។ **ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាអាចធ្វើឡើងនៅក្រៅតុលាការបាន (កថាខណ្ឌទី ១ មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី) ដើម្បីអះអាងអំពីការរំលាយកិច្ចសន្យា ពុំចាំបាច់ធ្វើការដាក់ពាក្យបណ្ដឹងទេ។**

**ការរំលាយកិច្ចសន្យានាំឲ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត (កថាខណ្ឌទី ១ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី)។ម្យ៉ាងវិញទៀត ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ ត្រូវមានករណីកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឲ្យភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយ (កថាខណ្ឌទី ២ មាត្រា ៤១១នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលដើមចោទពុំមានតាវកាលិកដែលចង់ទាមទារឲ្យចុងចម្លើយដែលជាភាគីម្ខាងទៀតសងមកវិញទេនោះ គ្រាន់តែបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាទៅកាន់ចុងចម្លើយនៅក្រៅតុលាការ គឺជាការគ្រាប់គ្រាន់ ហើយពុំចាំបាច់ដាក់ពាក្យបណ្ដឹងមកកាន់តុលាការទេ។**

[10] នៅក្នុងរឿងក្ដីនេះ ដោយហេតុថា ដើមចោទកំពុងតែអះអាងអំពី "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" ផ្អែកតាមចំណុច ក កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី ដូច្នេះហើយ ចាំបាច់ត្រូវតែអះអាងអំពី ① កាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់ (ថ្ងៃទី ៣១ ខែ វិច្ឆិកា ឆ្នាំ ២០១៨) បានកន្លងផុត ("ខ.២.១." និង "ខ.២.២.") និង ② ការបានដាស់តឿនដោយកំណត់អំឡុងពេលសមរម្យ ("ខ.២.៣.")។

នៅក្នុងអំឡុងពេល២សប្តាហ៍ ជាមួយគ្នានេះ ក៏បានធ្វើការបង្ហាញឆន្ទៈ[11] អំពីការរំលាយ "កិច្ចសន្យានៃរឿងក្ដីនេះ" នៅពេលដែលមិនបានបង់ប្រាក់ថ្លៃលក់នៅក្នុងអំឡុងពេល ២សប្តាហ៍។ **(ភស្តុតាង $X_3$)**

**ខ.២.៤.** ចុងចម្លើយមិនបានបង់ប្រាក់ថ្លៃលក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះទេ គិតមកដល់ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ។[12]

**ខ.២.៥.** នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ បានផ្ដល់នូវការប្រគល់ "ដីL" ទៅចុងចម្លើយ ផ្អែកតាម "កិច្ចសន្យានៃរឿងក្ដីនេះ" ។[13] **(ភស្តុតាង $X_4$)**

**ដូច្នេះ ដើមចោទទាមទារឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" ដោយផ្អែកលើកការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ"។**[14]

## គ. ប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដីនៃរឿងក្ដីនេះ គប្បីជាបន្ទុករបស់ចុងចម្លើយ (កថាខណ្ឌទី ១ មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

---

[11] ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យា អាចដាក់លក្ខខណ្ឌបង្អង់បាន (កថាខណ្ឌទី ៣ មាត្រា ៤០៩ និង វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្ដីនេះ នៅពេលដែលបង្ហាញឆន្ទៈរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ដើមចោទបានដាក់លក្ខខណ្ឌបង្អង់ថា "បើមិនបង់ប្រាក់នៅក្នុងអំឡុងពេលដាស់តឿន (អំឡុងពេល ២សប្តាហ៍) ។

[12] ដើមចោទអះអាងអំពីលក្ខខណ្ឌបង្អង់ ( លក្ខខណ្ឌដែលលើកឡើងថា "មិនបង់ប្រាក់នៅក្នុងអំឡុងពេលដាស់តឿន") ដែលបានដាក់នៅពេលបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យា គឺត្រូវបានបំពេញ (កថាខណ្ឌទី ៣ មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី)។

[13] អ្នកទិញអាចមិនព្រមបង់ប្រាក់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់បានផ្ដល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន (កថាខណ្ឌទី ១ មាត្រា ៥៥៨ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះហើយ ទោះបីជាអ្នកទិញមិនបានអនុវត្តកាតព្វកិច្ចបង់ថ្លៃទិញក៏ដោយ ដរាបណានៅក្នុងអំឡុងពេលដែលត្រូវទទួលនូវការផ្ដល់ការសងកាតព្វកិច្ចរបស់អ្នកលក់ គឺមិនអាចនិយាយថា "បំពានកិច្ចសន្យាធ្ងន់ធ្ងរ"បានទេ។

នៅក្នុងរឿងក្ដីនេះ ដើមចោទដែលជាអ្នកលក់ ក្រៅពីមានករណីយកិច្ចធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ នៅមានករណីយកិច្ចប្រគល់ដី L (មាត្រា ៥៣០ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ បើសិនជាមិនអះអាងអំពីការបានធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិ ("ខ.២.១.") ហើយបន្ថែមនូវការអះអាងអំពីការបានផ្ដល់នូវការប្រគល់ដី L ("ខ.២.៥.") ទេនោះ មិនអាចនិយាយបានថា ការមិនអនុវត្តករណីយកិច្ចបង់ថ្លៃទិញរបស់ចុងចម្លើយ គឺជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" បានទេ។

[14] បញ្ជាក់ឲ្យបានច្បាស់អំពីសារធាតុគតិយុត្តនៃសិទ្ធិទាមទារ។

## ខ. ភស្តុតាង

១. លិខិតលក់ផ្តាច់ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ **(ភស្តុតាង $X_1$)**

២. ច្បាប់ចម្លងនៃពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ **(ភស្តុតាង $X_2$)**

៣. រូបថត (សារនៅក្នុងTelegram ដែលត្រូវបានផ្ញើទៅមករវាងដើមចោទ និង ចុងចម្លើយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩) **(ភស្តុតាង $X_3$)**

៤. រូបថត (សារនៅក្នុងTelegram ដែលត្រូវបានផ្ញើទៅមករវាងដើមចោទ និង ចុងចម្លើយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨) **(ភស្តុតាង $X_4$)**

សេចក្តីដូចមានកំណត់ សូម **លោកប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។ សូម **លោកប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ខេត្តរតនគិរី, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្ដឹងឧទ្ធរណ៍

នាងខ្ញុំ/ខ្ញុំបាទឈ្មោះ.................... ភេទ.......... អាយុ..........ឆ្នាំ មុខរបរ.......... មានទីលំនៅ ភូមិ....................
ឃុំ.................... ស្រុក.................... ខេត្ត.................... ជា.................... លេខទូរស័ព្ទ:....................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូង....................**

*សូមមេត្តាជ្រាប:*

**កម្មវត្ថុ:** សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រម.................... លេខ:..........ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ..........
របស់សាលាដំបូងខេត្ត.......... ត្រង់សេចក្ដីសម្រេចទាំងមូល។

**យោង:** -សំណុំរឿង....................លេខ:..........ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... របស់សាលាដំបូងខេត្ត..........។
-សាលក្រមលេខ:..........ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... របស់សាលាដំបូងខេត្ត..........។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំ/ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: កាលពីថ្ងៃទី.......... ខែ.......... ឆ្នាំ.......... វេលាម៉ោង.......... និង..........នាទី សាលាដំបូងខេត្ត.......... បានបើក.................... លើសំណុំរឿង....................លេខ:.......... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... ដែលមានរូបនាងខ្ញុំ/ខ្ញុំបាទ ជា.......... ហើយបានសម្រេចចេញសាលក្រមលេខ:..........ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... របស់សាលាដំបូងខេត្ត..........។ ការសម្រេចនៅក្នុងសាលក្រមខាងលើនេះ គឺមានភាពអយុត្តិធម៌ និងធ្វើឲ្យបាត់បង់ផលប្រយោជន៍របស់នាងខ្ញុំ/ខ្ញុំបាទ ហេតុនេះហើយបានជានាងខ្ញុំ/ខ្ញុំបាទ សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមលេខ:..........ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.......... របស់សាលាដំបូងខេត្ត.......... ត្រង់សេចក្ដីសម្រេចទាំងមូល។

អាស្រ័យហេតុបានគោរពជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាទទួល និងបញ្ជូនទៅសាលាឧទ្ធរណ៍ ដើម្បីជួយរកយុត្តិធម៌ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ/ខ្ញុំបាទ។

ថ្ងៃ.................... ខែ.......... ឆ្នាំ....................ពស..........
ធ្វើនៅ...................., ថ្ងៃទី.......... ខែ.......... ឆ្នាំ..........
**ស្នាមមេដៃស្ដាំ**

ឈ្មោះ ....................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹងសាទុក្ខ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................. ភេទ........ អាយុ........ឆ្នាំ ជនជាតិ........ សញ្ជាតិ........ មានទីលំនៅភូមិ............. ឃុំ............. ស្រុក............. ខេត្ត............. ជា.........................។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាឧទ្ធរណ៍**

សូមមេត្តាជ្រាប។

**កម្មវត្ថុ:** សុំប្តឹងសាទុក្ខនឹងសាលដីកា................លេខ:...........ចុះថ្ងៃទី........ ខែ........ ឆ្នាំ........ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

<u>**យោង:**</u> សំណុំរឿងព្រហ្មទណ្ឌលេខ:............... ចុះថ្ងៃទី........ ខែ........ ឆ្នាំ........ របស់សាលាឧទ្ធរណ៍។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយស សូមជំរាបឯកឧត្តមប្រធានមេត្តាជ្រាបថា: កាលពីថ្ងៃទី.......... ខែ............ ឆ្នាំ........... សាលាឧទ្ធរណ៍បានបើកសវនាការលើសំណុំរឿង..................លេខ:......... ចុះថ្ងៃទី......... ខែ........... ឆ្នាំ........... ដោយបានកាត់សេចក្តីយ៉ាងអយុត្តធម៌ ចំពោះរូបខ្ញុំបាទ/នាងខ្ញុំ។ ហេតុដូច្នេះ ខ្ញុំបាទ/នាងខ្ញុំសុំប្តឹងសាទុក្ខនឹងសាលដីកាលេខ:........... ចុះថ្ងៃទី......... ខែ............ ឆ្នាំ........... ត្រង់ចំណុចសាលដីកាទាំងមូល។

អាស្រ័យហេតុដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ សូមឯកឧត្តម មេត្តាអនុញ្ញាតិអោយខ្ញុំបាទ/នាងខ្ញុំបានប្តឹងសាទុក្ខនឹងសាលដីកាខាងលើ ដោយក្តីអនុគ្រោះ។

សូមឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ.................. ខែ.............ឆ្នាំ................. .ព.ស...........

ធ្វើនៅ...................., ថ្ងៃទី......... ខែ.......... ឆ្នាំ.........

**ស្នាមមេដៃស្តាំ**

ឈ្មោះ..................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# **ពាក្យបណ្តឹងជំទាស់**

ខ្ញុំបាទឈ្មោះ.................... ភេទ...... អាយុ...... ឆ្នាំ ជនជាតិ...... សញ្ជាតិ...... មុខរបរ...... អត្តសញ្ញាណប័ណ្ណលេខ:............ ចុះថ្ងៃទី...... ខែ...... ឆ្នាំ...... មានទីលំនៅបច្ចុប្បន្នភូមិ........ ឃុំ........ ស្រុក........ ខេត្ត........។

**សូមគោរពជូន**
**លោកប្រធានគណៈកម្មការរដ្ឋបាល**

**កម្មវត្ថុ:** សំណើសុំប្តឹងជំទាស់ នៃការធ្វើប័ណ្ណកម្មសិទ្ធិអោយឈ្មោះ________ ភេទ____ អាយុ____ ឆ្នាំ ជនជាតិ____ សញ្ជាតិ____ មុខរបរ____ មានទីលំនៅបច្ចុប្បន្នភូមិ________ ឃុំ________ ស្រុក________ ខេត្ត________ នៅលើក្បាលដីលេខ________ ស្ថិតនៅភូមិ________ ឃុំ________ ស្រុក________ ខេត្ត________។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា: ដីរបស់ខ្ញុំបាទចំនួនមួយកន្លែង មានក្បាលដីលេខ________ ស្ថិតនៅភូមិ________ ឃុំ________ ស្រុក________ ខេត្ត________ បានទិញពីឈ្មោះ________ ភេទ____ អាយុ____ ឆ្នាំ ជនជាតិ____ សញ្ជាតិ____ មុខរបរ____ មានទីលំនៅបច្ចុប្បន្នភូមិ________ ឃុំ________ ស្រុក________ ខេត្ត________ ក្នុងអំឡុងឆ្នាំ________ លុះដល់ឆ្នាំ________ ឈ្មោះ________បានសុំជួលដីពីខ្ញុំបាទ ដើម្បីបង្កបង្កើនផល និងបានអោយថ្លៃឈ្នួលដីស្រែបានចំនួន____ ក្នុងមួយឆ្នាំ ហើយបានបន្តជួលមកដល់ឆ្នាំ________ ឈ្មោះ________ បានប្រកាសថា ដីស្រែនេះគឺជាដីរបស់គាត់ទៅវិញ រហូតដល់មានការប្តឹងផ្តល់គ្នា ដល់________________។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាជួយផ្អាកការចេញប័ណ្ណកម្មសិទ្ធិជូនឈ្មោះខាងលើ តាមបណ្តឹងខ្ញុំបាទ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ។

ថ្ងៃ________ ខែ______ ឆ្នាំ________ពស ២៥___
ធ្វើនៅ________, ថ្ងៃទី______ ខែ______ ឆ្នាំ២០___

**ស្នាមមេដៃស្តាំ**

**•ឯកសារភ្ជាប់:**

•________

•________

ឈ្មោះ ________

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុវត្តដោយបណ្ដោះអាសន្ន

ម្ចាស់បំណុលអនុវត្តៈ ឈ្មោះ.......................តំណាងស្របច្បាប់ដោយលោក.................................តួនាទី ................អាស័យដ្ឋាននៅ....................។

កូនបំណុលអនុវត្តៈ ឈ្មោះ...........ភេទ................កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេ....................... អាស័យដ្ឋាននៅ................ភូមិ............................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន**..................................................

**កម្មវត្ថុ** សុំអនុវត្តបណ្ដោះអាសន្ន ត្រង់សេចក្ដីសម្រេចបញ្ចប់ ចំណុចទី.........នៃសាលក្រមរដ្ឋប្បវេណី លេខ........ចុះថ្ងៃទី.........ខែ.......ឆ្នាំ ២០........របស់ .....................លើអចលនវត្ថុដែលជា .......................មានផ្ទៃក្រឡា..................ម៉ែត្រការេ ជាទីលំនៅដ្ឋាន មានទីតាំងស្ថិតនៅ ...............................ដើម្បីលក់ឡាយឡុងសងបំណុលមកឲ្យ.......................

យោង -សាលក្រមរដ្ឋប្បវេណីលេខ.....ចុះថ្ងៃទី.........ខែ.........ឆ្នាំ២០..............របស់សាលាដំបូង ខេត្ត/ក្រុង......................

-រូបមន្តអនុវត្តសាលក្រមលេខ...........ចុះថ្ងៃទី.......ខែ...........ឆ្នាំ ២០..................។

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុលេខ ចុះថ្ងៃទី.........ខែ..........ឆ្នាំ២០...........។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជូន **ឯកឧត្តមប្រធាន** មេត្តាជាបថាៈ កាលថ្ងៃទី.............ខែ................ឆ្នាំ ..............របស់...........បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ លើសំណុំរឿងរដ្ឋប្បវេណីលេខ.........ចុះថ្ងៃទី............ខែ..................ឆ្នាំ២០.....ដោយបានសេចក្ដីសម្រេចតាម សាលក្រមរដ្ឋប្បវេណីលេខ..............ចុះថ្ងៃទី.......ខែ.........ឆ្នាំ២០.........របស់........................ត្រង់ចំណុចទី .....នៃវិនិច្ឆ័យសេចក្ដីសម្រេចបញ្ចប់ដែលមានខ្លឹមសារថាៈ សាលក្រមនេះមានអនុភាពអនុវត្តជាបណ្ដោះអាសន្ន បានត្រង់វិនិច្ឆ័យទី........មានខ្លឹមសារាថាៈ បង្គាប់ឲ្យចុងចម្លើយឈ្មោះ.........................សងប្រាក់ដើមចំនួន ..................ឲ្យដើមចោទ..................។

ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលអនុវត្ត ស្របតាមខ្លឹមសារ នៃសាលក្រមរដ្ឋប្បវេណីលេខ ...... ចុះថ្ងៃទី.........ខែ.........ឆ្នាំ............ខ្ញុំបាទ/នាងខ្ញុំស្នើសុំអនុវត្តជាបណ្ដោះអាសន្ននូវចំណុចខាងលើ ដើម្បី លក់ឡាយឡុងសងបំណុលមកម្ចាស់បំណុលអនុវត្ត ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមប្រធាន មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ/ នាងខ្ញុំ ដូចបាន បញ្ជាក់ក្នុងកម្មវត្ថុខាងលើដោយក្ដីអនុគ្រោះ ។

សូម ឯឧត្តមប្រធាន ទទូលកាគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ ........ឆ្នាំ............

**ស្នាមមេដៃស្ដាំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំដកពាក្យបណ្ដឹង

ខ្ញុំបាទឈ្មោះ............................ មានអាសយដ្ឋានផ្ទះលេខ.........ផ្លូវលេខ.......... ភូមិ..................ឃុំ/សង្កាត់.......... ..........................................................................................ទូរសព្ទ...................។

**សូមគោរពជូន**
**លោកប្រធានសាលាដំបូង**.....................

**កម្មវត្ថុ៖** សំណើសុំដកពាក្យបណ្ដឹងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ............. ខែ...... ឆ្នាំ ២០.....
**យោង៖** សំណុំរឿងរដ្ឋប្បវេណីលេខ ......... ចុះថ្ងៃទី ..... ខែ........ ឆ្នាំ ២០.........

តបតាមកម្មវត្ថុ និងយោងខាងលើ សូម**លោកប្រធាន**ជ្រាបថា៖ កាលពីថ្ងៃទី....................ខ្ញុំបាទបានដាក់ពាក្យប្ដឹង ឈ្មោះ ................. ភេទ..... អាយុ.........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ............... មានទីលំនៅបច្ចុប្បន្ននៅភូមិ....... ឃុំ/សង្កាត់............. ស្រុក/ខណ្ឌ.......... ខេត្ត/ក្រុង............។ បន្ទាប់ពីតុលាការចេញដីកាកោះក្នុងនីតិវិធីត្រៀម កូនបំណុលក៏យល់ព្រមសង្គ្រោះតាមកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគឡើងវិញបន្ទាប់ពីបានពីឯកភាពគ្នាទាំងស្រុង ហេតុដូច្នេះទើបខ្ញុំបាទ សម្រេចចិត្តសុំដកពាក្យបណ្ដឹងដើម្បីបញ្ចប់នីតិវិធី។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ ដូចមានក្នុងកម្មវត្ថុខាងលើ ដោយក្ដីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ........... ថ្ងៃទី...........ខែ........ ឆ្នាំ ២០.....
ស្នាមមេដៃស្ដាំ

**ឈ្មោះ**

# ឧបសម្ព័ន្ធទី២
# គំរូសាលក្រម សាលដីកា
# ដីកាសម្រេច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**

សំណុំរឿងលេខ ........

ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩

សាលក្រមលេខ ........

ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៩

**សាលក្រម**[1]

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**[2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ

ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៩[3][4]

**ចៅក្រមជំនុំជម្រះ**

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

---

[1] ការសម្រេចសេចក្តី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្តីដាក់នៅត្រង់ចំណុចចាប់ផ្តើម។ ដោយសារតែ សាលក្រម និង ដីកាសម្រេចមានភាពខុសគ្នាចំពោះវិធីក្នុងការធ្វើឧបាស្រ័យជាអាទិ៍ ។ ជាគោលការណ៍បណ្តឹងឧបាស្រ័យចំពោះសាលក្រម គឺ បណ្តឹងឧទ្ធរណ៍ ហើយ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច គឺ បណ្តឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] សាលក្រមរដ្ឋប្បវេណីត្រូវតែសរសេរអំពីចំណុចដែលចែងនៅក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ខ ។ សាលក្រមនឹងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិនាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ២) ហេតុនេះ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់អំពី ពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ សាលក្រមគឺជាការសម្រេចសេចក្តីរបស់តុលាការដែលត្រូវបានធ្វើឡើងដោយកំណត់ជាមុននូវទំនាក់ទំនងអង្គហេតុគិតមកដល់ត្រឹមថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[4] ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧ នៃក្រមរដ្ឋប្បវេណី)។ ហើយការប្រកាសសាលក្រមចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (កថាខណ្ឌទី ១ មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឲ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ..............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ................................................

លេខទូរស័ព្ទ ៖ ...............................................................................................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ .......................................

លេខទូរស័ព្ទ ៖ ...............................................................................................

**អង្គហេតុ និងចំណុចវិវាទ**

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

(១) បង្គាប់ឲ្យចុងចម្លើយប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ[5]ឲ្យទៅដើមចោទ។

(២) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។

(៣) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

## ខ. ដំណើររឿងក្ដី និង ចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្ដី

នៅក្នុងរឿងក្ដីនេះ ដើមចោទបានទាមទារនូវការប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដី L") និង ការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើអចលនវត្ថុដដែលដោយផ្អែកលើកិច្ចសន្យាលក់ទិញចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ពីចុងចម្លើយ។

### ខ.២. អង្គហេតុដែលគ្មានវិវាទ[6]

ខ.២.១. នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ ដើមចោទបានទិញ "ដី L" ក្នុងតម្លៃ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិកពីចុងចម្លើយ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ")។

[5] ឧបសម្ព័ន្ធ ជាឯកសារមួយដែលបានបង្កើតដើម្បីដាក់បញ្ចូលព័ត៌មាននោះ ហើយជាផ្នែកតែមួយនៃឯកសារដើម។ ដូច្នេះហើយចំពោះអនុសារនៃសាលក្រម (កថាខណ្ឌទី ២ មាត្រា ១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ក៏ ប្រាកដជាត្រូវតែ**ធ្វើឡើងដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធ**ផងដែរ។ ឧបសម្ព័ន្ធ គឺជាគ្រាន់តែសរសេរដើម្បីធ្វើការសរុបនូវខ្លឹមសារមួយផ្នែកដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ដោយផ្អែកធ្វើការពិចារណាអំពីភាពងាយស្រួលនៃការអានខ្លឹមសារទាំងស្រុងនៃអត្ថបទ។ ប្រសិនបើនៅក្នុង លិខិតសាលក្រម មានការដកស្រង់ខ្លឹមសារទៅដាក់នៅក្នុងឧបសម្ព័ន្ធនោះមានន័យថា គេគ្រាន់តែបានយកខ្លឹមសារមួយផ្នែកដែលមានភាពចាំបាច់ត្រូវសរសេរនៅក្នុងលិខិតសាលក្រមមកសរសេរសរុបដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ហើយ**ខ្លឹមសារនៃលិខិតសាលក្រមក៏រួមបញ្ចូលទាំងឧបសម្ព័ន្ធ**ផងដែរ។

រីឯ ឯកសារភ្ជាប់ ជាឯកសារដែលគេបានយកមកភ្ជាប់ជាមួយឯកសារដើម ហើយឯកសារភ្ជាប់នេះមិនមែនជាផ្នែកមួយនៃឯកសារដើមឡើយ។

[6] មាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំណុចនេះនឹងត្រូវសរសេរអំពីអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា អត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្ដែង។

**ខ.២.២.** "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ត្រូវបានធ្វើឡើងជាលិខិតយថាភូត[7]។

**ខ.២.៣.** ដើមចោទបានព្រមព្រៀងបង់ប្រាក់កក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកចំពោះការចុះ "កិច្ចសន្យានៃរឿងក្ដីនេះ" ជាមួយចុងចម្លើយ ហើយបានប្រគល់ប្រាក់នេះឲ្យទៅចុងចម្លើយ។

**ខ.២.៤.** នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ ចុងចម្លើយបានធ្វើសំណើផ្ដល់ [8]ប្រាក់ជាក់ស្ដែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកនៅផ្ទះរបស់ដើមចោទ (ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់ទំនប់ទឹក ខណ្ឌចំការមនរាជធានីភ្នំពេញ) ហើយបានបង្ហាញឆន្ទៈថា នឹងរំលាយ "កិច្ចសន្យានៃរឿងក្ដីនេះ" [9]។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យអំពីការទាមទារ

ផ្អែកតាមអង្គហេតុដែលគូភាគីគ្មានវិវាទ តុលាការទទួលស្គាល់ថា "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ត្រូវបានចុះរវាងដើមចោទ និង ចុងចម្លើយមានសុពលភាព ប៉ុន្តែចុងចម្លើយដែលជាភាគីអ្នកលក់បានរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ដោយធ្វើសំណើផ្ដល់ប្រាក់ជាក់ស្ដែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែលជាចំនួនទឹកប្រាក់ពីរដងនៃចំនួនប្រាក់កក់ដែលត្រូវបានប្រគល់នៅពេលចុះ "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" (យោងមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី)។

ដូច្នេះហើយ ការទាមទាររបស់ដើមចោទដែលទាមទារនូវការប្រគល់ "ដី L" និងការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" គឺពុំមានមូលហេតុទេ (កថាខណ្ឌទី ១ មាត្រា ៤១៤ និង កថាខណ្ឌទី ១ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី )។

---

[7] ក្រមរដ្ឋប្បវេណី មាត្រា ៣៣៦ កថាខណ្ឌទី ២។ អង្គហេតុដែលមានភាពចាំបាច់ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នូវ "កិច្ចសន្យានៃរឿងក្ដីនេះ" ដែលបានបង្កើតឡើងដោយមានសុពលភាព។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្ដឹង។)

[8] ការពន្យល់លម្អិតអំពីពាក្យថា "ការធ្វើសំណើផ្ដល់ជាក់ស្ដែង" សូមយោងតាម Footnote នៃឯកសារចម្លើយ។

[9] មាត្រា ៥១៨ មាត្រា ៤១៤ កថាខណ្ឌទី ១ មាត្រា ៤០៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃឯកសារចម្លើយ។)

## ខ. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី

ដោយសារតែការទាមទារទាំងអស់របស់ដើមចោទពុំមានមូលហេតុ ដូច្នេះ ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ដើមចោទ (មាត្រា ៦៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## សេចក្តីសម្រេចបញ្ចប់

១. ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនការជាសាធារណៈនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៩ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃអង្គារ ១១ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃ ទី៣០ ខែ មេសា ឆ្នាំ២០១៩

**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**

សំណុំរឿងរដ្ឋប្បវេណី
លេខ:
ចុះថ្ងៃទី ខែ ឆ្នាំ
**សាលដីកា**
**លេខ:** ( )
ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**

បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ២ និង ៣០ នាទី (រសៀល) នៅសាលសវនាការទី១ សាលាឧទ្ធរណ៍ត្បូងឃ្មុំ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម **ម៉ុង មុនីចរិយា** ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ឯកឧត្តម **រៀល សុតិន** ជាចៅក្រមប្រឹក្សា
លោកស្រី **ខៀវ ផាន់ណា** ជាចៅក្រមប្រឹក្សា

**ក្រឡាបញ្ជី**

លោក **ស៊ឹម សុភា** ជាក្រឡាបញ្ជី

សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សការដ្ឋប្បវេណីសាលាឧទ្ធរណ៍ត្បូងឃ្មុំ ជាវិវាទរវាង៖

គូភាគី៖

-ដើមចោទ៖ ឈ្មោះ ភេទស្រី អាយុ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ:
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវជាតិលេខ ភូមិ សង្កាត់គីឡូម៉ែត្រលេខ ខណ្ឌ រាជធានីភ្នំពេញ។ *(ដើមបណ្តឹងឧទ្ធរណ៍)*

- លោក ជាមេធាវីតំណាងដោយអាណត្តិ

-សហចុងចម្លើយ៖ ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជាតិខ្មែរ និងប្រពន្ធឈ្មោះ អាយុ ឆ្នាំ រស់នៅភូមិ ឃុំ ស្រុក ខេត្ត ។ *(សហចុងបណ្តឹងឧទ្ធរណ៍)*

-និងតតិយជន៖ ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។ *(សហចុងបណ្តឹងឧទ្ធរណ៍)*

-មានលោកមេធាវី ជាមេធាវីតំណាងដោយអាណត្តិ

**១. អំពីអង្គហេតុ និងចំណុចវិវាទ**

**១-១-ទិមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

ក.សុំទទួលស្គាល់ឈ្មោះ ជាកម្មសិទ្ធិករលើដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ. ចុះថ្ងៃទី ខែ. ឆ្នាំ ចេញដោយប្រធានមន្ទីរសុរិយោដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ។

ខ.បង្គាប់ឱ្យសហចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឱ្យឈ្មោះ ជាកម្មសិទ្ធិករលើដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ចេញដោយប្រធានមន្ទីរសុរិយោដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ចុះថ្ងៃទី ខែ ឆ្នាំ ។

គ. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ។

**១-២-ទិមសារនៃសាលក្រមដែលតតិយជនទាមទារ៖**

ក.ស្នើសុំឱ្យឈ្មោះ និងប្រពន្ធឈ្មោះ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិនូវអចលនវត្ថុដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ: ស្ថិតនៅផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្តកំពង់ចាម ឱ្យភាគីដើមចោទឈ្មោះ និងនាងខ្ញុំជាពីរចំណែកស្មើគ្នា។

ខ.បង្គាប់ឱ្យភាគីដើមចោទឈ្មោះ និងនាងខ្ញុំបំបែកក្បាលដីលេខ ស្ថិតនៅផ្លូវជាតិ ជាពីរចំណែកស្មើគ្នា ។

**១-៣-ការពន្យល់ត្រួសៗអំពីរឿងក្តី**

សហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ បានលក់ដីមានប័ណ្ណសម្គាល់សិទ្ធិកាន់កាបអចលនវត្ថុលេខ: ចុះថ្ងៃទី ស្ថិតនៅ , មានទំហំ ឱ្យទៅឈ្មោះ និងឈ្មោះ ។ ក្រោយមកឈ្មោះ បានផ្ទេរចំណែករបស់ខ្លួនឱ្យឈ្មោះ ដែលជាតតីយជន។ រវាងឈ្មោះ និងឈ្មោះ បានព្រមព្រៀងគ្នាថា ចែកចំណែកដីនោះដោយឱ្យមន្ត្រីសុរិយោដីបំពេញទម្រង់បែបបទ ដើម្បីធ្វើការបំបែកក្បាលដី។ លុះក្រោយមកឈ្មោះ បានទទួលមរណៈភាព។ នៅក្នុងរឿងនេះ ឈ្មោះ បានប្តឹងសុំឱ្យទទួលស្គាល់ជាម្ចាស់កម្មសិទ្ធិលើដីនោះ ហើយឈ្មោះ ក៏បានដាក់ពាក្យបណ្តឹងអន្តរាគមន៍ជាតតីយជន ដោយទាមទារឱ្យទទួលស្គាល់ជាម្ចាស់កម្មសិទ្ធិលើចំណែកពាក់កណ្តាលនៃដីនោះផងដែរ ។

-បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងខេត្តកំពង់ចាម ដែលសម្រេចសេចក្តីដូចខាងក្រោម៖

២-បង្គាប់ឱ្យឈ្មោះ និងប្រពន្ធឈ្មោះ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ចុះថ្ងៃទី ខែ. ឆ្នាំ ស្ថិតនៅ ឱ្យទៅឈ្មោះ ព្រមទាំងទាយាទរបស់ មួយចំណែកខាងជើងស្មើនឹងពាក់កណ្តាលនៃដី និងឈ្មោះ មួយចំណែកខាងត្បូងស្មើនឹងពាក់កណ្តាលនៃដី ។

៣-បង្គាប់ឱ្យភាគីខាង ព្រមទាំងទាយាទរបស់ និងភាគីខាង ធ្វើនីតិវិធីបំបែក ក្បាលដីអចលនវត្ថុ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ:

ចុះថ្ងៃទី៨ ស្ថិតនៅផ្លូវជាតិលេខ៦ ភូមិបាធាយ ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម ជា ២ក្បាលដីក្នុងចំណែកស្មើគ្នា ស្របតាមចំណុចទី២ ខាងលើ ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះត្រូវបានទាញហេតុផលជាសាធារណៈនាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៩:៣០ ព្រឹក ចំពោះមុខដើមចោទ ចំពោះមុខតតិយជន និងកំបាំងមុខចុងចម្លើយ ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខៈ ០៥ ស្ន ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់ដើមចោទឈ្មោះ ។

-បានឃើញ របាយការណ៍ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍សភាវិនិច្ឆ័យសាលាឧទ្ធរណ៍ត្បូងឃ្មុំ ។

## ១-៤-<u>ដំណាក់កាលនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់</u>

-ចៅក្រមរបាយការណ៍អានរបាយការណ៍រឿង។

-ភាគីនៃបណ្តឹងឧទ្ធរណ៍សេចក្តីថ្លែងការណ៍អំពីមូលហេតុនៃបណ្តឹងឧទ្ធរណ៍។

- ដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសូមឲ្យមេធាវីតំណាងដោយអាណត្តិរបស់ខ្លួនថ្លែងការណ៍ជំនួស ។

-លោក ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ មូលហេតុដែលកូនក្តីខ្លួនប្តឹងឧទ្ធរណ៍មកនេះ គឺដោយសារកូនក្តីខ្លួនគឺជាអ្នកទិញដីនោះដោយផ្ទាល់ ហើយក៏មានការប្រគល់ទទួលលុយឲ្យទៅអ្នកលក់ផងដែរ ប៉ុន្តែស្រាប់តែមានតតិយជន និងភាគីឈ្មោះ មកអះអាងថាបានចូលហ៊ុនទិញដីជាមួយទៅវិញ ហេតុនេះហើយទើបកូនក្តីខ្លួនមិនសុខចិត្តនឹងការសម្រេចសេចក្តីរបស់សាលាដំបូងខេត្តកំពង់ចាម នេះ។ ក្នុងរឿងនេះកូនក្តីខ្លួនឈ្មោះ និងឈ្មោះ បានទិញដីដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ពីឈ្មោះ និងឈ្មោះ ហើយមានតែកូនក្តីខ្លួនតែប៉ុណ្ណោះដែលបានមកប្រគល់ប្រាក់ថ្លៃលក់ទិញដីទៅឲ្យម្ចាស់ដីដើមឈ្មោះ និងឈ្មោះ នេះ ដោយពុំមានវត្តមានអ្នកទិញណាផ្សេងមកបញ្ជាក់អះអាងថា ជាភាគីទិញដីចូលហ៊ុនគ្នាជាមួយឈ្មោះ និងប្រពន្ធឈ្មោះ នោះទេ។ បន្ថែមលើសពីនេះទៀត យោងតាមកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ បានបញ្ជាក់ថា មានតែកូនក្តីខ្លួនប៉ុណ្ណោះដែលបានទិញដីពីម្ចាស់ដីដើមឈ្មោះ និងឈ្មោះ ដូច្នេះប្រសិនបើឈ្មោះ បានចូលហ៊ុនទិញដីជាមួយឈ្មោះ និងប្រពន្ធឈ្មោះ ពិតប្រាកដមែននោះ ហេតុអ្វីបានជាឈ្មោះ មិនទៅចូលរួមប្រគល់ទទួលប្រាក់ថ្លៃលក់ទិញដីជាមួយឈ្មោះ និងប្រពន្ធឈ្មោះ នៅថ្ងៃប្រគល់ទទួលប្រាក់ ព្រោះឈ្មោះ ជាអ្នកស្រុករស់នៅជិតផ្ទះម្ចាស់ដីដើម ហើយប្រសិនបើឈ្មោះ បានចូលហ៊ុនទិញដីនេះពិតប្រាកដមែននោះ ហេតុអ្វីបានជាឈ្មោះ មិនដែលមកអះអាងប្រាប់ម្ចាស់ដីដើម ឬ អ្នកលក់ថា ខ្លួនបានចូលហ៊ុនទិញដីជាមួយឈ្មោះ និង ប្រពន្ធដែលចំណុចទាំងនេះគួរពិនិត្យ និងពិចារណា។

ការលក់ទិញដដែលបានធ្វើឡើងរវាងឈ្មោះ និងតតិយជនឈ្មោះ គឺជាការលក់ទិញដីមិនត្រឹមត្រូវនោះទេ ដោយសារឈ្មោះ ពុំមែនជាម្ចាស់ដីពិតប្រាកដ ហើយលក់ទិញដែលរៀបចំឡើងដោយភាគីទាំងពីរនេះ គឺជាការលក់ទិញដែលមានភាពមន្ទិលសង្ស័យ និងហាក់ដូចជាមានការរៀបចំឡើង

ស្នាមមេដៃជាន់គ្នាដែលមិនអាចបែងចែកបាន ហេតុដូច្នេះ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងខេត្តកំពង់ចាម និងសម្រេចតាមការស្នើសុំតាមពាក្យកែតម្រូវពាក្យបណ្ដឹងលេខ: ចុះថ្ងៃទី ខែ ឆ្នាំ ។

-លោកមេធាវី បានធ្វើសេចក្ដីសន្និដ្ឋានថា៖ ដោយផ្អែកតាមចម្លើយសាក្សីជាប្រធានភូមិបាលស្រុកបាធាយ បានបញ្ជាក់ច្បាស់ហើយថា ឈ្មោះ ឈ្មោះ និងឈ្មោះ បានមកផ្ដិតមេដៃដើម្បីបំបែកក្បាលដីជាពីរចំណែកស្មើគ្នា ប៉ុន្តែដោយពេលវាស់ជាក់ស្ដែង ដីមានធ្វើអាងស្តុកទឹក ធ្វើឲ្យវាស់ទៅលើសជាងពាក់កណ្ដាលបន្តិច អញ្ចឹងគូភាគីមិនឯកភាពគ្នា ក៏ពន្យាពេលរហូតដល់ពេលឈ្មោះ បានទៅដកប្លង់ពីសុរិយោដីវិញ។ និងបើតាមចម្លើយសាក្សីឈ្មោះ បានឆ្លើយបញ្ជាក់ថា ពិតជាមានការទិញដីចូលគ្នាពិតប្រាកដមែន។ ផ្អែកតាមចម្លើយសាក្សី ឃើញថា ភាគីឈ្មោះ ពិតជាមានទំនាក់ទំនងគតិយុត្ត ដោយបានចូលហ៊ុនគ្នាទិញដី ពិតមែន ដោយសារឈ្មោះ មានការខ្វះខាត ក៏យកដីនោះមកលក់ឲ្យកូនក្ដីរបស់ខ្លួនឈ្មោះ ក្នុងឆ្នាំ ហើយកូនក្ដីខ្លួនបានចាក់ដីតាំងពីឆ្នាំ២០១៣ មកម្លេះ ដោយពុំមានការតវ៉ាអ្វីនោះទេ។ ហេតុដូច្នេះ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ សម្រេចតម្កល់សាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល។

ចំណុចវិវាទ៖

- តើឈ្មោះ និងឈ្មោះ ពិតជាបានចូលហ៊ុនគ្នាទិញដី ដែលមានក្បាលដីលេខ: វិញ្ញាបនបត្រលេខ ពីឈ្មោះ និង មែនដែរឬទេ?
- តើឈ្មោះ ពិតជាបានលក់ដីឱ្យឈ្មោះ និងប្រពន្ធឈ្មោះ មែនឬទេ?

-ក្រោយពីបានស្ដាប់ការធ្វើសេចក្ដីថ្លែងការណ៍របស់គូភាគី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីតំណាងដោយអាណត្តិរបស់តតីយជន

-ក្រោយពីបានធ្វើការពិនិត្យកស្តុតាង និងឯកសារនានាដែលមាននៅក្នុងសំណុំរឿង

-ក្រោយពីបានពិភាក្សាគ្នា និងពិចារណាត្រឹមត្រូវតាមច្បាប់រួចរាល់ហើយ

## ២. __សំអាងហេតុ__

តាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់

ក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាឧទ្ធរណ៍ត្បូងឃ្មុំយល់ឃើញថា៖

២-១- បណ្ដឹងឧទ្ធរណ៍លេខ ០៥ស្នួន ចុះថ្ងៃទី ខែ ឆ្នាំ របស់ដើមចោទឈ្មោះ ប្ដឹងឧទ្ធរណ៍ទៅនឹងសាលក្រមរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី វិច្ឆិកាឆ្នាំ របស់សាលាដំបូងខេត្តកំពង់ចាម គ្រង់ចំណុចទាំងមូលនៃសាលក្រម បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ដែលក្រុមប្រឹក្សាជំនុំជម្រះ សការដ្ឋប្បវេណីនៃសាលាឧទ្ធរណ៍ត្បូងឃ្មុំ អាចទទួលមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន យោងតាមបញ្ញត្តិមាត្រា ២៦០ មាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-២- តាមសាលក្រមរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងខេត្តកំពង់ចាម ដែលសម្រេចសេចក្ដីដូចខាងក្រោម៖

- បង្គាប់ឱ្យឈ្មោះ និងប្រពន្ធឈ្មោះ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែល

មានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ ស្ថិតនៅ ផ្លូវជាតិលេខ ភូមិ ឃុំ ស្រុក ខេត្ត ឱ្យទៅឈ្មោះ ព្រមទាំងទាយាទរបស់ មួយចំណែកខាងជើងស្មើនឹងពាក់កណ្ដាលនៃដី និងឈ្មោះ មួយចំណែកខាងត្បូងស្មើនឹងពាក់កណ្ដាលនៃដី ។

- បង្គាប់ឱ្យភាគីខាង ព្រមទាំងទាយាទរបស់ និងភាគីខាង ធ្វើនីតិវិធីបំបែកក្បាលដីអចលនវត្ថុដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ ស្ថិតនៅផ្លូវជាតិលេខ៦ ភូមិ ឃុំ ស្រុក ខេត្តកំពង់ចាម ជា ២ក្បាលដីក្នុងចំណែកស្មើគ្នា ស្របតាមចំណុចទី២ ខាងលើ ។

២-៣- នាពេលទាញហេតុផលដោយផ្ទាល់មាត់នេះ ភាគីម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងនូវមូលហេតុនៃបណ្ដឹងឧទ្ធរណ៍ថា៖

- ផ្អែកតាមកិច្ចសន្យាលក់ផ្ដាច់ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ បានបញ្ជាក់ឲ្យឃើញថា មានតែកូនក្ដីខ្លួនឈ្មោះ និងប្រពន្ធឈ្មោះ ប៉ុណ្ណោះ ដែលជាអ្នកទិញដីទំនាស់ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ ពីឈ្មោះ និងប្រពន្ធឈ្មោះ គឺពុំមានឯកសារ និងសំអាងណា ដែលស្ដែងឲ្យឃើញថា ជាការទិញដីចូលហ៊ុនគ្នា រវាងភាគីកូនក្ដីខ្លួន ជាមួយឈ្មោះ និងប្រពន្ធឈ្មោះ នោះឡើយ។
- ចំពោះចម្លើយសាក្សីឈ្មោះ និងឈ្មោះ ដែលឆ្លើយបញ្ជាក់ប្រហាក់ប្រហែលគ្នាថា ឈ្មោះ ពិតជាបានចូលហ៊ុនទិញដីជាមួយឈ្មោះ និងប្រពន្ធឈ្មោះ នោះ គឺគ្រាន់តែជាការបានលឺពីឈ្មោះ ប្រាប់ប៉ុណ្ណោះ ហើយការអះអាងនេះ ហាក់បីដូចជាមានការរៀបចំទុកជាមុន ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នាទៅនឹងការទាមទាររបស់តតិយជនឈ្មោះ ឈីវ មួយ តែប៉ុណ្ណោះ ។
- ចំពោះការបង្កើតឯកសារដែលមានទម្រង់លិខិតលក់ផ្ដាច់ និងឯកសារផ្សេងៗទៀត ក៏ពុំបានឆ្លុះបញ្ចាំងអំពីឆន្ទៈពិតរបស់ភាគីក្នុងការលក់ទិញនោះដែរ ជាពិសេសក្នុងទម្រង់លិខិតលក់ផ្ដាច់នោះមានចំណុចមិនប្រក្រតីជាច្រើនមានដូចជា ត្រង់ផ្នែកខាងខ្នងនៃទម្រង់លក់ផ្ដាច់មានស្នាមផ្ដិតមេដៃសាក្សីចំនួន ពីររូប ដែលចំណុចនេះសាក្សីឈ្មោះ អះអាងថា ជាស្នាមមេដៃរបស់ឈ្មោះ និងឈ្មោះ គឺពុំមែនជាការពិតនោះឡើយ។
- ស្នាមមេដៃរបស់សាក្សីម្នាក់ៗលើទម្រង់លិខិផ្ទេរកម្មសិទ្ធិ គឺពុំមានភាពច្បាស់លាស់ដែលអាចកំណត់ថាជាស្នាមមេដៃរបស់បុគ្គលណាមួយឱ្យប្រាកដនោះទេ ហើយក្នុងទម្រង់លិខិតលក់ផ្ដាច់ និងឯកសារផ្សេងៗទៀតពាក់ព័ន្ធនឹងការផ្ដិតស្នាមមេដៃភាគច្រើនបំផុតមានតែផ្ដិតមេដៃទុកជាមុនរបស់តតិយជនឈ្មោះ និងមានសរសេរអក្សរទុកខាងក្រោមស្នាមមេដៃនោះ។

២-៤- ទាក់ទងនឹងមូលហេតុនៃបណ្ដឹងឧទ្ធរណ៍ដូចខាងលើនេះ ភាគីចុងបណ្ដឹងឧទ្ធរណ៍បានឆ្លើយតបថា

- ភាគីខ្លួនសុំបដិសេធចោលនូវមូលហេតុទាំងឡាយដែលម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើងដូចខាងលើ ដោយសំអាងលើអង្គហេតុ និងសំអាងជាសក្ខីកម្មលើសាក្សី ដូចខាងក្រោម៖
  - ✓ សាក្សីឈ្មោះ បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ថា ខ្លួនពិតពិតជាបានទិញដីចូលគ្នាហ៊ុនគ្នា ជាមួយភាគីឈ្មោះ និងប្រពន្ធឈ្មោះ ពិតប្រាកដមែន ហើយដោយសារឈ្មោះ មានការជីវភាពខ្វះខាត ក៏បានយកភាគជាចំណែករបស់ខ្លួនលើដីទំនាស់នោះមក

លក់ឲ្យកូនក្តីរបស់ខ្លួនឈ្មោះ នៅក្នុងឆ្នាំ និងកស្តុតាងជាក់ស្តែងលើអង្គហេតុនេះ គឺក្រោយពេលទិញ កូនក្តីខ្លួនក៏បានចំណាយប្រាក់ទិញដី យកទៅចាក់លើទីតាំងនៃដីទំនាស់នោះនៅក្នុងឆ្នាំ ការចាក់ដីនេះ គឺចាត់ទុកជាការទទួលស្គាល់របស់ឈ្មោះ និងប្រពន្ធហើយ ដោយហេតុថា រហូតមកទល់ពេលនេះ គឺពុំមានការតវ៉ាអ្វីទាក់ទងនឹងការចាក់ដីនាពេលនោះទេ។

- ✓ ដោយផ្អែកតាមចម្លើយសាក្សីជាប្រធានភូមិបាលស្រុកបាធាយ បានបញ្ជាក់យ៉ាងច្បាស់ថា ឈ្មោះ ឈ្មោះ និងឈ្មោះ ពិតជាបានមកផ្តិតមេដៃដើម្បីបំបែកក្បាលដីជាពីរចំណែកស្មើគ្នា ប៉ុន្តែដោយសារតែនៅពេលវាស់វែងជាក់ស្តែងលើទីតាំងដី ក៏មានភាពខ្វែងគ្នាលើចំណុចពុះចែកគ្នា ដោយមួយចំណែកមានទំហំលើសពីពាក់កណ្តាល ក៏ធ្វើឱ្យគូភាគីមិនឯកភាពគ្នា ហើយក៏បានពន្យាពេលសិន និងឯកសារបំបែកក្បាលដីក៏បានឯកភាពគ្នានៅសាក្សីជាប្រធានភូមិបាលស្រុកបាធាយ លុះក្រោយពីឈ្មោះ បានទទួលមរណភាព កូនៗរបស់លោក ក៏បានទៅដកប្លង់បំបែកក្បាលដីវិវាទនោះពីសុរិយោដីវិញ។

២-៥- យោងតាមសំអាងហេតុដូចខាលើ ជាពិសេសដោយផ្អែកតាមសក្ខីកម្មរបស់សាក្សីជាមន្ត្រីជំនាញ និងមូលដ្ឋាន នាពេលទាញហេតុផលដោយផ្ទាល់មាត់នេះ ក្រុមប្រឹក្សាជំនុំជម្រះពិចារណាឃើញថា៖

- តាមការអះអាងរបស់សាក្សីឈ្មោះ និងប្រពន្ធឈ្មោះ , សាក្សីឈ្មោះ , សាក្សីឈ្មោះ និងឈ្មោះ ជាមន្ត្រីជំនាញនៅមូលដ្ឋានដីទំនាស់ ក៏ដូចជាអង្គហេតុនៃការចាក់ដីបំពេញលើចំណែកនៃដីទំនាស់ ពិតជាស្តែងឲ្យឃើញពីអត្ថិភាពនៃអង្គហេតុនៃការចូលហ៊ុនគ្នារវាងភាគីដើមចោទឈ្មោះ និងប្រពន្ធ ជាមួយឈ្មោះ ក្នុងការទិញដីទំនាស់ពីឈ្មោះ និងប្រពន្ធឈ្មោះ ហើយឈ្មោះ ពិតជាបានលក់ដីដែលជាចំណែករបស់ខ្លួនលើដីទំនាស់ឲ្យទៅភាគីឈ្មោះ ប្រាកដមែន រហូតដល់ភាគីខាងលោកស្រី បានចាប់ផ្តើមចូលគ្រប់គ្រងដោយការចាក់ដី និងគូភាគីបាននាំគ្នាទៅពឹងមន្ត្រីសុរិយោដីឲ្យជួយបំបែកក្បាលដីឲ្យគូភាគីជាពីរចំណែកផងដែរ ។
- ការលើកឡើងរបស់ភាគីដើមបណ្តឹងឧទ្ធរណ៍ ក៏ដូចជាមេធាវីតំណាងដោយអាណត្តិដែលបានលើកឡើងអំពីមូលហេតុនៃបណ្តឹងឧទ្ធរណ៍ដូចមានក្នុងចំណុច ២-៣ ខាងលើ មិនមានមូលដ្ឋានដែលអាចជឿជាក់បានទេ ដោយហេតុថា បានត្រឹមតែធ្វើសេចក្តីសន្និដ្ឋានផ្អែកតាមការយល់ឃើញរបស់ខ្លួនតែប៉ុណ្ណោះ ដោយមិនបានលើកនូវសក្ខីកម្ម ឬសំអាងផ្សេងៗ ដែលនាំឲ្យឃើញពីអត្ថិភាពនៃអង្គហេតុ ដែលភាគីខ្លួនបានលើកឡើងដើម្បីការពារមូលហេតុនៃបណ្តឹងឧទ្ធរណ៍របស់ខ្លួននោះឡើយ ពោលគឺ សំអាងហេតុរបស់ភាគីម្ចាស់បណ្តឹងឧទ្ធរណ៍មិនមានឧត្តមានុភាពលើសពីអត្ថិភាពនៃអង្គហេតុ និងសំអាងនានាដែលសាលាដំបូងបានទទួលពិនិត្យ និងយកជាមូលដ្ឋានក្នុងសាលក្រមរបស់ខ្លួននោះឡើយ។

២-៦- សរុបមក ក្រុមប្រឹក្សាជំនុំជម្រះពិចារណាឃើញថា ការវិនិច្ឆ័យសេចក្តីរបស់សាលាដំបូងខេត្តកំពង់ចាម តាមសាលក្រមរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ គឺបានផ្អែកលើមូលដ្ឋាននៃអត្ថិភាពអង្គហេតុច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយតាមផ្លូវច្បាប់ហើយ ដែលក្រុមប្រឹក្សាជំនុំជម្រះឯកភាពតាម និងមិនចាំបាច់លើកយកសំអាងហេតុដ៏ដែលៗមកបញ្ជាក់ជាថ្មីទៀតនោះទេ ដូចនេះគប្បីទទួលស្គាល់សាលក្រមរដ្ឋប្បវេណីខាងលើនេះទុកជាបានការដដែល។

២-៧- ចំពោះប្រាក់ប្រដាប់ក្តីនៅសាលាឧទ្ធរណ៍ ត្រូវជាបន្ទុករបស់ដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៣. សេចក្តីសម្រេចបញ្ចប់

៣-១- ច្រានចោលបណ្តឹងឧទ្ធរណ៍លេខៈ **០៥ ស្ហួន** ចុះថ្ងៃទី ខែ ឆ្នាំ របស់ដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ ។

៣-២- ទទួលស្គាល់សាលក្រមរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល។

៣-៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ ។

៣-៤- សាលដីកានេះប្រកាសជាសាធារណៈនាព្រឹក ថ្ងៃព្រហស្បតិ៍ ១៣ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ។

គូភាគីមានសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេល ១ ខែ បន្ទាប់ពីបានទទួលការបញ្ជូនសាលដីកានេះ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| **ស៊ីម សុតា** | **ខៀវ ផាន់ណា** | **រឿល សុគិន** | **ម៉ុខ មុនីចរិយា** |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៣ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ត្បូងឃ្មុំ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ម៉ុខ មុនីចរិយា**

**ក្រឡាបញ្ជី**

ប៉ែន ផាន់នី

សាលាដំបូងរាជធានីភ្នំពេញ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ដីកាសម្រេចបែងចែកម៌ក

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីដែល
មិនមែនជាបណ្តឹងលេខ១៥៩ ចុះ
ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០១៧
ដីកាសម្រេចលេខ ១២៣ "ង"
ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨

-បានឃើញច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី ១៦-០៧-២០១៤

-បានឃើញមាត្រា **២៦**នៃច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

-បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃ**ទី១៥ ខែមករា ឆ្នាំ២០១៨** និងបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈ នៅថ្ងៃ**ទី០៧ ខែធ្នូ ឆ្នាំ២០១៧** ដោយមានសមាសភាព ៖

### ចៅក្រមជំនុំជម្រះ

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជី

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

## អង្គហេតុ និងការអះអាងរបស់ភាគី

**ក.ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឲ្យតុលាការចេញ**

១. អ្នកដាក់ពាក្យសុំ A ធ្វើលទ្ធកម្មចំណែកអវិភាគ ១ភាគ២នៃអចលនវត្ថុដូចក្នុងបញ្ជីសារពើភ័ណ្ឌ១ និង រថយន្តដូចក្នុងបញ្ជីសារពើភ័ណ្ឌ៣។

២. ភាគីម្ខាងទៀតនៃពាក្យសុំ B ធ្វើលទ្ធកម្មប្រាក់ក្នុងគណនីដូចក្នុងបញ្ជីសារពើភ័ណ្ឌ២។

ទី៣ បង្គាប់ឲ្យអ្នកដាក់ពាក្យសុំ A បង់ប្រាក់ចំនួន 35,000$ ដែលជាប្រាក់សម្រួលនៃលទ្ធកម្មមត៌កខាងលើឲ្យទៅភាគីម្ខាងទៀតនៃពាក្យសុំ B។

**ខ. អង្គហេតុ**

**ខ.១ ការសង្ខេបរឿងក្តី**

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤

**ខ.២. ការអះអាងរបស់ភាគី**

**-ការអះអាងរបស់អ្នកដាក់ពាក្យសុំ A**

អ្នកដាក់ពាក្យសុំបាន

**-ការអះអាងរបស់ភាគីម្ខាងទៀតនៃពាក្យសុំ B**

ភាគីម្ខាងទៀតនៃពាក្យសុំបានអះអាងថា

**សំអាងហេតុ**

**ក. ស្តីពីចំណុចទាមទារទី១**

**ក.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

-ករណីរឿងក្តីនេះ

-

**ក.២. ការវិនិច្ឆ័យអំពីចំណុចទាមទារ**

-ករណីនេះ

-

**ខ. ស្តីពីចំណុចទាមទារទី២**

**ខ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

-ករណីនេះ

-

**ខ.២.ការវិនិច្ឆ័យអំពីចំណុចទាមទារ**

-ករណីនេះ

-

**គ. ស្តីពីចំណុចទាមទារទី៣**

**គ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

២ (ពីរ) សប្តាហ៍មុន

**គ.២.ការវិនិច្ឆ័យអំពីចំណុចទាមទារ**

សាក្សី B បានអះអាងថា

**ឃ.សេចក្តីសន្និដ្ឋាន**

-

-

ជាសរុប តុលាការនឹងសម្រេចរឿងក្តីនេះ ដូចខាងក្រោម ៖

## សេចក្ដីសម្រេចបញ្ចប់

១.អ្នកដាក់ពាក្យសុំធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្ដីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ។

២.ភាគីម្ខាងទៀត......ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ២ស្ដីពីមត៌ក និងសាច់ប្រាក់ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ៣ស្ដីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ ។

ដីកាសម្រេចនេះប្រកាសជាសាធារណៈនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨ ចំពោះមុខភាគី និងអ្នកតំណាងដោយអាណត្តិរបស់ភាគី។ ទុកសិទ្ធិឲ្យភាគីប្ដឹងជំទាស់ក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតដីកាសម្រេចនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨

**ចៅក្រម**

# ឧបសម្ព័ន្ធទី៣
# លិខិតជូនដំណឹង និងដីកា
# បង្គាប់ផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី
លេខ ..............................
ចុះថ្ងៃទី..........ខែ.........ឆ្នាំ២០...

**ដីកាបង្គាប់ឱ្យដាក់លិខិតបញ្ជាក់**
**អំពីមូលហេតុ នៃបណ្តឹងសាទុក្ខ**

យើង .............................ចៅក្រមទទួលបញ្ជារបស់ក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល បង្គាប់មកលោក-លោកស្រី..............................អាយុ..........ឆ្នាំ មានមុខរបរ.................. អាសយដ្ឋាន: ផ្ទះលេខ..........ក្រុម/ផ្លូវ............ភូមិ......................សង្កាត់/ឃុំ ...................... ខណ្ឌ/ស្រុក..........................រាជធានី/ខេត្ត............................................................ ជាដើមបណ្តឹងសាទុក្ខ ឱ្យធ្វើលិខិតបញ្ជាក់អំពីមូលហេតុនៃ បណ្តឹងសាទុក្ខ ដែលបានប្តឹងពីសាលដីការដ្ឋប្បវេណី លេខ..............ចុះថ្ងៃទី..............ខែ..............ឆ្នាំ..............របស់សាលាឧទ្ធរណ៍ ដាក់ជូនតុលាការកំពូល ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូនដីកានេះ ។

**សំគាល់:** "បើដើមបណ្តឹងសាទុក្ខមិនដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ តាមដីកានេះទេ តុលាការកំពូលនឹងលើកបណ្តឹងសាទុក្ខចោល តាមចំណុចខ មាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី" ។

10/3/2015

ភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ..........
ចៅក្រម

សែម.សក្តិកុឡា

មហាវិថីសម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, កម្ពុជា
Samdech Sothearos Blvd, Sangkat Chatomouk, Khan Daun Penh, Phnom Penh, Cambodia.
ទូរស័ព្ទទូរសារ : (៨៥៥-២៣-) ២១២៨២៦
Phone/fax: (855-23) 212 826

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភារដ្ឋប្បវេណី

# លិខិតជូនដំណឹង
# អំពីការទទួលពាក្យបណ្តឹងជំទាស់ និង
# ឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់

យើង............................ ចៅក្រមទទួលបញ្ហានៃក្រុមប្រឹក្សាជំនុំជម្រះតុលាការកំពូល

## ជូនដំណឹង

ម្ចាស់បណ្តឹងជំទាស់ឈ្មោះ .................... ភេទ ..... កើតនៅថ្ងៃទី ... ខែ ...... ឆ្នាំ ....... អាយុ .... ឆ្នាំ សញ្ជាតិ ..... អាសយដ្ឋានផ្ទះលេខ ........... ផ្លូវលេខ ......... ភូមិ ................... ឃុំ/សង្កាត់ ...................... ស្រុក/ខណ្ឌ .................................. រាជធានីភ្នំពេញ/ខេត្ត .................................. ដូចខាងក្រោម :

១. តុលាការកំពូលបានទទួលពាក្យបណ្តឹងជំទាស់ របស់ម្ចាស់បណ្តឹងជំទាស់ ដោយចុះក្នុងបញ្ជីសំណុំរឿងរដ្ឋប្បវេណីលេខ .............. ចុះថ្ងៃទី ....... ខែ ........... ឆ្នាំ .................. ។

២. ម្ចាស់បណ្តឹងជំទាស់ត្រូវដាក់លិខិតបញ្ជាក់ អំពីមូលហេតុនៃបណ្តឹងជំទាស់ ក្នុងអំឡុងពេល **២ សប្តាហ៍** គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតជូនដំណឹងនេះ ។

បើម្ចាស់បណ្តឹងជំទាស់ មិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់ តាមការកំណត់ខាងលើ តុលាការកំពូលត្រូវលើកពាក្យបណ្តឹងជំទាស់ចោល តាមមាត្រា ៣០៤ និងមាត្រា ២៩០ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ ឆ្នាំ ២០១........

ចម្លងជូន :

ចុងបណ្តឹងជំទាស់ឈ្មោះ ........................

ដោយភ្ជាប់ជាមួយនឹងពាក្យបណ្តឹងជំទាស់

ចុះថ្ងៃទី .......... ខែ ............ ឆ្នាំ .............

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង...

ខ្ញុំបាទ/នាងខ្ញុំមេធាវី.............ជាមេធាវីតំណាងដោយអាណត្តឲ្យឈ្មោះ...........អាយុ...................ឆ្នាំ ជនជាតិខ្មែរ មុខរបរ......មានទីលំនៅបច្ចុប្បន្នភូមិ........................................................................... ក្នុងករណី សុំទាមទារដី-ផ្លាកទីន និង ម៉ូតូ មានសំណុំរឿងរដ្ឋប្បវេណីលេខ................ចុះថ្ងៃទី...........ខែ........ ឆ្នាំ...............របស់.....................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន**................................................

**កម្មវត្ថុៈ** សុំធ្វើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង...............ដើម្បីការពារផលប្រយោជន៍របស់កូនក្តី ខ្ញុំបាទ/នាងខ្ញុំក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ......ចុះថ្ងៃ.........ខែ...........ឆ្នាំ................របស់ .......................។

យោង -ដីកាបង្គាប់ឲ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹង........ចុះថ្ងៃទី........ខែ...............ឆ្នាំ ..................របស់......................។

-សំណុំរឿងរដ្ឋប្បវេណីលេខ..................ចុះថ្ងៃទី..............ខែ...............ឆ្នាំ............របស់ ...............។

ពាក្យតំណាងដោយអាណត្តចុះថ្ងៃទី..............ខែ .................ឆ្នាំ....................។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបពីដំណើររឿងដូចខាងក្រោមៈ

**១/អំពីអង្គហេតុ**..........................................................................................................
....................................................................................................................................
....................................................................................................................................
....................។

**២/អង្គច្បាប់**..............................................................................................................
....................................................................................................................................
....................................................................................................................................
....................។

**៣/អំពីការសម្រេចសេចក្តីរបស់តុលាការ**......................................................................
....................................................................................................................................

.................................................................................................................................................

.................................................................................................................................................

...................។

**៤/សំណូមពរ**.........................................................................................................

.................................................................................................................................................

.................................................................................................................................................

.........................។

អាស្រ័យដូចបានជម្រាបខាងលើសូម ឯកឧត្តមប្រធាន មេត្តាទទួលនូវការស្នើសុំរបស់ខ្ញុំបាទ នាងខ្ញុំ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពស់ខ្ពង់អំពីខ្ញុំបាទ/នាងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ ........ឆ្នាំ...........

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# ដីកាបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្តី

សំណុំរឿងរដ្ឋប្បវេណី

លេខ ....................

ចុះថ្ងៃទី ..........

យើង ..............................ចៅក្រមទទួលបញ្ហារបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃតុលាការកំពូល
បង្គាប់មកឈ្មោះ ...... ...............ភេទ .. អាយុ ......ឆ្នាំ
អាសយដ្ឋាន: ផ្ទះលេខ............ក្រុម/ផ្លូវ..................ភូមិ..... ...........សង្កាត់/ឃុំ.....
ខណ្ឌ/ ស្រុក... រាជធានី/ខេត្ត មុខរបរ..
ឲ្យមកបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធចំនួន ១០០.០០០ (ដប់ម៉ឺន)រៀល ក្នុងអំឡុងពេល......30.....ថ្ងៃ
បន្ទាប់ពីបានទទួលការបញ្ជូនដីកានេះពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ.........ចុះថ្ងៃទី.
.........ខែ............ឆ្នាំ.....................របស់សាលាឧទ្ធរណ៍ ទៅសភារដ្ឋប្បវេណីនៃតុលាការកំពូល ។

**<u>សំគាល់:</u>** "បើម្ចាស់បណ្តឹងសាទុក្ខមិនយកប្រាក់មកបង់តាមដីកានេះទេ តុលាការកំពូលនឹងលើកបណ្តឹងសាទុក្ខចោល តាមចំណុច ក មាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី" ។

ភ្នំពេញ, ថ្ងៃទី ........ ខែ ............ ឆ្នាំ

ចៅក្រម